ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ ១៤
ឆ្នាំ២០២៣



# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# បុព្វកថា

ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន**កម្ពុជាបានហែលឆ្លងគ្រោះជំងឺរាតត្បាតសកលដ៏សាហាវកូវីដ-១៩ ដែលអូសបន្លាយជាង ២ ឆ្នាំ កន្លងមកនេះ បានយ៉ាងល្អប្រសើរ ដោយអាចដំណើរការខ្សែច្រវ៉ាក់សេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិឱ្យងើបឡើងវិញយ៉ាងឆាប់រហ័សដោយឈរនៅលំដាប់ប្រទេសដែលអាចនិយាយបានថាជោគជ័យខ្លាំង។ យ៉ាងណាមិញ ពិភពលោកបានជួបប្រទះនូវវិបត្តិថ្មីមួយផ្សេងទៀត គឺសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន ខណៈជំងឺកូវីដ-១៩ នៅបន្សល់ស្លាកស្នាម ដែលអាចបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចក្នុងតំបន់ ដោយសារតែកំណើនសេដ្ឋកិច្ចសកលយឺត ការកើនឡើងតម្លៃទំនិញ និងការរឹតបន្តឹងល័ក្ខខ័ណ្ឌហិរញ្ញវត្ថុ ក្នុងការឆ្លើយតបនឹងអតិផរណារយៈពេលយូរ។ ទោះក្នុងបរិការណ៍នេះក្តី ក៏សេដ្ឋកិច្ចកម្ពុជានៅតែរំពឹងថានឹងឈានទៅរកកំណើនឡើងវិញ ដោយសារស្ថិរភាពនយោបាយក្នុងប្រទេសមានភាពរឹងមាំ និងភាពចាស់ទុំផ្នែកនយោបាយរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ដែលទើបតែបានប្រព្រឹត្តិទៅថ្មីៗ ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងអនុលោមតាមច្បាប់ជាធរមាន ដោយអត្រាប្រជាជនទៅបោះឆ្នោតខ្ពស់រហូតដល់ ៨៤,៥៨% លើសពីការបោះឆ្នោត ៤ ដងកន្លងមក គិតតាំងពីឆ្នាំ២០០៣។

ដើម្បីដឹកនាំកម្ពុជាឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, រាជរដ្ឋាភិបាលបានដាក់ចេញនិងអនុវត្តនូវគោលនយោបាយ, យុទ្ធសាស្ត្រ និងកម្មវិធីជាច្រើនដែលក្នុងនោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០០៤និងបានអនុវត្តដោយជោគជ័យ៣ដំណាក់កាលរួចមកហើយ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានប្រកាសដាក់ឱ្យអនុវត្តដំបូងនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ជាមួយចក្ខុវិស័យ **“ការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដោយផ្លាស់ប្តូរពីប្រព័ន្ធដែលផ្តោតលើធាតុចូលនិងមានលក្ខណៈមជ្ឈការ ទៅកាន់ប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ក្នុងកម្រិតឧត្តមានុវត្តន៍និងស្តង់ដារអន្តរជាតិ”**។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងឈរនៅ ដំណាក់កាលទី ៤ ដែលត្រូវបានប្រកាសដាក់អោយអនុវត្តនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលដំណាក់កាលទី ៤ នេះ ផ្តោតលើ “គណនេយ្យភាពសមិទ្ធកម្ម” អនុវត្តចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។

បន្ទាប់ពីទទួលបានជោគជ័យក្នុងការអនុវត្តដំណាក់កាលទាំង ៣ កន្លងមក ប្រទេសកម្ពុជាបានប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងគ្រប់គ្រងចំណូល ចំណាយរបស់ខ្លួនឱ្យមានប្រសិទ្ធភាពសម្រាប់កិច្ចអភិវឌ្ឍប្រកបដោយឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ស្របតាមបាវចនា ២ ៖ **“កែទម្រង់ខាងក្នុង, បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ”** និងអភិក្រមទាំង ៥ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** គឺ៖ **“ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និងវះកាត់”**។ ការអនុវត្តនេះស្របតាមអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត ដំណាក់កាលទី ៤ ដែលបានមានប្រសាសន៍ថា **“យើងមិនរង់ចាំទាល់តែមានសន្តិភាពពេញលេញ និងមានធនធានគ្រប់គ្រាន់ ទើបយើងធ្វើការកែទម្រង់នោះទេ”** គឺយើងរក្សាខ្ជាប់នូវស្មារតី **“ធ្វើបណ្តើរ, រៀនបណ្តើរ, និងកែលម្អបណ្តើរ”** ដើម្បីស្របតាម យុទ្ធសាស្ត្រកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា។

ឆ្លងកាត់រយៈពេលជិត ២ ទសវត្សន៍ កន្លងមកនេះ ការអនុវត្តដំណាក់ទាំង ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបានសមិទ្ធផលខ្ពស់ និងបានជំនះដោយជោគជ័យក្នុងការកែទម្រង់សមាសធាតុគន្លឹះៗ នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា នៅលើផ្លូវត្រូវឆ្ពោះទៅកាន់ចក្ខុវិស័យដែលបានកំណត់។ សមិទ្ធិផលទាំងអស់នេះពុំអាចសម្រេចបាននោះទេ ប្រសិនបើមិនមានការគាំទ្រ និងការចូលរួមយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវ និងការប្តេជ្ញាចិត្តឥតងាករេពីថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍។ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់សូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ទាំងការងារដឹកនាំ សម្របសម្រួល គាំទ្រ ផ្សព្វផ្សាយ ត្រួតពិនិត្យ ព្រមទាំងវាយតម្លៃ ប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម៕

ថ្ងៃ អង្គារ ៩រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ក្នុងឆ្នាំ២០២៣ នេះ កម្ពុជាបានរងឥទ្ធិពលនៃសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន គួបផ្សំនឹងស្លាកស្នាមដែលបានបន្សល់ពីវិបត្តិជំងឺកូវីដ-១៩ ដែលបាននឹងកំពុងបន្តបង្កជាផលប៉ះពាល់មកលើទិដ្ឋភាពសង្គម សេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងបន្តឈានទៅរកកំណើនឡើងវិញ បន្ទាប់ពីអាចគ្រប់គ្រងបានយ៉ាងល្អនូវស្ថានភាពជំងឺកូវីដ-១៩ តាមរយៈការសម្រេចបាននូវភាពស៊ាំសហគមន៍ និងការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី ក៏ដូចជាការដាក់ចេញនូវវិធានការអន្តរាគមន៍ ផ្នែកសង្គម សេដ្ឋកិច្ច បានរហ័ស និងចំទិសដៅ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងធានាស្ថិរភាពអាជីវកម្ម។ លើសពីនេះ ដើម្បីឈានទៅរកកំណើនដែលរំពឹងទុក គឺយើងត្រូវរក្សាឱ្យបាននូវស្ថិរភាពនយោបាយនិងសុខសន្តិភាពជាតិ ដែលនាំឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចឈានមកដល់ដំណាក់កាលនេះ និងទទួលបានការទុកចិត្តនិងគាំទ្រដ៏ច្រើនលើសលប់ពីសំណាក់ប្រជាជនដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី ៧ នៃរដ្ឋសភា។

ជាផ្នែកមួយ ក្នុងការចូលរួមធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកៀរគរចំណូលជាតិ ប្រកបដោយប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន ក៏ដូចជាការចំណាយឱ្យចំគោលដៅស្របតាមគោលនយោបាយជាតិនិងការគ្រប់គ្រងបានល្អនូវបំណុលសាធារណៈដើម្បីធានាបាននូវសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈដែលមានភាពធនធារភាព បរិយាប័ន្ន ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព ភាពជាម្ចាស់ ឯករាជ្យភាព និងការអភិវឌ្ឍជាតិ។ បន្ទាប់ពីការអនុវត្តយ៉ាងជោគជ័យនូវ ៣ ដំណាក់កាលរួចមក បច្ចុប្បន្នកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្ថិតនៅ ដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ ដែលផ្តោតលើ “គណនេយ្យភាពសមិទ្ធកម្ម” ហើយដំណាក់កាលនេះមានគោលដៅពង្រឹង និងពង្រីកប្រព័ន្ធគណនេយ្យសារធារណៈ ប្រព័ន្ធសវនកម្មនិងអធិការកិច្ចហិរញ្ញវត្ថុ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) យុទ្ធសាស្ត្រកែទម្រង់ និងច្បាប់គន្លឹះសំខាន់ៗ ដើម្បីជាមូលដ្ឋានគ្រឹះនៃ “ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម”។

ឆ្លងកាត់រយៈពេល ២០ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានទទួលផលបណ្តើរៗ ដូចជា ការពង្រឹងគុណភាពអភិបាលកិច្ចល្អ ការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដ៏រឹងមាំ ការអភិវឌ្ឍធនធានមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបានការគាំទ្រ និងសាទរពីសំណាក់សាធារណជនទូទៅ និងអាចដើរមកដល់ដំណាក់កាលទី ៤ នេះ បានគឺដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍ផងដែរ។ ដូចនេះដើម្បីបន្តលើកកម្ពស់ការយល់ដឹង និងការគាំទ្រដល់ទិសដៅ និងចក្ខុវិស័យ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដែលជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) នៅតែបន្តបេសកកម្មរបស់ខ្លួនឥតងាករេ ក្នុងការបញ្ជ្រាបការយល់ដឹងថ្មីៗបន្ថែម ក៏ដូចជាផ្សព្វផ្សាយនូវសមិទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់ តាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ការផ្សព្វផ្សាយ និងកិច្ចប្រជុំនានា។

ជាក់ស្តែង ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ ១៤ នេះ នឹងចងក្រងនូវបច្ចុប្បន្នភាពនៃព្រឹត្តិការណ៍ អត្ថបទ សុន្ទរកថា និងទស្សនៈ និងមតិ របស់ថ្នាក់ដឹកនាំសំខាន់ៗ ដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានតម្លៃជាច្រើនអាចផ្តល់ជាប្រយោជន៍បន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជនដែលចង់សិក្សា និងឈ្វេងយល់អំពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល៕

ថ្ងៃ សុក្រ ៦កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកានុក្រម

## ១ ព្រឹត្តិការណ៍


១ | ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម"

៩ | ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការ ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១

១៩ | កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ បូក ២

២៧ | សិក្ខាសាលាពិគ្រោះយោបល់ស្តីពី"ការចែករំលែកបទពិសោធន៍នៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"

៣៥ | ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការស្តីពី កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប សម្រាប់គាំទ្រការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤


## ២ អត្ថបទ


បទពិសោធន៍ជោគជ័យរបស់ប្រទេសសិង្ហបុរីលើការរៀបចំគោលនយោបាយអនុវត្តថវិកានិងការផ្តល់សេវាសាធារណៈ | ៤៥

ការវាយតម្លៃប្រសិទ្ធភាពប្រព័ន្ធនិងការគ្រប់គ្រងថវិកានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ៥៥

កំណែទម្រង់ពន្ធលើចលនទ្រព្យ និងអចលនទ្រព្យនៅអាស៊ីអាគ្នេយ៍ | ៦៣

ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន | ៧៣

# ៣ សុន្ទរកថា

៧៧ | សុន្ទរកថាគន្លឹះរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថ្លែងក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ “គណនេយ្យភាពសមិទ្ធកម្ម” នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៨៥ | សុន្ទរកថា ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្លែងក្នុងពិធីបិទការប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ “គណនេយ្យភាពសមិទ្ធកម្ម” នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ៤ ទស្សនៈ និងមតិ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងនៅក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧ “គណនេយ្យភាពសមិទ្ធកម្ម” | ៩១

សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. ថ្លែងក្នុងកម្មវិធីបិទពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនូវចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល” | ៩៣

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្លែងក្នុងកម្មវិធីបើកពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនូវចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល” | ៩៤

ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ថ្លែងក្នុងកម្មវិធីបើកសិក្ខាសាលាពិគ្រោះយោបល់លើចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល” | ៩៥

ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈថ្លែងក្នុងកម្មវិធីបិទសិក្ខាសាលាពិគ្រោះយោបល់លើចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល” | ៩៦





# ទិសដៅនៃកម្មវិធី កែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ នៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភា

ការបើកសម័យប្រជុំពេញអង្គរដ្ឋសភានីតិកាលទី ៧ នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ គឺការឈានចូលទំព័រប្រវត្តិសាស្ត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបន្តបេសកកម្មដ៏ឧត្តុងឧត្តម ដើម្បីពន្លឿនកិច្ចអភិវឌ្ឍជំរុញការងារកែទម្រង់ និងកសាងជាតិមាតុភូមិឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងស្របតាមឆន្ទៈនិងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា។

## ការធានា ៥ យ៉ាងរបស់រាជរដ្ឋាភិបាលតាមរយៈការដឹកនាំអនុវត្ត កម្មវិធីនយោបាយនៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភា៖



ទី១៖

**ការធានាការពារឱ្យបានជាដាច់ខាត នូវសន្តិភាព, ស្ថិរភាព, សន្តិសុខ និងសុវត្ថិភាព** សម្រាប់ការរស់នៅប្រកបដោយសុខក្សេមក្សាន្តរបស់ប្រជាជន នៅគ្រប់ទិសទីក្នុងផ្ទៃប្រទេស, ព្រមទាំងការការពារ **ឯករាជ្យ, អធិបតេយ្យ** និង**បូរណភាពទឹកដី** ឱ្យបានគង់វង្សចីរកាល មិនឱ្យកម្លាំងណាមកបំពាន ឬបំផ្លាញបានឡើយ។

ទី២៖

**ការធានាបន្តជំរុញអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាក្នុងគ្រប់វិស័យ** ដោយផ្តោតអាទិភាពលើការកែទម្រង់អភិបាលកិច្ច សំដៅពង្រឹងស្ថាប័នសាធារណៈ ដែលមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ រួមបញ្ចូលផងដែរនូវការពង្រឹងគោលការណ៍នីតិរដ្ឋ និងការពង្រឹងយុត្តិធម៌ក្នុងសង្គម ព្រមទាំងការបង្កើនប្រសិទ្ធភាពនិងការលើកកម្ពស់គុណភាពសេវាសាធារណៈ,ការពង្រឹងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដែលមានស្ថិរភាពរឹងមាំ ធន់នឹងវិបត្តិ និងទ្រទ្រង់ដល់កំណើនខ្ពស់ ប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌,ការបន្តផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើមូលធនមនុស្សដោយផ្តោតលើការកែទម្រង់វិស័យអប់រំ និងវិស័យសុខាភិបាល, ការលើកកម្ពស់និងការបង្កើនការវិនិយោគ, ទាំងការវិនិយោគសាធារណៈ ទាំងការវិនិយោគឯកជន, លើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា, ទាំងផ្នែករឹងនិងផ្នែកទន់ ដើម្បីបង្កើនភាពទាក់ទាញ និងគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ក៏ដូចជាបម្រើដល់សេចក្តីត្រូវការគ្រប់ផ្នែករបស់ប្រជាជន,ការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសេដ្ឋកច្ចិក្រៅប្រព័ន្ធនិងការបង្កើតបរិយាកាសអំណោយផលដល់សហគ្រាសធុនមីក្រូតូចនិងមធ្យម និងធុរកិច្ចថ្មីឱ្យរីកលូតលាស់, ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន, ការបង្កើនភាពស៊ីជម្រៅ និងការពង្រឹងភាពធន់ហិរញ្ញវត្ថុ ព្រមទាំងការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុ រួមបញ្ចូលនូវការរៀបចំ និងការកែលម្អក្របខ័ណ្ឌ និងយន្តការហិរញ្ញប្បទាន ព្រមទាំងការធ្វើពិពិធកម្មផលិតផល និងសេវាហិរញ្ញវត្ថុ សំដៅរួមចំណែកជំរុញសកម្មភាពសេដ្ឋកិច្ច និងការវិនិយោគនិងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និងសេដ្ឋកិច្ច។ល។

ទី៣៖

**ការធានាបន្តជំរុញលើកកម្ពស់ និងកែលម្អជីវភាពរបស់ប្រជាជន** តាមរយៈការផ្តល់ជូនដល់ស្រទាប់យុវជននូវការអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពព្រមជាមួយនឹងឱកាសទទួលបានការងារធ្វើ,ការជួយកសិករក្នុងការពង្រីកផលិតកម្មនិងរកទីផ្សារលក់កសិផលឱ្យបានតម្លៃថ្លៃសមរម្យ, ការបន្តដំឡើងប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ព្រមជាមួយនឹងការកែលម្អល័ក្ខខ័ណ្ឌការងារ និងការការពារអាជីពជូនកម្មករ និយោជិត, ការបន្តដំឡើងប្រាក់បៀវត្សអប្បបរមា និងប្រាក់សោធននិវត្តន៍ជូនមន្ត្រីរាជការសាធារណៈគ្រប់រូប ព្រមទាំងនិវត្តជន និងអតីតយុទ្ធជន គួបផ្សំជាមួយនឹងការរៀបចំប្រព័ន្ធបៀវត្ស និងប្រព័ន្ធលើកទឹកចិត្ត ក្នុងវិស័យសាធារណៈឱ្យកាន់តែមាន ប្រសិទ្ធភាព និងភាពគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើគុណាធិបតេយ្យ សំដៅលើកកម្ពស់ផលិតភាពការងារ សមិទ្ធកម្ម និងជីវភាព មន្ត្រីសាធារណៈឱ្យមានសង្គតិភាព ជាមួយកំណើនសេដ្ឋកិច្ច និងលទ្ធភាពនៃថវិកាជាតិ។ល។

**ទី៤៖**

**ការធានានូវសុវត្ថិភាពសង្គម និងលំនឹងក្នុងការរស់នៅរបស់ប្រជាជន, ទាំងនាពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត** តាមរយៈការអភិវឌ្ឍ និងការពង្រឹងប្រព័ន្ធគាំពារសង្គម ដែលរួមបញ្ចូលនូវរបប ជំនួយសង្គម និងរបបសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និងចីរភាពដែលជួយគាំពារប្រជាជន គ្រប់រូប, ជាពិសេសគ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យពីគ្រោះអាសន្ន និងវិបត្តិនានា ដោយមិនទុកឱ្យប្រជាជនណាម្នាក់ទទួលរងគ្រោះដោយមិនមានការ យកចិត្តទុកដាក់ នោះឡើយ។

**ទី៥៖**

ការធានាបង្កើនការយកចិត្តទុកដាក់ដល់ ចីរភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការកសាង ភាពធន់ទៅនឹងការ ប្រែប្រួលអាកាសធាតុ តាមរយៈការប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវផលលាភ ប្រជាសាស្ត្រ និងការពង្រឹងភាពធន់នៃប្រជាសាស្ត្ររបស់កម្ពុជា, ការលើកកម្ពស់សមភាពយេនឌ័រ, ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព, ការខិតខំបង្កើនហិរញ្ញប្បទានចីរភាព សំដៅ ជំរុញការវិនិយោគបៃតង និងសេដ្ឋកិច្ចបៃតង, ការជំរុញការវិនិយោគសាធារណៈដែលមានភាពធន់ នឹងអាកាសធាតុ និងការបញ្ចេញកាបូនទាប, និងការធានាចីរភាពបរិស្ថាន ព្រមទាំងការត្រៀមខ្លួន រួចជាស្រេចដើម្បីឆ្លើយតបទៅនឹងបញ្ហានៃការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ ក្នុងនាមជា ប្រមុខនៃរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧នៃរដ្ឋសភា,ខ្ញុំក៏សូមសន្យានិងធ្វើការប្ដេជ្ញាចិត្តជាឱឡារិក ជូនបងប្អូនជនរួមជាតិ ទូទាំងប្រទេសថាខ្ញុំនឹងប្ដូរផ្ដាច់ដឹកនាំស្ថាប័ននីតិប្រតិបត្តិរបស់ជាតិ, ជានា អនុវត្តឱ្យបានសម្រេចជោគជ័យ នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលជាការសន្យារបស់ គណបក្សប្រជាជនកម្ពុជាជូនដល់ប្រជាពលរដ្ឋនៅមុនការបោះឆ្នោត, ហើយខ្ញុំក៏បានដាក់ជូនអង្គរដ្ឋ សភាដ៏ឧត្ដុង្គឧត្ដមនាពេលនេះ, ពិសេសដោយផ្ដោតការយកចិត្តទុកដាក់លើ កម្មវិធីគោលនយោបាយ ជាអាទិភាព ទាំង ៦ ដែលនឹងត្រូវបានដាក់ឱ្យចាប់ផ្ដើមអនុវត្តភ្លាម នៅក្នុងឆ្នាំ ២០២៣ នេះ រួមមាន៖

១ ការពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្ដប់សុខភាពជាសកល,

២ ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រនិង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស,

៣ ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ,ក្រុមជនងាយរងគ្រោះ នៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ចនិងគ្រាមាន គ្រោះអាសន្ន,

៤ ការដាក់ចេញ និងការជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបាន ផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ,

៥ ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង

៦ ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស និងការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ។

រៀបចំអត្ថបទដោយ៖ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.

បច្ច័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
នាពេលកន្លងមក បានក្លាយជាសមិទ្ធផលគួរជាទីមោទនៈ សម្រាប់ប្រជាជន
កម្ពុជា និងជាមរតកគួរជាទីចងចាំនូវគំរូវីរភាពដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមរបស់រាជរដ្ឋាភិបាល
កម្ពុជានៅអាណត្តិទី ៦។ ការផ្លាស់ប្តូរសមាសភាពរដ្ឋាភិបាលថ្មីក្រោមការដឹកនាំដ៏ឈ្លាសវៃ
ប្រកបដោយគតិបណ្ឌិត និងសុភវិនិច្ឆ័យរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**,
អគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) សង្ឃឹម
និងជឿជាក់យ៉ាងមុតមាំថា ប្រទេសកម្ពុជានឹងនៅតែបន្តរក្សាបាននូវស្ថិរភាព និងកំណើនសេដ្ឋកិច្ច
ក្នុងការជំរុញឱ្យកម្ពុជាក្លាយទៅជាប្រទេសដែលរីកចម្រើនគ្រប់វិស័យ និងប្តូរឋានៈទៅជា
ប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ស្របតាមចក្ខុវិស័យ ដែលបានកំណត់៕





# ផ្នែកទី ១

# ព្រឹត្តិការណ៍


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម”



ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា,រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម” ដែលជាដំណាក់កាលចុងក្រោយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ។ ពិធីប្រកាសដាក់ឱ្យអនុវត្តនេះ មានការអញ្ជើញចូលរួមពីសំណាក់ សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរាជរដ្ឋាភិបាល, ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍, ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ន, ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងតំណាងអង្គការមិនមែនរដ្ឋាភិបាល។






# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រកាសដាក់ឱ្យអនុវត្តតាំងពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ កន្លងមក ដោយបានកំណត់ចក្ខុវិស័យ "ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ"។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ, រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកយុទ្ធសាស្ត្រ "បោះជំហានតាមដំណាក់កាល ឬអភិក្រមជាខឿន (Platforms)" ជា ៤ ដំណាក់កាល។

- ដំណាក់កាលទី ១ "ភាពជឿទុកចិត្តបាននៃថវិកា" ចាប់ពីឆ្នាំ២០០៤ ដល់ ២០០៨,
- ដំណាក់កាលទី ២ "គណនេយ្យភាពហិរញ្ញវត្ថុ" ចាប់ពីឆ្នាំ២០០៩ ដល់ ២០១៥,
- ដំណាក់កាលទី ៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ចាប់ពីឆ្នាំ២០១៦ ដល់ ២០២២,
- ដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" ចាប់ពីឆ្នាំ២០២៣ ដល់ ២០២៧។

ដំណាក់កាលទាំង ៤ ត្រូវបានអនុវត្ត ដោយកំណត់សកម្មភាពកែទម្រង់សំខាន់ៗ និងសូចនាករលទ្ធផល ច្បាស់លាស់ នៅក្នុងក្របខ័ណ្ឌផែនការសកម្មភាពរួមនៃដំណាក់កាលនីមួយៗ ដែលហៅថា CAP (Consolidated Action Plan) ដើម្បីជាមូលដ្ឋានគ្រឹះនៅតាមដំណាក់កាលនីមួយៗ មុនឈានចូលទៅដល់ដំណាក់កាលបន្ទាប់។

# គណនេយ្យភាពសមិទ្ធកម្ម

គោលដៅនៃការកសាងគណនេយ្យភាពសមិទ្ធកម្មសំដៅទៅដល់ការកសាងភាពទទួលខុសត្រូវរបស់ស្ថាប័នសាធារណៈនិងមន្ត្រីរាជការក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូលចំពោះលទ្ធផលនៃការអនុវត្តការងារ។“គណនេយ្យភាពសមិទ្ធកម្ម”ដែលត្រូវបានកំណត់នៅក្នុងដំណាក់កាលទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលបំណងរៀបចំ និងដាក់ឱ្យដំណើរការនូវសមាសធាតុនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ ដើម្បីកែលម្អការគ្រប់គ្រង, ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។ ក្នុងន័យនេះ, ក្រសួង ស្ថាប័ននីមួយៗ ដែលទទួលបានការផ្ទេរសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួន នឹងត្រូវមានការទទួលខុសត្រូវខ្ពស់ លើការប្រើប្រាស់ថវិកា ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាពស្របតាមគោលដៅកំណត់ ពោលត្រូវទទួលខុសត្រូវទាំងសមិទ្ធកម្មការងារឱ្យស្របតាមគោលបំណងគោលនយោបាយ បេសកកម្ម សូចនាករលទ្ធផល និងទាំងការប្រើប្រាស់ថវិកាដែលបានអនុម័តជូនជាមួយនឹងការរក្សាបាននូវ “តម្លៃនៃលុយ”។

# សមិទ្ធផលរយៈពេល ៣ ដំណាក់កាល

រាជរដ្ឋាភិបាលបានដាក់ចេញនិងជំរុញការអនុវត្តវិធានការជាច្រើន ដែលនាំឱ្យកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើន ដូចជា៖ ការដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ, ការបង្កើតគណនីទោលរតនាគារ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចំណូល ចំណាយ និងសាច់ប្រាក់, ការធ្វើទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨, ការកែទម្រង់កិច្ចលទ្ធកម្មសាធារណៈ និងការបង្កើតប្រព័ន្ធត្រួតពិនិត្យនិងសវនកម្ម, ការរៀបចំកែលម្អការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុឱ្យបានកាន់តែត្រឹមត្រូវ និងទាន់ពេលវេលាស្របតាមស្តង់ដា, ការដាក់ឱ្យអនុវត្តប្រព័ន្ធធនាគារសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សមន្ត្រីរាជការ, ការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS, និងការរៀបចំយុទ្ធសាស្ត្រគន្លឹះៗ ដើម្បីធានាថាបាននូវទិសដៅការងារដែលច្បាស់លាស់ ប្រកបដោយឆន្ទៈ, មនសិការ និងការទទួលខុសត្រូវខ្ពស់។

# បច្ច័យនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

*“សមិទ្ធកម្មដ៏ល្អនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ”* បានពង្រឹងឱ្យកាន់តែមាំមួនឡើងនូវភាពជាម្ចាស់ និងតួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិ ដោយបានកាត់បន្ថយការពឹងពាក់លើប្រាក់កម្ចីពីក្រៅប្រទេស។

*“សុខភាពដ៏ល្អប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា”* បានធ្វើឱ្យរាជរដ្ឋាភិបាលមានថវិកាសន្សំគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាជាយថាហេតុទាំងឡាយនាគ្រាកន្លងមក ក្នុងការឆ្លើយតបនឹងស្ថានភាពមិនអំណោយផល បង្កឡើងដោយវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល ក៏ដូចជាការឆ្លើយតបនឹងហានិភ័យ និងគ្រោះធម្មជាតិផ្សេងៗ ដែលមិនអាចស្មានទុកជាមុនបាន។

*“អភិបាលកិច្ចល្អ និងការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរឹងមាំ”* ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាល អាចលើកកម្ពស់ជីវភាព និងបម្រើសេវាសាធារណៈជូនប្រជាជនបានកាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍធនធានមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានា។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ គឺជាឃ្នាស់សេដ្ឋកិច្ចដ៏សំខាន់បំផុតមួយ ដែលធ្វើឱ្យកម្ពុជាទទួលបានកំណើន និងបន្តស្ថិរភាពសេដ្ឋកិច្ចក្នុងស្ថានភាពសុទិដ្ឋិនិយមក្នុងការឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

# សារតារ

មុននឹងឈានដល់ ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម”, ផែនការសកម្មភាពរួម (CAP) ដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ “គណនេយ្យភាពសមិទ្ធកម្ម” ដែលជាផែនទីចង្អុលផ្លូវក្នុងការសម្រេចឱ្យបាន នូវដំណាក់កាលទី ៤ ត្រូវបានប្រជុំពិភាក្សាពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ ទាំងកម្រិតផ្ទៃក្នុងអ.គ.ហ.,កម្រិតអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,កម្រិតក្រសួងស្ថាប័ននិងកម្រិតដៃគូអភិវឌ្ឍន៍។







នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅសណ្ឋាគារសុខាភ្នំពេញ, អ.គ.ហ. បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម" លើកចុងក្រោយ ដើម្បីពិនិត្យឡើងវិញនូវផែនការសកម្មភាព និងសូចនាករសមិទ្ធកម្មគន្លឹះដែលបានកំណត់មុននឹងដាក់ឱ្យអនុវត្ត។

លទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់នេះ, អ.គ.ហ. បានកំណត់ទិសដៅច្បាស់លាស់ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី ៤ គឺ "ការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មនិងធានាបាននូវគណនេយ្យភាពសមិទ្ធកម្មដែលជាគ្រឹះក្នុងការកសាងវប្បធម៌សមិទ្ធកម្ម" ដែលឆ្លើយតបទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ និងតថភាពរបស់កម្ពុជា ក៏ដូចជាបញ្ចប់ការរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤។






“ត្រូវបង្កើនភាពជាម្ចាស់” ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន ដោយរដ្ឋមន្ត្រី និងប្រធានស្ថាប័នត្រូវជំរុញអនុវត្តប្រកបដោយភាពជាម្ចាស់នូវកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅតាមគោលការណ៍រួម របស់រាជរដ្ឋាភិបាល។

“ត្រូវផ្តល់ការយកចិត្តទុកដាក់ខ្ពស់” ដល់ការត្រៀមរៀបចំគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យបាននូវការអនុវត្តជាមូលដ្ឋាន នូវថវិកាព័ត៌មានសមិទ្ធកម្ម យ៉ាងយូរនៅឆ្នាំ២០២៦ ខាងមុខ ស្របតាមគោលដៅកំណត់នៃ “យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ” របស់រាជរដ្ឋាភិបាល។

# អនុសាសន៍គន្លឹះរបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី

**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍គន្លឹះនៅក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម”សម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃគ្រប់ក្រសួង ស្ថាប័ន ដែលជាតួអង្គនិម្មាបនករ និងប្រតិបត្តិករនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៨ ចំណុច៖

រៀបចំអត្ថបទដោយ៖ ផ្នែកចំណូលសារពើពន្ធ នៃ អ.គ.ហ.

ត្រូវបន្តប្រកាន់ខ្ជាប់នូវអភិក្រមការងារ “ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និងវះកាត់” ដែលជា អភិក្រមកែទម្រង់របស់មន្ត្រីរាជការ និងថ្នាក់ដឹកនាំនៅតាមក្រសួង ស្ថាប័ន ក្នុងគ្រប់កម្រិត, ទាំងកម្រិតបច្ចេកទេស, កម្រិតគ្រប់គ្រង និងកម្រិតដឹកនាំ, ក្នុងស្មារតីភ្ញាក់រលឹក, កែលម្អ និងបង្កើនប្រសិទ្ធភាពការងារ, ទាំងក្នុងក្របខ័ណ្ឌនៃការបំពេញការងារជាបុគ្គលក៏ដូចជាការបំពេញការងារជាក្រុម។

ត្រូវប្រកាន់យកគោលការណ៍ “គុណភាព, សមត្ថភាព និងគុណាធិបតេយ្យ” ជាវប្បធម៌ការងារ, ពិសេស នៅក្នុងការគ្រប់គ្រងធនធានមនុស្ស។

ត្រូវផ្តល់សារៈសំខាន់លើការពង្រឹង “ភាពជាអ្នកដឹកនាំ” នៅគ្រប់កម្រិត និងជាពិសេស “ក្នុងកម្រិតថ្នាក់ដឹកនាំ” នៅក្នុងស្ថាប័ន និងអង្គភាព ពីព្រោះនេះ គឺជាកត្តាចម្បងដែលកំណត់នូវភាពជោគជ័យនៃការងារ នៅក្នុងគ្រប់អង្គភាព និងក្រសួងស្ថាប័ន, ទាំងសាធារណៈ និងឯកជន។

“ត្រូវផ្តល់ការយកចិត្តទុកដាក់ខ្ពស់” ដល់ការត្រៀមរៀបចំគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យបាននូវការអនុវត្តជាមូលដ្ឋាន នូវថវិកាព័ត៌មានសមិទ្ធកម្ម យ៉ាងយូរនៅឆ្នាំ២០២៦ ខាងមុខ ស្របតាមគោលដៅកំណត់នៃ “យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ” របស់រាជរដ្ឋាភិបាល។

ត្រូវពង្រឹងយន្តការ “តាមដាន, ត្រួតពិនិត្យ និងវាយតម្លៃ” នៅគ្រប់កម្រិត និងឱ្យបានទូលំទូលាយ, ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ជាឧបករណ៍ ដើម្បីកំណត់ចំណុចខ្លាំង, ចំណុចខ្សោយ, បញ្ហាប្រឈម និងកាលានុវត្តភាពនៃរាល់ការអនុវត្តផែនការសកម្មភាពការងារ៕

“ត្រូវបន្តជំរុញឱ្យបានរីកចម្រើននូវវិស័យឌីជីថល” ស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដោយបន្សី និងប្រទាក់ក្រឡាគ្នា ជាមួយនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាជាមួយកម្មវិធីកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

## ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការ

# ចក្ខុវិស័យនិងយុទ្ធសាស្រ្ត ស្ដីពីសុខដុមនីយកម្ម ការកែទម្រង់ ៣ បូក ១

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២
សណ្ឋាគារសូហ្វីតែលភ្នំពេញ



ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនូវ ចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី "សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល" ត្រូវបានសហការរៀបចំដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ.)លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប.) លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (លេខាធិការដ្ឋាន គ.ក.រ.) និងលេខាធិការដ្ឋានអចិន្ត្រៃយ៍






គណៈកម្មាធិការដឹកនាំកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ល.គ.ច.ប្រ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។



# សារតារ



ពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំឡើងបន្ទាប់ពីឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល ត្រូវបានផ្តល់ហត្ថលេខាដ៏ខ្ពង់ខ្ពស់លើបុព្វកថាពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ត្រូវបានអនុម័តជាផ្លូវការ។







គោលដៅនៃការរៀបចំឯកសារនេះគឺជាការកំណត់ទស្សនាទាន និងជាផែនទីបង្ហាញផ្លូវអំពីយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវធ្វើរួមគ្នា ដើម្បីគាំទ្រនិងសហការគ្នាដោយគោរពភាពជាម្ចាស់ នៃកម្មវិធីកែទម្រង់នីមួយៗ សំដៅធ្វើឱ្យកិច្ចដំណើរការ និងការអនុវត្តកម្មវិធីកែទម្រង់ទាំង ៤ ឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពបន្ថែមទៀត។

- រៀបចំអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១
- បញ្ចូលជាផ្លូវការនូវលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ក្នុងការសម្របសម្រួលអន្តរកែទម្រង់ហៅកាត់ “យ.ស.ក.”





នៅក្នុងពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ សម្តេចក្រឡាហោម **ស ខេង** និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានរំលេចពីខ្លឹមសារនិងអនុសាសន៍គន្លឹះៗសម្រាប់ជាគុណប្រយោជន៍ក្នុងការអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ឱ្យមានប្រសិទ្ធភាព៖



# អនុសាសន៍

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**៖ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តចាត់ទុកការកែទម្រង់ជាអាទិភាពគោលនយោបាយរបស់ខ្លួនដែលឆ្លុះបញ្ចាំងតាមរយៈការកំណត់ថា“ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច”ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤។ បន្ថែមពីនេះ នៅក្នុងបរិបទសកលលោកនាពេលបច្ចុប្បន្នការកែទម្រង់ផ្នែកអភិបាលកិច្ចមានសារៈសំខាន់ជាងពេលណាៗទាំងអស់ព្រោះត្រូវពង្រឹងសមត្ថភាពនិងភាពរឹងមាំរបស់ស្ថាប័នសាធារណៈក្នុងការឆ្លើយតបដោយវិធានការបង្ការជាបុរេសកម្មបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពចំពោះវិបត្តិជាច្រើនដែលអាចកើតឡើងដោយមិនអាចស្មានទុកបានដែលកាន់តែពិបាកដោះស្រាយនិងមានលក្ខណៈកាន់តែស្រួចស្រាល់ខ្លាំងឡើង។



១ អភិក្រមរក្សាគំហើញទាំងមូល ដែលសំដៅដល់ប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀតដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងដោយមិនអាចខ្វះបាននៅក្នុងបរិយាការរួមនៃការកែទម្រង់។ ឧទាហរណ៍៖ ការផ្ទេរមុខងារតម្រូវឱ្យពិនិត្យនិងរៀបចំជាវិធាននិងនីតិវិធីជាកញ្ចប់ក្នុងពេលតែមួយ ជាមួយនឹងធនធានហិរញ្ញវត្ថុ ធនធានមនុស្សការពិនិត្យទិដ្ឋភាពក្របខ័ណ្ឌស្ថាប័នច្បាប់និងនីតិវិធីនិងប្រព័ន្ធយុត្តិធម៌។ល។



៤ អភិក្រមបុរេសកម្ម គឺការប្រមើលមើលត្រៀមលក្ខណៈដោះស្រាយបញ្ហា ឬទប់ស្កាត់បញ្ហាមិនឱ្យកើតមានតាមរយៈយន្តការសម្របសម្រួលការកែទម្រង់៣បូក១ដោយមិនរង់ចាំបញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយ។

៣ អភិក្រមរក្សាភាពជាម្ចាស់និងគាំទ្រកិច្ចសហការ គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាពនិងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផងនិងផ្តល់ការគាំទ្រនិងកិច្ចសហការ ប្រកបដោយឆន្ទៈជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀត។

២ អភិក្រមចូលរួមចំណែកតាមតួនាទី សំដៅដល់កម្មវិធីកែទម្រង់នីមួយៗត្រូវបំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទីនិងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**សម្តេចក្រឡាហោម៖** កំណែទម្រង់ទាំង ៤ ដែលជាកំណែទម្រង់ផ្នែកអភិបាលកិច្ចនិងមានចរិតលក្ខណៈកំណែទម្រង់អន្តរវិស័យ ពិតជាមានភាពសាំញ៉ាំនិងស្មុគស្មាញទាំងក្នុងការរៀបចំ និងការអនុវត្ត។ ដូចនេះ ដើម្បីសម្រេចបាននូវគោលបំណងរួមចាំបាច់ត្រូវប្រកាន់យកបុរេលក្ខខណ្ឌមួយចំនួនដូចជា៖



១). *ការបន្តរក្សាឱ្យបានសន្តិភាព ស្ថិរភាពនយោបាយ និងការពង្រឹងបាននូវប្រជាធិបតេយ្យ៖* ព្រោះថាបើគ្មានសន្តិភាព គ្មានស្ថិរភាពនយោបាយ និងគ្មានប្រជាធិបតេយ្យ នោះរាជរដ្ឋាភិបាលពុំអាចរៀបចំនិងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយជោគជ័យបានដែរ។

២). *ឆន្ទៈផ្នែកនយោបាយរបស់រាជរដ្ឋាភិបាល៖* ការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងសាធារណៈជាកិច្ចការសាំញ៉ាំ ស្មុគស្មាញ ដែលនឹងមានផលប៉ះពាល់ទាំងទៅលើផ្នែកបុគ្គល និងផ្នែកស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិព្រមទាំងត្រូវការពេលវេលាពីមធ្យមទៅវែង។ ដូចនេះ ការតាំងចិត្តផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលជារឿងដ៏ចាំបាច់ ដើម្បីប្រសិទ្ធភាពនៃការអនុវត្តការកែទម្រង់។

៣). *ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ៖* កំណែទម្រង់ទាំង ៤ ជាកំណែទម្រង់ពាក់ព័ន្ធទាំងផ្នែករដ្ឋបាលនិងផ្នែកនយោបាយ និងមានផលប៉ះពាល់ទាំងនៅក្នុងស្ថាប័នរដ្ឋនិងស្ថាប័នមិនមែនរដ្ឋ។ ដូចនេះ ជោគជ័យនៃកំណែទម្រង់ គឺអាស្រ័យដោយការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន សហគមន៍មូលដ្ឋាន និងសាធារណជនទូទៅ។

៤). ភាពស៊ីសង្វាក់ ភាពប្រទាក់ក្រឡាគ្នា និងសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់ទាំង ៤ ដែលចាំបាច់ត្រូវបំពេញឱ្យគ្នា និងគាំទ្រគ្នាទៅវិញទៅមក។

រៀបចំអត្ថបទដោយ៖ ផ្នែកការងារកែទម្រង់ទាំងបី គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

# អនុសាសន៍



១

អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំងបួនត្រូវបន្តកិច្ចសហការគ្នាក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពរួមនៃកំណែទម្រង់ទាំងបួនឱ្យកាន់តែមានភាពប្រទាក់ក្រឡានិងស៊ីសង្វាក់គ្នាផ្អែកតាមយុទ្ធសាស្ត្រនិងអតិក្រមដែលបានកំណត់ក្នុងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី“សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១”។



២

អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំងបួនត្រូវរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលការកែទម្រង់៣បូក១នេះឱ្យបានទៀងទាត់តាមពេលវេលាដែលបានកំណត់ ដើម្បីតាមដាន ត្រួតពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាពរួម និងស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលាព្រមទាំងធ្វើសេចក្តីរាយការណ៍ ជូនគណៈកម្មាធិការសាមីនីមួយៗ ជាប្រចាំតាមគោលការណ៍កំណត់។



៣

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធត្រូវរៀបចំឱ្យមានយន្តការរួមមួយនៅក្នុងក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ សម្រាប់ដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការសកម្មភាពរួមប្រចាំឆ្នាំដែលពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់ស្នូលទាំង ៤ ប្រកបដោយប្រសិទ្ធភាព ជាជាងការរៀបចំបង្កើតនូវយន្តការសម្រាប់ដឹកនាំសម្របសម្រួល និងគាំទ្រកម្មវិធីកំណែទម្រង់នីមួយៗ ដាច់ដោយឡែកពីគ្នា។



៤

ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រធនធាន និងមធ្យោបាយដល់កម្មវិធីកំណែទម្រង់នីមួយៗឱ្យបានសមស្របនិងសូមស្នើដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំនិងជាមន្ត្រីនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបន្តផ្តល់ការគាំទ្រ និងចូលរួមក្នុងកិច្ចដំណើរការនៃកំណែទម្រង់ស្នូលទាំង ៤ របស់រាជរដ្ឋាភិបាលឱ្យកាន់តែសកម្មបន្ថែមទៀតដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងរួមនៃកំណែទម្រង់ទាំងនេះ នោះគឺការពង្រឹងគុណភាពអភិបាលកិច្ចដើម្បីបម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជាឱ្យបានកាន់តែប្រសើរឡើង។



៥

អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានទាំងបួនត្រូវបន្តសហការគ្នាក្នុងការផ្សព្វផ្សាយកៀរគរការចូលរួមនិងគាំទ្រពីក្រសួងស្ថាប័នព្រមទាំងស្ថាប័នមិនមែនរដ្ឋាភិបាលរួមមានដៃគូអភិវឌ្ឍន៍អង្គការសង្គមស៊ីវិលវិស័យឯកជនសហគមន៍មូលដ្ឋាននិងសាធារណជនទូទៅ៕

# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ បូក ២

នាថ្ងៃពុធ ៣ កើត ខែផល្គុន ឆ្នាំខាល ចត្វាស័កព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង៩:០០នាទីព្រឹក,នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានការរៀបចំកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។





កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងជាសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, តំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍជាតិតាមបែបប្រជាធិបតេយ្យ, តំណាងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាសាធារណៈ, តំណាងដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិរូបិយវត្ថុអន្តរជាតិ, ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង, ស្ថានទូតស៊ុយអែត និងអង្គការយូនីសេហ្វ) ព្រមទាំងតំណាងអង្គការក្រៅរដ្ឋាភិបាល។



# លទ្ធផលវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២២

១ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានជាសារវ័ន្ត តាមរយៈការកសាង និងកែលម្អប្រព័ន្ធគតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់អនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ក្នុងការកសាង និងបញ្ជ្រាប "វប្បធម៌សមិទ្ធកម្ម" នៅក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល និងទូទាំងមន្ត្រីរាជការ។

២ ស្ថាប័នរាជរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាពតាមរយៈការអនុវត្តថវិកាសមិទ្ធកម្មជាមួយនឹងការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មផ្សារភ្ជាប់នឹងគោលនយោបាយ(NSDP/BSP/PB) ដែលមានបច្ច័យដល់ (១). ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច (២). ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៣). ការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

៣ ក្នុងរយៈពេលប្រមាណ ៣ ឆ្នាំ នៃវិបត្តិជំងឺកូវីដ-១៩ កន្លងទៅ, រាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយ ដើម្បីជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជារក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជន ដែលបាននិងកំពុងបន្តទទួលរងនូវផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩។

៤ រាជរដ្ឋាភិបាលកម្ពុជាក៏បាននិងកំពុងបន្តខិតខំដោះស្រាយបញ្ហាប្រឈមនិងហានិភ័យផ្នែកម៉ាក្រូសេដ្ឋកិច្ចនានា ជាពិសេសផលប៉ះពាល់ពីវិបត្តិនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលនេះបានរុញអត្រាអតិផរណាឱ្យកើនឡើងខ្ពស់ ជាអាទិ៍ ការឡើងថ្លៃប្រេងឥន្ធនៈ ចំណីអាហារ ជីកសិកម្ម និងទំនិញស្ទើរគ្រប់ប្រភេទ ទាំងតាមរយៈគោលនយោបាយសារពើពន្ធ និងគោលនយោបាយគន្លឹះផ្សេងទៀត។



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី វាយតម្លៃខ្ពស់ និងកោតសរសើរដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំពោះកិច្ចខិតខំប្រឹងប្រែងសម្របសម្រួល និងជំរុញការងារកែទម្រង់ ក្នុងគោលដៅរួមគ្នាកសាងភាពរឹងមាំ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា។ ដៃគូអភិវឌ្ឍន៍ចូលរួមសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជាសម្រាប់វឌ្ឍនភាពប្រកបដោយចីរភាពលើគ្រប់ទិដ្ឋភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសវឌ្ឍនភាពនៃការអនុម័តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និងប្តេជ្ញាមុតមាំក្នុងការបន្តគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម” ឆ្នាំ២០២៣-២០២៧៕



រៀបចំអត្ថបទដោយ៖ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ នៃ អ.គ.ហ.



# សិក្ខាសាលាពិគ្រោះយោបល់ស្តីពី “ការចែករំលែកបទពិសោធន៍នៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ”



ក្រោមកិច្ចសហការជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនិងអគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(កសហវ.),សិក្ខាសាលានេះត្រូវបានសម្របសម្រួលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ នៅខេត្តព្រះសីហនុ ដោយមានការអញ្ជើញក្រសួងស្ថាប័នប្រមាណ ៣០០ នាក់។



# គោលបំណងនៃសិក្ខាសាលា៖

១ ពង្រឹងការរៀបចំផែនការថវិកា និងជំរុញការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន។

២ ចែករំលែកបទពិសោធន៍អនុវត្តជាក់ស្តែងរបស់ កសហវ. ជូនក្រសួង ស្ថាប័ន។

៣ បង្កើតឱកាសពិភាក្សា និងពិគ្រោះយោបល់ អំពីបញ្ហាប្រឈមនានា រវាងក្រសួង ស្ថាប័ន។










សិក្ខាសាលាពិគ្រោះយោបល់
ស្តីពី
ការចែករំលែកបទពិសោធន៍នៃការត្រួតពិនិត្យ និងវាយតម្លៃ
ការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ថ្ងៃព្រហស្បតិ៍ ១២រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧









ការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី និងរបបប្រជុំ។

វិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ចំណូល ចំណាយ ថវិកា និងសមិទ្ធកម្ម។

បញ្ហាប្រឈម ឬ ចំណុចខ្វះខាតក្នុងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកាកម្មវិធីនៅក្រសួង ស្ថាប័ន។

យោបល់របស់ក្រសួង ស្ថាប័ន លើការចែករំលែកបទពិសោធន៍ដែលបានដកស្រង់ចេញពីបទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កម្មវត្ថុពិភាក្សា និងពិគ្រោះយោបល់៖

ក្រសួង ស្ថាប័នទាំងអស់ត្រូវបានបែងចែកជា ៨ ក្រុម ដើម្បីពិភាក្សាលើប្រធានបទធំពីរ រួមមាន ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកាកម្មវិធី និងបទពិសោធន៍នៃការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម។ ខ្លឹមសារនៃកិច្ចពិភាក្សា ត្រូវបានកំណត់ និងពិភាក្សាលើចំណុចសំខាន់ៗ ដូចខាងលើ៖




ការរៀបចំជារួម

បទពិសោធន៍នៃការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មរបស់ក្រសួងស្ថាប័នដែលបានរៀបចំសាកល្បងក្នុងឆ្នាំ២០២២។

## ការវាយតម្លៃ និងសំណូមពររបស់សិក្ខាកាមៈ

សិក្ខាសាលានេះមានការគាំទ្រនិងការចាប់អារម្មណ៍ពីក្រសួងស្ថាប័នជាច្រើនហើយសិក្ខាកាមជាច្រើនបានស្នើសុំឱ្យមានការបន្តរៀបចំសិក្ខាសាលាពិគ្រោះយោបល់និងចែករំលែកបែបនេះទៀតទៅលើប្រធានបទនានាទាក់ទងនឹងថវិកា។




ការចែករំលែកបទពិសោធន៍ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




កិច្ចពិភាក្សា និងពិគ្រោះយោបល់រវាងក្រសួង ស្ថាប័ន

# ទិសដៅការងារទៅមុខ៖

១

សិក្ខាសាលាពិគ្រោះ
យោបល់លើប្រធានបទថវិកា
នានា (ដូចជាគោលការណ៍ណែនាំ
ហិរញ្ញវត្ថុសាធារណៈ (FMM) និង
ការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ
(KPI) របស់ក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ)។

រៀបចំអត្ថបទដោយ៖ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.

# ២

បង្កើតក្រុមការងារ
ចែករំលែក និងពិគ្រោះយោបល់
ដែលមានសមាសភាពមកពី
ក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាននិង
អង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ ដើម្បីកំណត់ការងារ
នៅក្នុងផែនការសកម្មភាព
នៅឆ្នាំបន្ទាប់៕



# ពិធីប្រកាសដាក់ឱ្យអនុវត្ត ជាផ្លូវការស្តីពីកិច្ចព្រមព្រៀង ហិរញ្ញប្បទានឥតសំណង រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប សម្រាប់គាំទ្រការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ដំណាក់កាលទី ៤




រវាង


ចុះថ្ងៃទី៨ ខែធ្នូ



នាព្រឹកថ្ងៃពុធ ១១ កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នាទី, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.), ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីដាក់ឱ្យអនុវត្តជាផ្លូវការ ស្តីពីកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុបសម្រាប់គាំទ្រការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ដោយមានការអញ្ជើញចូលរួមពីលោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា និងឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតំណាងស្ថានទូតស៊ុយអ៊ែត។







ការរៀបចំ និងអនុវត្តកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតំណង ឆ្នាំ២០២២-២០២៥ ក្នុងទម្រង់ជាមូលនិធិទ្រទ្រង់ថវិកានេះគឺមានសារៈសំខាន់ជាសារវន្ត រួមមាន៖ (ទី១)-បង្កើនភាពជាម្ចាស់របស់រាជរដ្ឋាភិបាល, (ទី២)-ដៃគូអភិវឌ្ឍន៍មានភាពជឿជាក់លើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា និង (ទី៣)-បង្កើនកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ជាក់ស្តែង, ផ្អែកលើការរៀបចំ និងអនុវត្តក្របខ័ណ្ឌលទ្ធផល ឬសមិទ្ធកម្ម (Results/Performance Framework) កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងនេះស្របតាមទិសដៅ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលគន្លឹះៗ ដូចតទៅ៖









កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងឆ្នាំ២០២២-២០២៥ បានកំណត់នូវលទ្ធផលចុងក្រោយចំនួន ៦ រួមមាន (១) ការកៀរគរចំណូលក្នុងស្រុក, (២) តម្លាភាពថវិកា, (៣) ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, (៤) លទ្ធកម្មសាធារណៈ, (៥) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), (៦) គណនេយ្យភាពថវិកា សវនកម្មផ្ទៃក្រៅ និងសូចនាករគោលដៅចំនួន ២១ ក្នុងឆ្នាំនីមួយៗ (ឆ្នាំទី ១, ឆ្នាំទី ២ និងឆ្នាំទី ៣)។



*“កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) គឺជាកម្មវិធីកែទម្រង់ស្នូលមួយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាសេនាធិការ បានជំនះដោយជោគជ័យក្នុងការកែទម្រង់សមាសធាតុគន្លឹះៗនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា នៅលើផ្លូវត្រូវឆ្ពោះទៅកាន់ការសម្រេចបាននូវចក្ខុវិស័យដែលបានកំណត់។ ជោគជ័យនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានផ្តល់ផលជាបណ្តើរៗទៅលើការពង្រឹងគុណភាព“អភិបាលកិច្ចល្អ” និងការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយដ៏រឹងមាំ ដែលបានធ្វើឱ្យរាជរដ្ឋាភិបាលអាចលើកកម្ពស់ជីវភាពនិងបម្រើសេវាសាធារណៈជូនប្រជាជនបានកាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែមានគុណភាព កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានាដូចជា ប្រព័ន្ធគមនាគមន៍, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការកសាងសាលារៀន, មន្ទីរពេទ្យបានកាន់តែច្រើននិងមានគុណភាពប្រសើរឡើងឥតឈប់ឈរ។”*

ការគូសបញ្ជាក់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។



*“ចាប់តាំងពីឆ្នាំ២០០៥មកសហភាពអឺរ៉ុបបានធ្វើការជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលជាមូលដ្ឋានគ្រឹះសម្រាប់កម្មវិធីកិច្ចសហប្រតិបត្តិការទាំងអស់នៅក្នុងប្រទេសកម្ពុជា។ លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ទាំង ៣ ដំណាក់កាលនាពេលកន្លងមក, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្នមានលក្ខណៈកាន់តែប្រសើរឡើងនិងកាន់តែមានប្រសិទ្ធភាពឡើងក្នុងការចូលរួមសម្រេចបាននូវគោលដៅសេដ្ឋកិច្ចនិងសង្គមកម្ពុជាក្នុងនោះរួមមានការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ក្នុងទស្សនវិស័យប្រកបដោយសុទិដ្ឋិនិយមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, សហភាពអឺរ៉ុបអបអរសាទរ ចំពោះរាជរដ្ឋាភិបាលកម្ពុជា សម្រាប់វឌ្ឍនភាពប្រកបដោយចីរភាពលើគ្រប់ទិដ្ឋភាព ជាពិសេសវឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដៃគូអភិវឌ្ឍន៍ប្ដេជ្ញាយ៉ាងមុតមាំក្នុងការបន្តគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម”។”*

ចំណាប់អារម្មណ៍ និងការកត់សម្គាល់ជារួមរបស់លោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា។

ជាការពិត, សមិទ្ធផលដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងសម្រេចដ៏ច្រើនសន្ធឹកសន្ធាប់មិនអាចកាត់ផ្តាច់ចេញពីការចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ឡើយ។ ពិធីដាក់ឱ្យអនុវត្តជាផ្លូវការកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងឆ្នាំ២០២២-២០២៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុបសម្រាប់គាំទ្រការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ នាឱកាសនេះ គឺជាសក្ខីភាពមួយយ៉ាងច្បាស់ ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីការបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និត រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប៕

រៀបចំអត្ថបទដោយៈ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ នៃ អ.គ.ហ.


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
ច្បាប់
ស្ដីពី
ភាពជាដៃគូ
រវាង
រដ្ឋ និងឯកជន
លើចលនទ្រព្យ



# ផ្នែកទី ២

# អត្ថបទ


MINISTRY OF ECONOMY AND FINANCE
NUS
National University of Singapore
LKY
Lee Kuan Yew
School of Public Policy
បទពិសោធន៍
ជោគជ័យ របស់ប្រទេសសិង្ហបុរី
លើការរៀបចំ គោលនយោបាយ
អនុវត្តថវិកា និងការផ្តល់
សេវាសាធារណៈ


Maybank
CapitaLand
wework
wework
THE FULLERTON HOTEL

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.)បានដឹកនាំសម្របសម្រួលមន្ត្រីកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃ ៤០ ក្រសួង ស្ថាប័នទៅសិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍របស់ប្រទេសសឹង្ហបុរី ក្នុងការរៀបចំគោលនយោបាយ រៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។



១

ការរៀបចំគោលនយោបាយសាធារណៈ៖ការរៀបចំគោលនយោបាយសាធារណៈ គឺផ្តោតលើគោលដៅរយៈពេលវែង (Long-Term Goals) និងត្រូវកំណត់ចេញនូវបញ្ហាចម្បងៗសម្រាប់ដោះស្រាយ និងភាពមិនប្រាកដប្រជានានានៅពេលអនាគត។ ជានីតិវិធីតាក់តែងគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេសសិង្ហបុរី ជាស្ថាប័នយុទ្ធសាស្ត្រដែលមានតួនាទីរៀបចំ និងកំណត់យុទ្ធសាស្ត្រអាទិភាពផង និងជាអ្នកពិនិត្យលើលទ្ធភាពថវិកាក៏ដូចជាគ្រោងថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ។ ក្នុងន័យនេះ គោលនយោបាយរបស់សិង្ហបុរីមានលក្ខណៈផ្សារភ្ជាប់នឹងថវិកា ដោយប្រទេសនេះបានអនុវត្តវិធីសាស្ត្ររៀបចំគោលនយោបាយនិងគ្រោងថវិកាសម្រាប់អនុវត្តដំណាលគ្នា។បន្ទាប់ពីគោលនយោបាយត្រូវបានអនុម័តរួច, ភ្នាក់ងារជំនាញបច្ចេកទេស (Line Agency) ជាអ្នកអនុវត្តគម្រោង និងផលិតនូវលទ្ធផលចុងក្រោយ។

២

វិធីសាស្ត្រអនុវត្តថវិកា៖ សិង្ហបុរីប្រើប្រាស់ថវិកាអាទិភាព (Priority Based Budgeting) ដែលកំណត់ថារាល់សេចក្តីសម្រេចថវិកា និងការវិភាជន៍ធនធាន គឺអាស្រ័យលើតម្រូវការអាទិភាពរបស់សហគមន៍មូលដ្ឋាននិងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ការគ្រោងថវិកាជារួម ផ្តោតលើទំហំចំណាយជាក់ស្តែងសម្រាប់អនុវត្តកម្មវិធីអាទិភាព ដូចជា កម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតង, ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ, ការធ្វើទំនើបកម្មប្រព័ន្ធសេវាសាធារណៈជាដើម ដោយពុំផ្អែកលើពិដានចំណាយឆ្នាំចាស់។ ដោយឡែក ចំពោះកម្មវិធីណាមិនមានអាទិភាព ឬមិនចាំបាច់នឹងត្រូវកាត់ចេញពីកញ្ចប់ថវិកា។





៣

គោលការណ៍អភិបាលកិច្ច និងការផ្តល់សេវាសាធារណៈ៖ គោលការណ៍អភិបាលកិច្ច ផ្តោតសំខាន់លើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការដឹកនាំការងារដោយកំណត់ឱ្យបាននូវតួអង្គ និងភាគីពាក់ព័ន្ធក្នុងកិច្ចដំណើរការការងារ។ តួអង្គសំខាន់ ដែលធានាដល់អភិបាលកិច្ចល្អរួមមាន រដ្ឋាភិបាល (សំដៅដល់ក្រសួង ស្ថាប័នអនុវត្ត), ស្ថាប័នសង្គមស៊ីវិល និងវិស័យឯកជន, ប្រព័ន្ធផ្សព្វផ្សាយ, និងការចូលរួមរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នា ក្នុងទិដ្ឋភាពនៃការផ្តល់សេវាសាធារណៈពុំមែនមានត្រឹមតែរដ្ឋទេដែលមានសិទ្ធអំណាច និងតួនាទីផ្តាច់មុខក្នុងផ្តល់សេវាសាធារណៈ ប៉ុន្តែរដ្ឋអាចធ្វើប្រតិភូកម្មអំណាច ឬអនុញ្ញាតឱ្យវិស័យឯកជនជាអ្នកផ្តល់សេវាសាធារណៈក្នុងវិស័យសំខាន់ៗនានាក្នុងនាមតំណាងឱ្យរដ្ឋាភិបាល។ដើម្បីដឹងពីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក្រសួងហិរញ្ញវត្ថុនៃ ប្រទេសសិង្ហបុរី បានធ្វើរបាយការណ៍ស្តីពី “Measure the Output and Quality of Government” ក្នុងរយៈពេល ២ ឆ្នាំ ម្តង ដើម្បីពង្រឹងការផ្តល់សេវាតាមវិស័យនានា ដូចជាវិស័យអប់រំ សុខាភិបាល បរិស្ថាន ...។ល។

៤

ប្រព័ន្ធឌីជីថលនៃសេវាសាធារណៈ៖សិង្ហបុរីបានអភិវឌ្ឍនូវកម្មវិធីផ្តល់សេវាសាធារណៈតាមទូរស័ព្ទហៅថា “One Service APP” ដែលមានមុខងារទទួល និងដោះស្រាយនូវរាល់បញ្ហាជូនប្រជាពលរដ្ឋ តាមរយៈកម្មវិធីទូរស័ព្ទដៃ។ រាល់បញ្ហាដែលបានជូនដំណឹងនឹងផ្ញើទៅកាន់ភ្នាក់ងារមានសមត្ថកិច្ចដោយស្វ័យប្រវត្តិ។ គិតត្រឹមឆ្នាំ២០២១ មានអ្នកប្រើប្រាស់កម្មវិធី One Service ជាង ៣៥០,០០០ នាក់ ហើយក្នុងមួយករណីត្រូវការរយៈពេលយ៉ាងយូរ ១០ ថ្ងៃ ដើម្បីដោះស្រាយរួចរាល់។

៥

ទស្សនៈ Smart Nation៖ គោលគំនិតនៃពាក្យ Smart ផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហា និងជាការប្រើប្រាស់បច្ចេកវិទ្យាដើម្បីឆ្លើយតបនឹងគោលនយោបាយ។ ពាក្យ Smart Nation សំដៅទៅលើរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថល ដែលក្នុងនោះរដ្ឋាភិបាលឌីជីថល ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធបច្ចេកវិទ្យាថ្នាលបើកចំហាទិន្នន័យ និងថ្នាលផ្សេងៗ សម្រាប់គាំទ្រដល់ការផ្តល់សេវារបស់រដ្ឋ, ការរៀបចំនីតិវិធីការងារ និងការលើកស្ទួយពីការចូលរួមពីប្រជាពលរដ្ឋ។ ជារួម ដើម្បីអនុវត្តគោលនយោបាយប្រកបដោយជោគជ័យ និងប្រកបដោយលទ្ធផល ត្រូវមានស្នូលសំខាន់ៗចំនួន ៤ គឺឆន្ទៈថ្នាក់ដឹកនាំកំពូល, ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា, ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស។



អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានដឹកនាំសម្របសម្រួលមន្ត្រីកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃ ៤០ ក្រសួងស្ថាប័នទៅសិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍របស់ប្រទេសសឹង្ហបុរី ក្នុងការរៀបចំគោលនយោបាយ រៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។



១

ការរៀបចំគោលនយោបាយសាធារណៈ៖ ការរៀបចំគោលនយោបាយសាធារណៈ គឺផ្តោតលើគោលដៅរយៈពេលវែង (Long-Term Goals) និងត្រូវកំណត់ចេញនូវបញ្ហាចម្បងៗសម្រាប់ដោះស្រាយ និងភាពមិនប្រាកដប្រជានានានៅពេលអនាគត។ ជានីតិវិធីតាក់តែងគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេសសិង្ហបុរី ជាស្ថាប័នយុទ្ធសាស្ត្រដែលមានតួនាទីរៀបចំ និងកំណត់យុទ្ធសាស្ត្រអាទិភាពផង និងជាអ្នកពិនិត្យលើលទ្ធភាពថវិកា ក៏ដូចជាគ្រោងថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ។ ក្នុងន័យនេះ គោលនយោបាយរបស់សិង្ហបុរីមានលក្ខណៈផ្សារភ្ជាប់នឹងថវិកា ដោយប្រទេសនេះបានអនុវត្តវិធីសាស្ត្ររៀបចំគោលនយោបាយនិងគ្រោងថវិកាសម្រាប់អនុវត្តដំណាលគ្នា។ បន្ទាប់ពីគោលនយោបាយត្រូវបានអនុម័តរួច, ភ្នាក់ងារជំនាញបច្ចេកទេស (Line Agency) ជាអ្នកអនុវត្តគម្រោង និងផលិតនូវលទ្ធផលចុងក្រោយ។

២

វិធីសាស្ត្រអនុវត្តថវិកា៖ សិង្ហបុរីប្រើប្រាស់ថវិកាអាទិភាព (Priority Based Budgeting) ដែលកំណត់ថារាល់សេចក្តីសម្រេចថវិកា និងការវិភាជន៍ធនធាន គឺអាស្រ័យលើតម្រូវការអាទិភាពរបស់សហគមន៍មូលដ្ឋាននិងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ការគ្រោងថវិកាជារួមផ្តោតលើទំហំចំណាយជាក់ស្តែងសម្រាប់អនុវត្តកម្មវិធីអាទិភាព ដូចជា កម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតង, ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ, ការធ្វើទំនើបកម្មប្រព័ន្ធសេវាសាធារណៈជាដើម ដោយពុំផ្អែកលើពិដានចំណាយឆ្នាំចាស់។ ដោយឡែក ចំពោះកម្មវិធីណាមិនមានអាទិភាព ឬមិនចាំបាច់នឹងត្រូវកាត់ចេញពីកញ្ចប់ថវិកា។





៣

គោលការណ៍អភិបាលកិច្ច និងការផ្តល់សេវាសាធារណៈ៖ គោលការណ៍អភិបាលកិច្ច ផ្តោតសំខាន់លើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការដឹកនាំការងារដោយកំណត់ឱ្យបាននូវតួអង្គ និងភាគីពាក់ព័ន្ធក្នុងកិច្ចដំណើរការការងារ។ តួអង្គសំខាន់ ដែលធានាដល់អភិបាលកិច្ចល្អរួមមាន រដ្ឋាភិបាល (សំដៅដល់ក្រសួង ស្ថាប័នអនុវត្ត), ស្ថាប័នសង្គមស៊ីវិល និងវិស័យឯកជន, ប្រព័ន្ធផ្សព្វផ្សាយ, និងការចូលរួមរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នា ក្នុងទិដ្ឋភាពនៃការផ្តល់សេវាសាធារណៈពុំមែនមានត្រឹមតែរដ្ឋទេដែលមានសិទ្ធអំណាច និងតួនាទីផ្តាច់មុខក្នុងផ្តល់សេវាសាវាធារណៈ ប៉ុន្តែរដ្ឋអាចធ្វើប្រតិភូកម្មអំណាច ឬអនុញ្ញាតឱ្យវិស័យឯកជនជាអ្នកផ្តល់សេវាសាធារណៈក្នុងវិស័យសំខាន់ៗនានាក្នុងនាមតំណាងឱ្យរដ្ឋាភិបាល។ដើម្បីដឹងពីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក្រសួងហិរញ្ញវត្ថុនៃ ប្រទេសសិង្ហបុរី បានធ្វើរបាយការណ៍ស្តីពី “Measure the Output and Quality of Government” ក្នុងរយៈពេល ២ ឆ្នាំ ម្តង ដើម្បីពង្រឹងការផ្តល់សេវាតាមវិស័យនានា ដូចជាវិស័យអប់រំ សុខាភិបាល បរិស្ថាន ...។ល។

៤

ប្រព័ន្ធឌីជីថលនៃសេវាសាធារណៈ៖សិង្ហបុរីបានអភិវឌ្ឍនូវកម្មវិធីផ្តល់សេវាសាធារណៈតាមទូរស័ព្ទហៅថា “One Service APP” ដែលមានមុខងារទទួល និងដោះស្រាយនូវរាល់បញ្ហាជូនប្រជាពលរដ្ឋ តាមរយៈកម្មវិធីទូរស័ព្ទដៃ។ រាល់បញ្ហាដែលបានជូនដំណឹងនឹងផ្ញើទៅកាន់ភ្នាក់ងារមានសមត្ថកិច្ចដោយស្វ័យប្រវត្តិ។ គិតត្រឹមឆ្នាំ២០២១ មានអ្នកប្រើប្រាស់កម្មវិធី One Service ជាង ៣៥០,០០០ នាក់ ហើយក្នុងមួយករណីត្រូវការរយៈពេលយ៉ាងយូរ ១០ ថ្ងៃ ដើម្បីដោះស្រាយរួចរាល់។

៥

ទស្សនៈ Smart Nation៖ គោលគំនិតនៃពាក្យ Smart ផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហា និងជាការប្រើប្រាស់បច្ចេកវិទ្យាដើម្បីឆ្លើយតបនឹងគោលនយោបាយ។ ពាក្យ Smart Nation សំដៅទៅលើរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថល ដែលក្នុងនោះរដ្ឋាភិបាលឌីជីថល ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធបច្ចេកវិទ្យាថ្នាលបើកចំហទិន្នន័យ និងថ្នាលផ្សេងៗ សម្រាប់គាំទ្រដល់ការផ្តល់សេវារបស់រដ្ឋ, ការរៀបចំនីតិវិធីការងារ និងការលើកស្ទួយពីការចូលរួមពីប្រជាពលរដ្ឋ។ ជារួម ដើម្បីអនុវត្តគោលនយោបាយប្រកបដោយជោគជ័យ និងប្រកបដោយលទ្ធផល ត្រូវមានស្នូលសំខាន់ៗចំនួន ៤ គឺឆន្ទៈថ្នាក់ដឹកនាំកំពូល, ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា, ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស។

ក្នុងឆ្នាំ២០១៩អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) និងសាលាគោលនយោបាយលីក្វាន់យូនៃប្រទេសសិង្ហបុរីបានចុះអនុស្សរណៈយោគយល់គ្នាដើម្បីផ្តល់កិច្ចសហការលើការងារកសាង និងអភិវឌ្ឍន៍សមត្ថភាព។ គោលបំណងរបស់ អ.គ.ហ. ក្នុងការផ្តួចផ្តើមរៀបចំកិច្ចសហការជាមួយសាលាលីក្វាន់យូ គឺដើម្បីចូលរួមលើកកម្ពស់ពង្រឹងសមត្ថភាព និងចែករំលែកចំណេះដឹង និងបទពិសោធន៍ពីសាលាដែលមានគុណភាពជូនមន្ត្រីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងស្ថាប័នក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។



ក្រោមកិច្ចសហការជាមួយសាលាគោលនយោបាយលីក្វាន់យូនៃប្រទេសសិង្ហបុរី, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ លើក នៅឆ្នាំ២០២២ និង ២០២៣ ជូនសិក្ខាកាមមកពីគ្រប់ក្រសួង ស្ថាប័នក្នុងការសិក្សាស្វែងយល់ពី បទពិសោធន៍របស់ប្រទេសសិង្ហបុរីលើការរៀបចំគោលនយោបាយអនុវត្តថវិកា និងផ្តល់សេវាសាធារណៈនៅសាលាគោលនយោបាយលីក្វាន់យូ នៃប្រទេសសិង្ហបុរី។










ក្រោមកិច្ចសហការរវាង អ.គ.ហ. និងសាលាគោលនយោបាយលីក្វាន់យូ នៃប្រទេសសិង្ហបុរី, អ.គ.ហ. បានចូលរួមលើកកម្ពស់ និងពង្រឹងសមត្ថភាពមន្ត្រីកែទម្រង់ជាមួយនឹងសមិទ្ធផលដូចខាងក្រោម៖

- សម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៤ លើក
  - ២ លើក ជាការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ
  - ២ លើក ជាការបណ្តុះបណ្តាលផ្ទាល់នៅសាលាគោលនយោបាយលីក្វាន់យូ នៃប្រទេសសិង្ហបុរី។

- ផ្តល់អាហារូបករណ៍ជូនមន្ត្រីរាជការ និងមន្ត្រីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន៖
  - មុខវិជ្ជា MPA រយៈពេល ១ ឆ្នាំ ជូនមន្ត្រីចំនួន ២ នាក់
  - មុខវិជ្ជា MPP រយៈពេល ២ ឆ្នាំ ជូនមន្ត្រីចំនួន ៤ នាក់។

សាលាគោលនយោបាយលីក្វាន់យូនៃសាកលវិទ្យាល័យជាតិសិង្ហបុរី គឺជាស្ថាប័នសិក្សាឈានមុខគេក្នុងវិស័យគោលនយោបាយសាធារណៈនិងអភិបាលកិច្ច។សាលានេះមានទីតាំងនៅប្រទេសសិង្ហបុរីដែលជាប្រទេសមួយត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយសម្រាប់ភាពជោគជ័យក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចអភិបាលកិច្ចល្អនិងគោលនយោបាយសាធារណៈប្រកបដោយប្រសិទ្ធភាព។អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសហការជាមួយនឹងសាលាគោលនយោបាយលីក្វាន់យូតាំងពីឆ្នាំ២០២០ និងបានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ (Master in Public Admiration [MPA]) និងគោលនយោបាយសាធារណៈ (Master in Public Policy [MPP]) ជូនមន្ត្រីរាជការដែលមានសមត្ថភាពជារៀងរាល់ឆ្នាំ។




បណ្ឌិត **វង្ស មេង** ជាអនុប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាដែលបានទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ (Master in Public Administration-MPA) ក្រោមកម្មវិធីអាហារូបករណ៍របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅសិក្សានៅសាលាគោលនយោបាយលីក្វាន់យូនៃសាកលវិទ្យាល័យជាតិសិង្ហបុរី (Lee Kuan Yew School of Public Policy, National University of Singapore) សម្រាប់ឆ្នាំសិក្សា ២០២១ ដល់ ២០២២។





*“មុខវិជ្ជាដែលទទួលបានពីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលសាធារណៈនៃសាលាគោលនយោបាយលីក្វាន់យូ បានបង្កើនចំណេះដឹងខាងសិក្សាគោលនយោបាយសាធារណៈ ដើម្បីអោយនិស្សិតយកទៅអភិវឌ្ឍសង្គមជាតិរបស់ខ្លួន។ ក្នុងរយៈកាលសិក្សាមួយឆ្នាំនេះ ខ្ញុំបានសិក្សាអំពីទ្រឹស្តី ព្រមទាំងការអនុវត្តជាច្រើន រួមមាន គម្រោងសិក្សាអភិបាលកិច្ច វិភាគសេដ្ឋកិច្ច ការគ្រប់គ្រងសាធារណៈ វិភាគគោលនយោបាយការបរទេស ការអភិវឌ្ឍសេដ្ឋកិច្ចនិងមគ្គុទ្ទេសកភាពនយោបាយប្រទេសចិន បញ្ហាទីផ្សារការងារនិងគោលនយោបាយសាធារណៈ វិភាគគោលនយោបាយសាធារណៈ មគ្គុទេសកភាពនៅយុគសម័យបម្រែបម្រួល មគ្គុទ្ទេសកភាពសេវាសាធារណៈ រដ្ឋបាលសាធារណៈ បច្ចេកវិទ្យា និងនវានុវត្តន៍។ ទាំងនេះ សុទ្ធតែបង្ហាញអំពីទ្រឹស្តី និងអនុវត្តជាក់ស្តែង ដែលខ្ញុំអាចយកចំណេះដឹងដ៏មានសក្តានុពលមករួមចំណែកអភិវឌ្ឍចំណេះដឹង និងអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់កម្ពុជាតទៅអនាគត។ ការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ខាងរដ្ឋបាលសាធារណៈ ដែលមានរយៈពេល ១ ឆ្នាំនេះ ពិតជាទទួលបានផល និងផ្លែផ្កាយ៉ាងច្រើន រួមមាន គុណភាពការសិក្សា គុណភាពនៃការបង្រៀន បទពិសោធន៍ជីវិត ការរស់នៅ ទំនាក់ទំនងនិស្សិតនិងនិស្សិត និស្សិតនិងសាស្ត្រាចារ្យ និស្សិតនិងថ្នាក់ដឹកនាំសាលា បរិស្ថានជុំវិញ លើសពីនេះទៀត បរិស្ថានដ៏ស្រស់ស្អាតរបស់សាលាគោលនយោបាយលីក្វាន់យូតែម្តង។ គុណភាពនៃការសិក្សាផ្តោតទៅអំណានជាច្រើនដែលពង្រឹងសមត្ថភាពនិស្សិតគ្រប់មជ្ឈដ្ឋានអោយបានទទួលជោគជ័យក្នុងការសិក្សាយល់ដឹងបានទូលំទូលាយ អំពីទ្រឹស្តីនិងអនុវត្តជាក់ស្តែងនៅក្នុងសង្គម ដើម្បីរៀបចំអភិវឌ្ឍប្រទេសជាពិសេសបទពិសោធន៍ក្នុងការរៀបចំគោលនយោបាយរបស់ប្រទេសសិង្ហបុរីនេះផ្ទាល់តែម្តង។ ប្រទេសសិង្ហបុរី ត្រូវគេអោយឈ្មោះថាជា «បុរីនៅអាស៊ីបែបអឺរ៉ុប» មានន័យថាប្រទេសនេះនៅតំបន់អាស៊ី ប៉ុន្តែសម្រាប់ជនជាតិអឺរ៉ុបក៏អាចមកសិក្សាបាន និង រស់នៅបានដូចនៅអឺរ៉ុបដែរ ។ ប្រសិនបើបេក្ខជនជ្រើសរើសសាលា គឺសាលាគោលនយោបាយលីក្វាន់យូនេះហើយ ជាជម្រើសទី ១ ទាំងគុណភាព ទាំងបរិស្ថាន ព្រមទាំងជាសាលាជាប់លំដាប់លេខ ១ នៅអាស៊ី និងលេខ ៨ លំដាប់ពិភពលោក។”*

“បទពិសោធន៍នៃការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈនៅសាលាគោលនយោបាយលីក្វាន់យូរយៈពេល ២ ឆ្នាំ បានបង្រៀនខ្ញុំនូវជំនាញនិងចំណេះដឹងជាច្រើនក្នុងការវិភាគ និងដោះស្រាយបញ្ហាគោលនយោបាយដ៏ស្មុគស្មាញនានា។កម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈនៅសាលាគោលនយោបាយលីក្វាន់យូ មានភាពតឹងរឹង និងម៉ត់ចត់ប្រកបដោយវិន័យ និងគុណភាពដែលជំរុញឱ្យនិស្សិតត្រូវសិក្សាស្រាវជ្រាវ និងមានការទទួលខុសត្រូវលើការសិក្សារបស់ខ្លួន។ ការសិក្សាមុខវិជ្ជានេះមានភាពទូលំទូលាយ ដោយគ្របដណ្តប់លើប្រធានបទជាច្រើនសម្រាប់ជាធាតុចូលបន្ថែមដូចជាសេដ្ឋកិច្ចវិទ្យាសាស្ត្រនយោបាយស្ថិតិនិងការគ្រប់គ្រងសាធារណៈ។បន្ថែមពីលើការសិក្សានៅក្នុងថ្នាក់រៀនខ្ញុំបាទទទួលបានឱកាសផ្សេងៗពីសាលាក្នុងការចូលរួមសិក្សាជាមួយនឹងការអនុវត្តជាក់ស្តែងដូចជាការចុះកម្មសិក្សា ការរៀបចំគម្រោងស្រាវជ្រាវ និងការបង្កើតគោលនយោបាយជាដើម។ ចំណុចសំខាន់មួយនៃបទពិសោធន៍សិក្សារបស់ខ្ញុំនៅសាលាគោលនយោបាយលីក្វាន់យូ គឺជាឱកាសសិក្សារៀនសូត្រពីសាស្ត្រាចារ្យ, អ្នកអនុវត្តជំនាញល្បីៗលើពិភពលោក ដែលបានធ្វើការនៅក្នុងទីភ្នាក់ងាររដ្ឋាភិបាល អង្គការអន្តរជាតិ និងស្ថាប័នស្រាវជ្រាវផ្សេងៗ ដែលបានចែករំលែកចំណេះដឹង និងជំនាញជាច្រើនដល់និស្សិតនៅក្នុងសាលាជាមួយឆន្ទៈគាំទ្រណែនាំនិងលើកទឹកចិត្ត។ក្រៅពីនេះការបង្កើតឱកាសប្រាស្រ័យទាក់ទងជាមួយក្រុមសិស្សចម្រុះមកពីប្រទេសផ្សេងៗ គ្នាប្រមាណ ៧០ នាក់នៅក្នុងថ្នាក់រៀនរបស់ខ្ញុំ បានបង្កើត ឱកាសសិក្សាមួយពោរពេញទៅដោយការចែករំលែកវប្បធម៌ ទស្សនៈ យោបល់ និងបណ្តាញទំនាក់ទំនងជុំវិញពិភពលោក។ តាមរយៈឱកាសដ៏មានតម្លៃទាំងនេះ ការសិក្សាថ្នាក់ អនុបណ្ឌិតរយៈពេល ២ ឆ្នាំនៅសាលាគោលនយោបាយសាធារណៈលីក្វាន់យូនៃប្រទេសសិង្ហបុរីពិតជាបានផ្តល់នូវគុណតម្លៃ បន្ថែមមួយកម្រិតទៀតក្នុងវិថីការងារ ក៏ដូចជាការអភិវឌ្ឍន៍ខ្លួនខ្ញុំក្នុងភាពជាអ្នកដឹកនាំ និងការចូលរួមសហគមន៍។ជាថ្មីម្តងទៀតខ្ញុំបាទសូមអរគុណចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការហិរញ្ញវត្ថុសាធារណៈ ដែលបានបង្កើតកម្មវិធីអាហារូបករណ៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់មន្ត្រីរាជការដែលមានសមត្ថភាពទទួលបានឱកាសសិក្សាពីសាលាលីក្វាន់យូដែលមានគុណភាព។ខ្ញុំបាទមានមោទនភាពដែលបានក្លាយជាអតីតបេក្ខភាពជ័យលាភីមួយរូបនៃកម្មវិធីអាហារូបករណ៍នេះ។ជាមួយនឹងភាពជោគជ័យនេះខ្ញុំនឹងបន្តកសាងចំណេះ និងជំនាញដើម្បីជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងការចូលរួមចំណែកកសាងប្រទេសជាតិកម្ពុជានាពេលខាងមុខ៕”

រៀបចំអត្ថបទដោយ៖ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.

លោក **លាភ សូយទ្រី** គឺជាមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈ Master in Public Policy (MPP) នៅសាលាលីក្វាន់យូ ក្នុងឆ្នាំសិក្សា ២០២១ ដល់ ២០២៣ ក្រោមកម្មវិធីអាហារូបករណ៍កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងនាមជាអតីតនិស្សិតនៅសាលាគោលនយោបាយលីក្វាន់យូលោកបានក្លាយជាផ្នែកមួយនៃក្រុមអ្នកសិក្សាស្រាវជ្រាវចម្រុះ ដែលមានឆន្ទៈបង្កើតនូវនវានុវត្តន៍ នៃវិស័យជំនាញរបស់ខ្លួន។



# ការវាយតម្លៃប្រសិទ្ធភាពប្រព័ន្ធ និងការគ្រប់គ្រងថវិកានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ



ការវាយតម្លៃប្រសិទ្ធភាពប្រព័ន្ធនិងការគ្រប់គ្រងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានធ្វើឡើងដោយប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យចំណាយសាធារណៈ (Public Expenditure Review - PER) និងឧបករណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability - PEFA) ដោយមានការអនុញ្ញាតិពីគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.)។ របាយការណ៍វាយតម្លៃប្រព័ន្ធ និងការគ្រប់គ្រងថវិកាផ្តោតលើវិស័យនិងប្រធានបទសំខាន់ៗរួមមាន (១) ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) វិស័យកសិកម្ម, (៣) វិស័យធារាសាស្រ្តនិងការគ្រប់គ្រងធនធានទឹក, (៤) វិស័យសុខាភិបាល និង (៥) រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តព្រះសីហនុ។

# ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជាជារួមមានភាពរីកចម្រើនរឹងមាំ និងបរិយាបន្នគួរឱ្យកត់សម្គាល់ ដែលបានឆ្លុះបញ្ចាំងពីនិរន្តរភាពចំពោះអត្រាកំណើនសេដ្ឋកិច្ចពិតប្រចាំឆ្នាំជាមធ្យម ៧,៦% ពីឆ្នាំឆ្នាំ១៩៩៥ ដល់ ២០១៩។ ទាំងនេះបានជំរុញឱ្យកម្ពុជាក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក។ជាទំនោរសកល,កំណើនសេដ្ឋកិច្ចពិភពលោកព្រមទាំងកម្ពុជាបានថយចុះនៅដើមឆ្នាំ២០២០ ដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ដែលបានគម្រាមកំហែងដល់ការអភិវឌ្ឍន៍កម្ពុជា និងបានកាត់បន្ថយទំហំលំហរសារពើពន្ធ។ប្រាក់ចំណូលសរុបរបស់រដ្ឋាភិបាលរួមទាំងហិរញ្ញប្បទានឥតសំណងដែលបានកើនឡើងដល់២៧%នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ក្នុងឆ្នាំ២០១៩ និងបានធ្លាក់ចុះមកវិញត្រឹម ២៤,១% នៃ ផ.ស.ស. ក្នុងឆ្នាំ២០២០ ដោយសារការប្រមូលចំណូលទាំងសារពើពន្ធ និងមិនមែនសារពើពន្ធបានធ្លាក់ចុះ។ គោលនយោបាយវិត្ថារកម្មហិរញ្ញវត្ថុសាធារណៈ (Expansionary fiscal policy) និងគោលនយោបាយបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុ (Loose monetary policy) ត្រូវបានប្រើប្រាស់ដើម្បីទប់ទល់ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩។ នៅផ្នែកសារពើពន្ធ ការចំណាយរបស់រដ្ឋាភិបាលឈានដល់ប្រមាណ ២៦,៩% នៃ ផ.ស.ស. ក្នុងឆ្នាំ២០២០ ធៀបនឹង ២៥,៥% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៩ ដែលជំរុញភាគច្រើនដោយអន្តរាគមន៍របស់រដ្ឋាភិបាលដែលរួមបញ្ចូលការចំណាយកម្មវិធីសង្គម (ឧបត្ថម្ភធន និងការផ្ទេរ) ក៏ដូចជាការចំណាយមូលធនផងដែរ។ ខាងគោលនយោបាយរូបិយវត្ថុ ធនាគារជាតិ បានកាត់បន្ថយអនុបាតតម្រូវការឥណទានបម្រុង និងបានដាក់ចេញជាវិធានការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ។ អនុបាតនេះត្រូវបានកាត់បន្ថយមកត្រឹម ៧% សម្រាប់ទាំងប្រាក់បញ្ញើរូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេស, សម្រាប់រូបិយប័ណ្ណក្នុងស្រុកធ្លាក់ចុះពី ៨% និង ១២,៥% សម្រាប់ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសសម្រាប់រយៈពេលប្រាំមួយខែដែលចាប់ផ្តើមនៅក្នុងខែមេសា ឆ្នាំ ២០២០។ លើសពីនេះ, ធនាគារជាតិ បានចេញសេចក្តីណែនាំមួយដល់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុទាំងអស់រៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ខណៈពេលដែលការបន្ធូរបន្ថយបន្ទុករបស់កូនបំណុលដែលប្រឈមនឹងការធ្លាក់ចុះនៃប្រាក់ចំណូលជំដែលបណ្តាលមកពីជំងឺកូវីដ-១៩នេះ។ដោយវិធានការរៀបចំរចនាសម្ព័ន្ធបំណុលដែលរងឥទ្ធិពលដោយជំងឺកូវីដ-១៩ ត្រូវបានដាក់ឱ្យអនុវត្តនៅខែមេសា ឆ្នាំ២០២០ ហើយបញ្ចប់នៅខែមិថុនា ឆ្នាំ ២០២២ ដោយសារសេដ្ឋកិច្ចបានចាប់ផ្តើមមានភាពប្រសើរឡើង។ កម្ពុជាមានលទ្ធភាពជំរុញការប្រមូលចំណូលក្នុងស្រុកបានដែលគួរជាទីមោទនភាពចំពោះការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពជោគជ័យ។ បន្ទាប់ពីជួបប្រទះឱនភាពថវិកាជាច្រើនឆ្នាំ កម្ពុជាសម្រេចបានអតិរេកសារពើពន្ធក្នុងឆ្នាំ២០១៨ និង ២០១៩ (ប្រហែល ០,៤% និង ១,៥% នៃ ផ.ស.ស.) ។ ប្រាក់បញ្ញើរបស់រដ្ឋាភិបាល ឬទុនបំរុងថវិកាសរុបដែលបានឡើងដល់កម្រិតកំពូលក្នុងឆ្នាំ២០២០ ស្មើ ២៣,៧% នៃ ផ.ស.ស. ។ ការផ្ទុះឡើងជំងឺកូវីដ-១៩ បានប៉ះពាល់ ការនៃប្រមូលចំណូល ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះចំណូលសារពើពន្ធ ពី ១៨% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៩ មកត្រឹម ១៦% នៃ ផ.ស.ស. ក្នុងឆ្នាំ២០២១។ នៅឆ្នាំ២០២១ កម្ពុជាបានដាក់ឱ្យប្រើប្រាស់ច្បាប់ថ្មីស្តីពីការវិនិយោគដែលមានលក្ខណៈទូលំទូលាយជាងច្បាប់មុន។កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីបង្កើតលំហរហិរញ្ញវត្ថុសាធារណៈ ខណៈដែលផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩ បានធូរស្រាល ក្នុងកំឡុងពេលសេដ្ឋកិច្ចបានចាប់ផ្តើមងើបឡើងវិញ។យុទ្ធសាស្ត្រកៀរគរចំណូលថ្មី(២០២៤-២០២៨)ត្រូវបាននិងកំពុងរៀបចំនៅក្រោមសកម្មភាពកែទម្រង់ប្រព័ន្ធសារពើពន្ធ,ឧបករណ៍វិភាគរដ្ឋបាលពន្ធដារនិងរដ្ឋបាលគយ (DIAMOND និង TADAT) ត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ ខណៈពេលពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល, ការកែទម្រង់ពន្ធអាករ និងបន្ទុកសារពើពន្ធត្រូវបាននិងកំពុងពិភាក្សា។ផ្អែកតាមការវាយតម្លៃរបកគំហើញបានផ្តល់អនុសាសន៍មួយចំនួន ជាអាទិ៍ (១) ចំណាយមូលធននិងបៀវត្សត្រូវបានបង្កើនខ្លាំង ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពចំណាយ, (២) កែលម្អគណនេយ្យភាព និងសមត្ថភាព ដើម្បីសម្រេចបានលទ្ធផលចុងក្រោយ តាមវិស័យ។ ការណ៍នេះ គាំទ្រដល់ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៣) គិតគូរអំពីបន្ទុកសារពើពន្ធ, និងពង្រីកមូលដ្ឋានពន្ធ (ពន្ធលើរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន, ពន្ធកាបូន និងពន្ធលើសេវាឌីជីថល), និង (៤) គិតគូរទទួលយកគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ផ្អែកតាមគោលការណ៍អាកាសធាតុដែលជាផ្នែកនៃការលើកកម្ពស់ភាពធន់ និងលើកទឹកចិត្តគម្រោងវិនិយោគឯកជន ប្រកបដោយចីរភាព។

# វិស័យកសិកម្ម

អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះស្មើពាក់កណ្តាលចន្លោះពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៩ ដែលមានប្រជាជនកម្ពុជាជិត ២ លាននាក់ បានរួចផុតពីភាពក្រីក្រតាមរយៈការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាដែលកម្មករបានផ្លាស់ប្តូរពីវិស័យកសិកម្មទៅប្រកបការងារផ្សេងទៀត ដែលមានតម្លៃបន្ថែមខ្ពស់ជាង។ ការពង្រីកផលិតកម្មមិនមែនកសិកម្ម និងសេវាកម្ម បាននាំឱ្យមានការថយចុះជាលំដាប់នៃការរួមចំណែកវិស័យកសិកម្មនៅក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ពី ៣៦% ក្នុងឆ្នាំ២០០០ មកនៅប្រហែល ២២% នៃ ផ.ស.ស. នាពេលបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយ វិស័យកសិកម្មនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមរបស់កម្ពុជា ហើយជាប្រភពការងារ និងប្រាក់ចំណូលដ៏សំខាន់ជាពិសេសសម្រាប់នៅតំបន់ជនបទក្រីក្រដែល ៣៥% នៃកម្លាំងពលកម្មសរុបគឺស្ថិតក្នុងវិស័យកសិកម្ម។ ខណៈពេលដែលកម្ពុជាអាចបង្កើនផលិតភាពកសិកម្មដូចបណ្តាប្រទេសជិតខាងក្នុងតំបន់ វិស័យនេះប្រឈមមុខនឹងការប្រកួតប្រជែងក្នុងទីផ្សារនាំចេញដែលនៅសេសសល់។ តម្លៃកសិផលនៅប្រទេសកម្ពុជានៅបន្តមានការប្រកួតប្រជែង ទោះយ៉ាងណាក៏ដោយ ថ្លៃអគ្គិសនីសម្រាប់សហគ្រាសកែច្នៃកសិផល (Agro-Processing), ថ្លៃឡូជីស្ទីក (Logistic Costs) និងថ្លៃនាំចេញ (Shipping Costs) ផលិតផលកសិកម្មគឺមិនមានការប្រកួតប្រជែងនោះទេ។លើសពីនេះវិស័យនេះប្រឈមនឹងហានិភ័យចំពោះកំណើននិងបញ្ហាប្រឈមដាច់ដោយឡែកដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងកង្វះកម្លាំងពលកម្ម ដោយសារទាំងកត្តាតម្រូវការ និងការផ្គត់ផ្គង់។ ការអនុវត្តគោលនយោបាយកសិកម្ម និងគុណភាពចំណាយសាធារណៈក្នុងវិស័យនេះ គឺមានសារៈសំខាន់ក្នុងការជំរុញកំណើនផលិតភាពកសិកម្មបន្ថែមទៀត និងការលើកកម្ពស់សេដ្ឋកិច្ចជនបទឱ្យរស់រវើក។ការដំណោះស្រាយបញ្ហាប្រឈមក្នុងវិស័យកសិកម្មនឹងទាមទារឱ្យមានការពង្រឹងការសម្របសម្រួលរវាងក្រសួងស្ថាប័ន ក្នុងវិស័យកសិកម្ម និងដៃគូអភិវឌ្ឍន៍។ វិស័យកសិកម្មពឹងផ្អែកលើការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលមានប្រហែល ៤៣% នៃការចំណាយលើវិស័យសាធារណៈក្នុងឆ្នាំ២០២០។ដើម្បីធានាឱ្យបាននូវការតម្រឹមស្អិតរមួតជាមួយនឹងគោលដៅរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យនេះ ការចូលរួមប្រកបដោយបុរេសកម្មជាងមុនជាមួយដៃគូអភិវឌ្ឍន៍ ទាំងក្នុងដំណាក់កាលជ្រើសរើសគម្រោង ការរៀបចំគម្រោង និងការអនុវត្តគម្រោងគឺជាការចាំបាច់ ខណៈដែលបន្តពឹងផ្អែកខ្ពស់លើម្ចាស់ជំនួយ ដើម្បីគាំទ្រការវិនិយោគលើវិស័យកសិកម្ម។

ថវិកាក្រសួងកសិកម្ម (លានដុល្លាអាមេរិក)




ថវិកាក្រសួងកសិកម្ម (ភាគរយសរុប)




ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា (BSP) និងការសាកល្បងនៃគម្រោងថវិកាកម្មវិធី (PB) គឺជាជំហានយុទ្ធសាស្ត្រដ៏សំខាន់ ស្ថិតក្នុងដំណាក់កាលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល និងការខិតខំប្រឹងប្រែងដើម្បីកែលម្អគុណភាពនៃការចំណាយសាធារណៈ។ បទពិសោធន៍របស់ក្រសួងកសិកម្ម លើការងារកែទម្រង់បង្ហាញថា ជំហានទាំងនេះបានជួយពង្រឹងសមាសធាតុនៃដំណើរការរៀបចំផែនការ ប៉ុន្តែនៅមិនទាន់មានបច្ច័យ ដល់ប្រព័ន្ធគ្រប់គ្រងថវិកា និងការរៀបចំថវិកានៅឡើយ។ លំដាប់លំដោយនៃការកែទម្រង់ PB និង BSP គឺជាគន្លឹះនៃការអនុវត្តប្រកបដោយជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលឆ្ពោះទៅរកការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម (PIB)។ នេះរួមបញ្ចូលទាំង (i) ការពង្រឹងខ្លឹមសារ BSP; (ii) ការតម្រឹមឯកសារ និងដំណើរការរៀបចំ BSP ជាមួយនឹង PB និងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និង (iii) សមាហរណកម្ម BSP និងតក្កកម្មវិធីទៅក្នុងដំណើរការចរចា, ការគ្រប់គ្រងថវិកា, ការត្រួតពិនិត្យ និងការវាយតម្លៃ និងក្របខ័ណ្ឌច្បាប់។ របកគំហើញនៃការវាយតម្លៃ បានផ្តល់អនុសាសន៍មួយចំនួនជាអាទិ៍ ពង្រឹងការផ្សារភ្ជាប់ថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា,ពង្រឹងការចូលរួមរៀបចំផែនការថវិកាមូលធនពីក្រសួងស្ថាប័នដោយធ្វើការសម្របសម្រួលជាមួយវិស័យពាក់ព័ន្ធ,ពង្រឹងការរៀបចំម៉ាទ្រីសសមិទ្ធកម្ម, ដាក់បញ្ចូលព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ នៅក្នុងសំណើថវិកាប្រចាំឆ្នាំ, សម្រួលដំណើរការអនុវត្តថវិកា និងនីតិវិធីនិយ័តថវិកា និងពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្ម។

# វិស័យធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក

ការចំណាយរបស់ក្រសួងធនធានទឹកនិងឧតុនិយមគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើការផ្តល់មូលនិធិវិនិយោគខាងក្រៅ។នៅក្នុងក្រសួងធនធានទឹកនិងឧតុនិយមមានការបែងចែកកម្មវិធីជា ៥ ដែលក្នុងនោះពាក់ព័ន្ធនឹងកសិកម្មទទួលបានចំណែកធំបំផុត (ជាង ៩០%)។ ចំពោះចំណាត់ថ្នាក់សេដ្ឋកិច្ច(ចំណាត់ថ្នាក់ថវិកា)មួយចំនួនធំស្ថិតក្រោមជំពូកទី២១(ថវិកាមូលធន)ជំពូកទី៦១(ជួសជុល និងថែទាំ)និងជំពូកទី៦៤(បុគ្គលិក)។ ចំណាយចរន្តនៅថ្នាក់កណ្តាលក៏គួរឱ្យកត់សម្គាល់ផងដែរដែលលើសពី៥០%គឺចំណាយលើប្រាក់បៀវត្សនិង៨០%ចំណាយលើចំណាយចរន្តមិនមែនប្រាក់បៀវត្ស។ ក្រសួងធនធានទឹកនិងឧតុនិយម ជាស្ថាប័នដែលមានកម្រិតនៅក្នុងការផ្ទេរមុខងារ និងធនធានទៅថ្នាក់ក្រោមជាតិ ដែលការផ្ទេរមុខងារនិងធនធានមានសារៈសំខាន់ក្នុងការផ្តល់ដល់សេវាផ្គត់ផ្គង់ធនធានទឹកជូនផលិតកម្មកសិកម្ម។ទំហំនៃតម្រូវការនិងទីផ្សារនៃវិស័យធារាសាស្ត្រ(និងកសិកម្ម)បង្ហាញឱ្យឃើញពីតម្រូវការការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការរួមចំណែករបស់វិស័យឯកជននិងការគិតឡើងវិញអំពីតួនាទីរបស់គណៈកម្មការកសិករប្រើប្រាស់ទឹក (FWUCs)។ ចំណុចដែលគួរឱ្យកត់ស្គាល់មួយផ្សេងទៀត ការសម្របសម្រួល ការរៀបចំ និងការអនុវត្តផែនការ ដែលតម្រឹមជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិស័យផ្សេងទៀត នៅមានកម្រិតដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការវិភាជ និងអនុវត្តថវិកាក្នុងវិស័យដែលមានភាពប្រទាក់ក្រឡាគ្នា។

របកគំហើញពីការវាយតម្លៃបានផ្តល់អនុសាសន៍មួយចំនួន ក្នុងនោះរួមមាន៖ ខាងផ្នែកវិភាជថវិកា, ការវិភាជថវិកាត្រូវអនុវត្តតាមអាទិភាពគោលនយោបាយ ដែលផ្សារភ្ជាប់ទៅនឹងកសិកម្ម, ការគ្រប់គ្រងទឹក និងបម្រែបម្រួលអាកាសធាតុ, លើកកម្ពស់សហប្រតិបត្តិការ (Synergy) រវាងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ, ពង្រឹងការវិភាជថវិការវាងថ្នាក់កណ្តាលមន្ទីរនិងរដ្ឋបាលថ្នាក់ក្រោមជាតិនិងដោះស្រាយបញ្ហាពង្រាយបុគ្គលិករវាងថ្នាក់កណ្តាល និងមន្ទីរ។ រីឯខាងផ្នែកប្រតិបត្តិការថវិកា, គួរមានការកែលម្អការវាយតម្លៃនិងជ្រើសរើសគម្រោង និងបង្កើនការប្រកួតប្រជែងកិច្ចលទ្ធកម្ម, គួរមានគោលការណ៍ណែនាំបច្ចេកទេសអំពីការស្តារប្រព័ន្ធធារាសាស្ត្រ(ផ្សារភ្ជាប់ទៅនឹងប្រែប្រួលអាកាសធាតុ), ព្យាករណ៍ការជួសជុលការខូចខាតដែលជួយកាត់បន្ថយការងារចំពោះកិច្ច, គិតគូរផ្ទេរថវិកាប្រតិបត្តិការនិងថែទាំ (O&M) ទៅមន្ទីរ (ហោចណាស់ ៣០%),រៀបចំគោលការណ៍ណែនាំច្បាស់លាស់អំពីរបៀបដែលគម្រោង O&M ត្រូវបានជ្រើសរើសម្រាប់ផ្តល់ហិរញ្ញប្បទាន, រៀបចំគោលការណ៍ណែនាំបច្ចេកទេសលើការងារ O&M, និងអនុវត្តមុខងារដែលបានផ្ទេរសម្រាប់គាំទ្រសហគមន៍អ្នកប្រើប្រាស់ទឹក។ បន្ថែមពីនេះ ខាងផ្នែកតួអង្គអនុវត្ត, ក្រសួងធនធានទឹកនិងឧតុនិយម គួរផ្តោតលើការរៀបចំគោលការណ៍ណែនាំបច្ចេកទេសនិងប្រព័ន្ធ M&E និងផ្តោតតិចតួចលើការអនុវត្តជាក់ស្តែងខណៈមន្ទីរធនធានទឹកនិងឧតុនិយមផ្តោតលើការអនុវត្តជាក់ស្តែង។

ចំណាត់ថ្នាក់នៃការចំណាយថវិកាជាតិប្រចាំឆ្នាំ






# វិស័យសុខាភិបាល

## *ការចំណាយ និងហិរញ្ញប្បទានរបស់ក្រសួងសុខាភិបាល សម្រាប់ការឆ្លើយតបនឹងជំងឺកូវីដ-១៩*

ចំណាយមូលធនពឹងផ្អែកលើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។ ការកើនឡើងនៃថ្លៃចំណាយបច្ចុប្បន្ន (Nominal Spending) នៃក្រសួងសុខាភិបាល ជំរុញខ្លាំងលើបន្ទុកបុគ្គលិក (ជំពូក ៦៤) និងអត្ថប្រយោជន៍សង្គម (ជំពូក ៦២)។ ចំណាយអត្ថប្រយោជន៍សង្គម (ជំពូក ៦២) មានដូចជា ការចំណាយលើអ្នកជំងឺ និងការធ្វើដំណើរនៅមណ្ឌលសុខភាព ការទិញថ្នាំ និងការផ្គត់ផ្គង់ផ្សេងៗ សម្រាប់ផ្នែកវេជ្ជសាស្ត្រ។ ចំពោះការកើនឡើងថវិការបស់ក្រសួងសុខាភិបាល ភាគច្រើនមកពីចំណាយផ្នែកមិនមែនបន្ទុកបុគ្គលិក ដែលនៅឆ្នាំ២០២២ ថវិកាសម្រាប់បន្ទុកបុគ្គលិក មានទំហំស្មើនឹងមួយភាគបី (ឬ ២៩%) ប៉ុណ្ណោះនៃថវិកាសរុប។

*ការចំណាយរបស់ក្រសួងសុខាភិបាល (ថ្លៃបច្ចុប្បន្ន) តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ឯកតា៖ លានរៀល)*








*បន្ទុកបុគ្គលិករបស់ក្រសួងសុខាភិបាល (២០១៧-២០២១) និងចាប់ផ្តើមបៀវត្សរ៍សម្រាប់វេជ្ជបណ្ឌិត (រៀល/ឆ្នាំ)*




ការអនុវត្តតាមចំណាត់ថ្នាក់កម្មវិធី, ក្រសួងសុខាភិបាលបានដាក់ចេញកម្មវិធីចំនួន ៤ ក្នុងនោះរួមមាន (ទី១) សុខភាពបន្តពូជ, យុវជន, មាតា, ទារក, កុមារ និងអាហារូបត្ថម្ភ (ទី២) ការគ្រប់គ្រងជំងឺឆ្លង (ទី៣) ការគ្រប់គ្រងជំងឺដែលមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត (ទី៤) ពង្រឹងប្រព័ន្ធសុខាភិបាល ដែលមានទំហំថវិកាធំជាងគេនៃថវិកាចរន្ត។ ចំណែកឯ ថវិកាសម្រាប់ថ្នាក់ក្រោមជាតិមានត្រឹមមួយភាគបីនៃថវិការបស់ក្រសួងប៉ុណ្ណោះ។

*ថវិកាផ្អែកលើកម្មវិធី ឆ្នាំ២០១៧-២០២២*




*ថវិកាផ្អែកលើកម្មវិធី (% នៃចំណាយចរន្តសរុប)*




ផ្អែកតាមការវាយតម្លៃបឋម, របកគំហើញបានផ្តល់អនុសាសន៍មួយចំនួនជាអាទិ៍ កែលម្អការធ្វើសមាហរណកម្មទិន្នន័យចំណាយថ្នាក់ខេត្ត, ពង្រឹងការធ្វើសមាហរណកម្មចំណាយមូលធនហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, ពង្រឹងសង្គតិភាពសូចនាករនីមួយៗក្នុងផែនការយុទ្ធសាស្ត្រថវិកា, ពិនិត្យសូចនាករសមិទ្ធកម្ម, ដាក់ឱ្យអនុវត្តជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្មនៅក្នុងសំណើថវិកា, តម្រឹមរចនាសម្ព័ន្ធថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា, និងវិភាជចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ។

# រដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានីភ្នំពេញ (PEFA)

លទ្ធផលនៃការវាយតម្លៃPEFAរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលរាជធានីភ្នំពេញបានឆ្លុះបញ្ចាំងពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនិងត្រូវការពេលវេលាបន្ថែមទៀតក្នុងការកែលម្អ ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងដើម្បីឱ្យរដ្ឋបាលរាជធានីភ្នំពេញរៀបចំផែនការប្រមូលនិងប្រើប្រាស់ធនធានស្របតាមចំណាយថវិការយៈពេលមធ្យមក៏ដូចជាផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ។ លទ្ធផលនៃការវាយតម្លៃបង្ហាញថា សូចនាករចំនួន ៤ ក្នុងចំណោម ៣៤ ទទួលពិន្ទុ “A” ឬ “B” ដែលស្របទៅនឹងការអនុវត្តល្អ (Good Practice) ជាអន្តរជាតិ, សូចនាករចំនួន ៦ ទទួលបានពិន្ទុ “C” ឬ “C+” ដែលស្ថិតក្នុងកម្រិតមូលដ្ឋាន ហើយសូចនាករចំនួន ១៨ ទទួលបានពិន្ទុ “D” ឬ “D+” ដែលបង្ហាញពីការអនុវត្តខ្សោយ។ ដោយឡែក សូចនាករចំនួន ៣ គឺ “NA-Not Applicable” មានន័យថាពុំមានមុខងារនៅរដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមានសូចនាករ PI-13, PI-19 និង PI-31 និងសូចនាករចំនួន ៣ គឺ “NU-Not Use” មានន័យថាពុំត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមាន សូចនាករ PI-15, PI-16 និង PI-30។ លទ្ធផលនេះក៏ជាមូលដ្ឋានសម្រាប់ការវាយតម្លៃបន្ទាប់ក៏ដូចជាការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍នេះគឺរដ្ឋបាលរាជធានីភ្នំពេញពឹងផ្អែកលើចំណូលប្រភពផ្ទាល់ខ្លួន និងការបែងចែករំលែកចំណូលពន្ធ និងការរៀបចំថវិកាប្រចាំឆ្នាំស្របតាមប្រតិទិនផ្ញើជូន កសហវ. ទាន់ពេលវេលា និងភ្ជាប់ជាមួយជាតុសំខាន់ៗភាគច្រើន។ ជារួម លទ្ធផលវាយតម្លៃ PEFA សម្រាប់រដ្ឋបាលរាជធានីភ្នំពេញបង្ហាញថា ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ននៅមានកម្រិតនៅឡើយ ដែលសមត្ថភាពសម្រាប់ការអនុវត្តក្របខ័ណ្ឌគតិយុត្តនៅមានកម្រិត តែការត្រួតពិនិត្យសមិទ្ធកម្មត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់។ ចំណុចខ្វះខាតទាំងនេះត្រូវបានផ្សារភ្ជាប់ទៅនឹងភាពជឿទុកចិត្តនៃថវិកា ដែលនៅមានកម្រិតទាបផងដែរនិងជាឧបករណ៍មួយដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយកម្រិតខ្ពស់។

*សង្ខេបពិន្ទុនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរដ្ឋបាលរាជធានីភ្នំពេញ*




PEFA

A collaborative approach to a sustainable PFM system



# រដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្តព្រះសីហនុ (PEFA)

របាយការណ៍វាយតម្លៃសាធារណៈបានផ្តោតលើរដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីកម្រិត ប៉ុន្តែផ្តោតលើរដ្ឋបាលខេត្តច្រើនជាង។ រដ្ឋបាលខេត្តព្រះសីហនុមានទំហំថវិកាដែលស្មើនឹង ៤៥% នៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់មន្ទីរជំនាញនៅជុំវិញ ខេត្ត។ រដ្ឋបាលខេត្តព្រះសីហនុក៏មានចំណូលពីប្រភពផ្ទាល់ខ្លួនច្រើនជាងគេផងដែរ បើប្រៀបធៀបទៅនឹងថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។ ចំណូលទាំងអស់ភាគច្រើន (ដែលច្រើនជាង ៨០%) បានមកពីចំណូលសារពើពន្ធ។ ការរៀបចំថវិការបស់រដ្ឋបាលខេត្តព្រះសីហនុបង្ហាញវឌ្ឍនភាព ជាពិសេសបន្ទាប់ពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០២០។ ទោះជាយ៉ាងណា ប្រសិទ្ធភាពនៃការវិភាជ អាចពង្រឹងបន្ថែមទៀតប្រសិនបើមានការប្រគល់មុខងារកាន់តែច្បាស់ ពិសេសរវាងរដ្ឋបាលខេត្ត និងក្រុង ស្រុក ពាក់ព័ន្ធនឹងការស្តារ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ។ នៅក្នុងកម្រិតក្រុង ស្រុក, ការផ្ទេរមុខងារដែលមានល្បឿនយឺតខ្លាំង (រួមជាមួយនឹងការផ្ទេរថវិកា និងការផ្ទេរមន្ត្រីដើម្បីបម្រើការងារ) ដល់ ក្រុង ស្រុក បានក្លាយទៅជាបញ្ហាសម្រាប់ការផ្តល់សេវាសាធារណៈតាមក្រុង ស្រុក ទាំងមូល និងការកែទម្រង់ថវិកា។ ទាក់ទងនឹងការផ្តល់សេវាក្នុងតំបន់ ចំណុចដែលត្រូវបានមើលរំលងដ៏សំខាន់គឺការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់សេវាក្នុងតំបន់។ សម្រាប់កម្រិតឃុំ សង្កាត់ ការផ្តោតសំខាន់ក្នុងរយៈពេលដ៏ខ្លីនេះគួរ ផ្តោតលើការកែលម្អដំណើរការកិច្ចលទ្ធកម្ម ជាពិសេសបន្ទាប់ពីការកែប្រែច្បាប់លទ្ធកម្មបច្ចុប្បន្ន។ ថ្នាក់ខេត្ត, គួរពង្រឹងសមត្ថភាពធ្វើផែនការ (ថវិកាកម្មវិធី និងផែនការយុទ្ធសាស្រ្តថវិកា), កែលម្អសមត្ថភាពព្យាករណ៍ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ, ពង្រឹងភាពច្បាស់លាស់ នៃមុខងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ជាពិសេសលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងយន្តការការងារជាមួយវិស័យឯកជន, ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, និងកែលម្អដំណើរការអនុវត្តថវិកា។ នៅថ្នាក់ស្រុក, គួរកែលម្អ លទ្ធភាពថវិកា និងភាពច្បាស់លាស់នៃមុខងារ ដោយដោះស្រាយគម្លាតថវិកានៅថ្នាក់ក្រុង ស្រុក និងកំណត់គតិយុត្ត ដែលត្រូវកែសម្រួល ស្របទៅនឹងការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ បន្ថែមពីនេះ គួរកែលម្អការគ្រប់គ្រងធនធានមនុស្ស ដោយដោះស្រាយបញ្ហាកង្វះបុគ្គលិករដ្ឋសម្រាប់សេវាគន្លឹះ (ការផ្គត់ផ្គង់ទឹក និងសំណល់រឹង) និងរៀបចំល័ក្ខខ័ណ្ឌយោងការងារសម្រាប់រដ្ឋបាលក្រុង ស្រុក។ នៅថ្នាក់ឃុំ សង្កាត់, ដោះស្រាយភាពយឺតពេលនៃការរៀបចំ និងអភិវឌ្ឍន៍គម្រោង ដោយគាំទ្រមន្ត្រីឃុំ សង្កាត់អនុវត្តសារាចរពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍។

*ប្រភេទចំណូលរបស់រដ្ឋបាលខេត្តព្រះសីហនុ (២០១៨-២០២០)*




រៀបចំអត្ថបទដោយៈ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ នៃ អ.គ.ហ.

*ការចំណាយនៅខេត្តព្រះសីហនុ, គ្រោងនិងជាក់ស្តែង,គិតជាភាគរយ (២០១៨-២០២០)*




# សន្និដ្ឋានរួម

របាយការណ៍វាយតម្លៃប្រសិទ្ធភាពប្រព័ន្ធនិងការគ្រប់គ្រងថវិកានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដោយប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ ទាំង PER និង PEFA បូករួមទាំងវិធីសាស្ត្រប្រមូលធាតុចូលទិន្នន័យគំរូ (Sampling techniques) ទាំងបរិមាណ និងគុណភាព (Quantitative and Qualitative) តាមវិស័យអាទិភាពមានជាអាទិ៍វិស័យកសិកម្ម, វិស័យធារាសាស្ត្រនិងការគ្រប់គ្រងធនធានទឹក, វិស័យសុខាភិបាល, រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលរាជធានីភ្នំពេញនិងរដ្ឋបាលខេត្តព្រះសីហនុ និងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឆ្លុះបញ្ចាំងស្ថានភាពនៃប្រព័ន្ធ និងការគ្រប់គ្រងថវិកាទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ។ របកគំហើញនៃរបាយការណ៍បានរំលេចនូវអនុសាសន៍ជាយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងរយៈពេលវែង ដើម្បីកែលម្អប្រព័ន្ធនិងការគ្រប់គ្រងថវិកា នៅតាមវិស័យ។

# កំណែទម្រង់ពន្ធ
# លើចលនទ្រព្យ







# និងអចលនទ្រព្យ
# នៅអាស៊ីអាគ្នេយ៍

អត្ថបទនេះ បង្ហាញអំពីទិដ្ឋភាពទូទៅ និងយុទ្ធសាស្ត្រកែទម្រង់លើប្រព័ន្ធពន្ធលើចលនទ្រព្យនិងអចលនទ្រព្យនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ចំនួន ៤ រួមមាន៖ កម្ពុជា, ហ្វីលីពីន, ថៃ និងវៀតណាម ក៏ដូចជាឆ្លុះបញ្ចាំងពីបទពិសោធន៍ឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលប្រទេសនីមួយៗជួបប្រទះលើកិច្ចការប្រមូលចំណូល។ ជាទូទៅ ពន្ធលើចលនទ្រព្យ និងអចលនទ្រព្យគ្របដណ្ដប់លើទាំងប្រភេទពន្ធដែលត្រូវបង់ជាប្រចាំ(Recurrent Taxes)និងប្រភេទពន្ធដែលត្រូវបង់ពេលមានសកម្មភាពសេដ្ឋកិច្ច (Nonrecurrent Taxes)ដែលត្រូវប្រមូលលើការប្រើប្រាស់, ភាពជាម្ចាស់កម្មសិទ្ធិ, និងការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ។ ប្រភេទពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ រួមមាន៖ ១. ពន្ធលើអចលនទ្រព្យ (Tax on Immovable Property) ត្រូវបង់ជាប្រចាំ, ២. ពន្ធលើទ្រព្យសម្បត្តិសុទ្ធ (Tax on Net Wealth) ត្រូវបង់ជាប្រចាំ, ៣. ពន្ធលើមរតក និងអំណោយ (Tax on Inheritances and Gifts), ៤. ពន្ធលើប្រតិបត្តិការហិរញ្ញវត្ថុ និងមូលធន (Tax on Financial and Capital Transactions) និង ៥. ពន្ធពាក់ព័ន្ធផ្សេងទៀត។

## I. ទិដ្ឋភាពទូទៅ នៃការប្រមូលពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ នៅក្នុងប្រទេសទាំង ៤

សម្រាប់ប្រទេសទាំង ៤ ដែលត្រូវបានកំណត់ក្នុងសិក្សានេះ ប្រទេសខ្លះមានប្រភេទពន្ធលើអចលនទ្រព្យដែលត្រូវបង់ជាប្រចាំលើសពីមួយប្រភេទពន្ធ ប៉ុន្តែប្រទេសទាំងនេះពុំមាននូវប្រភេទពន្ធលើទ្រព្យសម្បត្តិសុទ្ធ ដែលត្រូវបង់ជាប្រចាំនោះទេ។ ជាការកត់សម្គាល់ក្នុងចំណោមប្រទេសទាំង៤កម្ពុជាអនុវត្តការប្រមូលពន្ធលើចលនទ្រព្យនិងអចលនទ្រព្យជាមួយនឹងចំនួនប្រភេទពន្ធតិចនិងអត្រាពន្ធមានកម្រិតទាបជាងគេ។តារាងខាងក្រោមបង្ហាញអំពីទិដ្ឋភាពទូទៅនៃប្រភេទពន្ធលើចលនទ្រព្យនិងអចលនទ្រព្យនៅក្នុងប្រទេសទាំង ៤ ដូចតទៅ៖



# កម្ពុជា

| ឈ្មោះពន្ធ | អត្រាពន្ធ | ប្រភេទពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ | | | |
|---|---|---|---|---|---|
| | | អចលនទ្រព្យ (ត្រូវបង់ជាប្រចាំ) | មរតក និងអំណោយ | ការផ្ទេរហិរញ្ញវត្ថុ និងមូលធន | ផ្សេងទៀត |
| ពន្ធលើអចលនទ្រព្យ<br>Tax on Immovable Property<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធ ០,១% លើអចលនទ្រព្យ ស្ថិតក្នុងរាជធានី និងក្រុងនៃបណ្តាខេត្ត | ✔ | | | |
| ពន្ធលើដីធ្លីមិនបានប្រើប្រាស់<br>Tax on Unused Land<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធ ២% នៃតម្លៃដី | ✔ | | | |
| ពន្ធប្រថាប់ត្រា<br>Registration Tax (Transfer Tax)<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធ ៤% នៃតម្លៃចលនទ្រព្យ និង អចលនទ្រព្យដែលត្រូវធ្វើការផ្ទេរសិទ្ធិ | | | ✔ | |



# ហ្វីលីពីន

| ឈ្មោះពន្ធ | អត្រាពន្ធ | ប្រភេទពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ | | | |
|---|---|---|---|---|---|
| | | អចលនទ្រព្យ (ត្រូវបង់ជាប្រចាំ) | មរតក និងអំណោយ | ការផ្ទេរហិរញ្ញវត្ថុ និងមូលធន | ផ្សេងទៀត |
| ពន្ធលើអចលនទ្រព្យ<br>Real Property Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | - អត្រាពន្ធ ១% លើអចលនទ្រព្យនៅបណ្តាខេត្ត<br>- អត្រាពន្ធ ២% លើអចលនទ្រព្យនៅរដ្ឋធានីម៉ានីល | ✓ | | | |
| ពន្ធលើដីធ្លីមិនបានប្រើប្រាស់<br>Idle Land Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធ ៥% នៃតម្លៃដី | ✓ | | | |
| ពន្ធលើមរតក<br>Estate Tax (Inheritance Tax)<br>*សម្រាប់ថវិកាថ្នាក់ជាតិ* | អត្រាពន្ធ ៦% នៃតម្លៃមរតក | | ✓ | | |
| ពន្ធលើអំណោយ<br>Donor's Tax (Gift Tax)<br>*សម្រាប់ថវិកាថ្នាក់ជាតិ* | អត្រាពន្ធ ៦% លើអំណោយដែលមានតម្លៃលើសពី ២៥០.០០០ ប៉េសូ (ប្រមាណ ៥.០០០ ដុល្លារអាមេរិក) | | ✓ | | |
| ពន្ធលើការផ្ទេរសិទ្ធិ<br>Transfer Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | - អត្រាពន្ធអតិបរិមា ០,៥% លើតម្លៃទីផ្សារនៃអចលនទ្រព្យ ឬតម្លៃលើកិច្ចសន្យា ដែលមួយណាខ្ពស់ជាង សម្រាប់ការលក់ ការផ្តល់ជាអំណោយ ការផ្លាស់ប្តូរ ឬមធ្យោបាយផ្សេងទៀតនៃការផ្ទេរសិទ្ធិអចលនទ្រព្យ<br>- អត្រាពន្ធអតិបរិមា ០,៧៥% លើអចលនទ្រព្យដែលស្ថិតនៅ | | | ✓ | |
| ពន្ធមូលនិធិអប់រំពិសេស<br>Special Education Fund Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធ ១% ទៅលើតម្លៃអចលនទ្រព្យ ត្រូវបង់ប្រចាំឆ្នាំក្នុងគោលដៅរួមចំណែកដល់មូលនិធិគាំទ្រការអប់រំសាធារណៈ | | | | ✓ |
| ការប្រមូលចំណូលពិសេស<br>Special Levy<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | សំដៅលើដីធ្លីដែលទទួលបានអត្ថប្រយោជន៍ពីគម្រោងសាធារណៈ ឬការអភិវឌ្ឍសាធារណៈ | | | | ✓ |
| ពន្ធលើលំនៅដ្ឋានសង្គម<br>Socialized Housing Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធ ០.៥% លើដីទាំងអស់ដែលស្ថិតក្នុងតំបន់ទីក្រុងហើយមានតម្លៃលើសពី៥០.០០០ ប៉េសូ (ប្រមាណ ៩៩០ ដុល្លារអាមេរិក) | | | | ✓ |
| ពន្ធតែមប្រ៊ី<br>Documentary Stamp Tax<br>*សម្រាប់ថវិកាថ្នាក់ជាតិ* | អត្រាពន្ធ ១.៥% លើតម្លៃកំណត់ក្នុងប្បញ្ញត្តិ ឬតម្លៃទទួលបាន ឬកិច្ចសន្យានឹងទទួលបាន ការទូទាត់ជាក់ស្តែងសម្រាប់ការផ្ទេរអចលនទ្រព្យ | | | ✓ | |

# ថៃ

| ឈ្មោះពន្ធ | អត្រាពន្ធ | ប្រភេទពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ | | | |
|---|---|---|---|---|---|
| | | អចលនទ្រព្យ (ត្រូវបង់ជាប្រចាំ) | មរតក និងអំណោយ | ការផ្ទេរហិរញ្ញវត្ថុ និងមូលធន | ផ្សេងទៀត |
| ពន្ធលើដី និងអគារ<br>Land and Building Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រាពន្ធផ្សេងៗគ្នា (ពោលគឺចន្លោះពី ០,០១% ទៅ ១,២%) និងកំណើនតាមថ្នាក់ ផ្អែកលើការប្រើប្រាស់ និងប្រភេទនៃអចលនទ្រព្យ | ✓ | | | |
| ពន្ធលើមរតក<br>Inheritance Tax<br>*សម្រាប់ថវិកាថ្នាក់ជាតិ* | ពន្ធនេះត្រូវប្រមូលលើមរតកដែលមានតម្លៃលើសពី ១០០ លានបាត (ប្រមាណ ២,៨ លានដុល្លារអាមេរិក) ហើយមាន៖<br>- អត្រាពន្ធ ៥% លើមរតកទទួលបានដោយអ្នកទទួលមរតកជាសាច់លោហិតផ្ទាល់ ឬកំណត់ដោយច្បាប់ លើកលែងសហព័ន្ធ<br>- អត្រាពន្ធ ១០% លើមរតកទទួលបានដោយអ្នកទទួលមរតកក្រៅពីខាងលើ | | ✓ | | |
| កម្រៃលើការផ្ទេរអចលនទ្រព្យ<br>Property Transfer Fee<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រា ២% លើតម្លៃអចលនទ្រព្យ ដែលបានវាយតម្លៃ សម្រាប់ការលក់ និងការផ្ទេរសិទ្ធិ | | | ✓ | |
| ពន្ធតែមប្រិ៍<br>Stamp Duty Tax<br>*សម្រាប់ថវិកាថ្នាក់ជាតិ* | ពន្ធនេះត្រូវប្រមូលលើលិខិតបទដ្ឋានច្បាប់ជាក់លាក់មួយចំនួនជាមួយអត្រាផ្សេងគ្នា រួមមាន៖<br>- អត្រាពន្ធ ០,៥% នៃតម្លៃលក់សម្រាប់ការផ្ទេរអចលនទ្រព្យ<br>- អត្រាពន្ធ ០,១% នៃតម្លៃជួល ឬការទូទាត់ដទៃទៀតក្រោមភតិសន្យា | | | ✓ | |

# វៀតណាម

| ឈ្មោះពន្ធ | អត្រាពន្ធ | ប្រភេទពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ | | | |
|---|---|---|---|---|---|
| | | អចលនទ្រព្យ (ត្រូវបង់ជាប្រចាំ) | មរតក និងអំណោយ | ការផ្ទេរហិរញ្ញវត្ថុ និងមូលធន | ផ្សេងទៀត |
| ពន្ធលើការប្រើប្រាស់ដីមិនមែនកសិកម្ម<br>Non-Agricultural Land Use Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | - អត្រាពន្ធកំណើនតាមថ្នាក់ពី ០,០៣% ទៅ ០,១៥% សម្រាប់ដីលំនៅដ្ឋាន<br>- អត្រាពន្ធ ០,០៣% សម្រាប់ដីពាណិជ្ជកម្ម និងដីឧស្សាហកម្ម | ✓ | | | |
| ពន្ធលើការប្រើប្រាស់ដីកសិកម្ម<br>Agricultural Land Use Tax<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | ពន្ធត្រូវបានគណនាផ្អែកលើបរិមាណស្រូវក្នុងមួយហិកតាដោយបង្វែរជាប្រាក់ជាមួយនឹងតារាងតម្លៃកំណត់ដោយរដ្ឋ។ ប៉ុន្តែ ពន្ធនេះត្រូវបានលើកលែងចាប់តាំងពីឆ្នាំ ២០០១ ដល់ ២០២០ ហើយរំពឹងថានឹងត្រូវបន្តលើកលែងដល់ឆ្នាំ២០២៥។ | ✓ | | | |
| កម្រៃលើការចុះបញ្ជី<br>Registration Fee<br>*សម្រាប់ថវិកាថ្នាក់ក្រោមជាតិ* | អត្រា ០,៥% លើតម្លៃអចលនទ្រព្យ នៅពេលចុះបញ្ជីសិទ្ធិប្រើប្រាស់ដី កម្មសិទ្ធិផ្ទះ និងទ្រព្យសកម្មផ្សេងទៀតនៅលើដី។ | | | ✓ | |

## II. ការរៀបចំបែបបទរដ្ឋបាលសម្រាប់គ្រប់គ្រងពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ

រដ្ឋបាលគ្រប់គ្រងនៃពន្ធលើចលនទ្រព្យ និងអចលនទ្រព្យរួមបញ្ចូលនូវមុខងារត្រូវអនុវត្តចំនួន ៤រួមមាន៖ (១) ការវាយតម្លៃអចលនទ្រព្យ, (២) ការកំណត់ប្រាក់ពន្ធត្រូវបង់ ការប្រមូលពន្ធ និងការពង្រឹងការអនុវត្តច្បាប់, (៣) ការទទួលបណ្តឹងតវ៉ាពីអ្នកជាប់ពន្ធ, និង (៤) ការផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធ ដែលមានលម្អិតដូចខាងក្រោម៖

### ១. ការវាយតម្លៃអចលនទ្រព្យ

ដំណើរការរៀបចំឱ្យមាននូវការវាយតម្លៃអចលនទ្រព្យមួយដែលមានលក្ខណៈល្អប្រសើរ ត្រូវពឹងផ្អែកលើសមត្ថភាពរដ្ឋបាលគ្រប់គ្រង, ធនធានមនុស្សនិងហិរញ្ញវត្ថុ និងប្រព័ន្ធទិន្នន័យអចលនទ្រព្យត្រឹមត្រូវច្បាស់លាស់មួយដែលមានកត់ត្រារាល់ព័ត៌មានលម្អិតនៃអចលនទ្រព្យ, តម្លៃ និងព័ត៌មានអ្នកជាប់ពន្ធដោយរួមបញ្ចូលនូវលក្ខខណ្ឌដែលអាចទទួលបានការលើកលែង ឬបន្ធូរបន្ថយពន្ធ។ ការអភិវឌ្ឍប្រព័ន្ធទិន្នន័យអចលនទ្រព្យត្រូវបានមើលឃើញថានឹងត្រូវចំណាយខ្ពស់សម្រាប់រដ្ឋបាលសារពើពន្ធ ប៉ុន្តែជាកិច្ចការចាំបាច់មួយក្នុងដំណើរការរៀបចំឱ្យមាននូវការវាយតម្លៃអចលនទ្រព្យ។

### ២. ការកំណត់ប្រាក់ពន្ធត្រូវបង់ ការប្រមូលពន្ធ និងការពង្រឹងការអនុវត្តច្បាប់

ប្រទេសទាំង ៤ បានរៀបចំនូវសេចក្តីជូនដំណឹងប្រចាំឆ្នាំជាសាធារណៈ និងបុគ្គល ដើម្បីរំលឹកអ្នកជាប់ពន្ធអំពីកាតព្វកិច្ចត្រូវបង់ពន្ធ។ នៅកម្ពុជានិងវៀតណាមអង្គភាពពន្ធដារថ្នាក់មូលដ្ឋាននៃរដ្ឋបាលសារពើពន្ធទទួលបន្ទុកលើការប្រមូលពន្ធនិងការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ ចំណែកនៅហ្វីលីពីន និងថៃ រដ្ឋបាលគ្រប់គ្រងនិងការប្រមូលពន្ធត្រូវបានធ្វើវិមជ្ឈការ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការប្រមូលពន្ធ ក៏ដូចជាធ្វើការពិន័យសម្រាប់ការខកខានក្នុងការបង់ពន្ធ។

### ៣. ការទទួលបណ្តឹងតវ៉ាពីអ្នកជាប់ពន្ធ

ដើម្បីការពារសិទ្ធិរបស់អ្នកជាប់ពន្ធ ប្រទេសទាំង ៤ បានរៀបចំឱ្យមាននូវដំណើរការទទួលបណ្តឹងតវ៉ាដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធធ្វើការតវ៉ាលើការកំណត់ពន្ធនិងការវាយតម្លៃអចលនទ្រព្យ។ជាទូទៅអ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅកាន់រដ្ឋបាលគ្រប់គ្រងថ្នាក់មូលដ្ឋានឬអង្គភាពពន្ធដារដែលទទួលបន្ទុកកំណត់ពន្ធនិងវាយតម្លៃអចលនទ្រព្យហើយប្រសិនបើបណ្តឹងតវ៉ានោះពុំអាចដោះស្រាយបានអ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅកាន់កម្រិតបន្តបន្ទាប់ដែលបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិ មុននឹងឈានដល់ការដោះស្រាយតាមផ្លូវតុលាការ។

### ៤. ការផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធ

ការផ្តល់សេវានិងការអប់រំដល់អ្នកជាប់ពន្ធដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់កម្រិតអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្តរបស់អ្នកជាប់ពន្ធនិងបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលហើយយុទ្ធសាស្ត្រសម្រាប់មុខងារនេះក៏រួមបញ្ចូលនូវការធ្វើឱ្យមានភាពងាយស្រួលក្នុងការបង់ពន្ធតាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារអនឡាញ និងតាមរយៈទូរស័ព្ទដៃ ខណៈដែលប្រទេសទាំង ៤ នៅក្នុងការសិក្សានេះប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា។

## II. ការរៀបចំបែបបទរដ្ឋបាលសម្រាប់គ្រប់គ្រងពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ

គោលបំណងនៃការធ្វើកំណែទម្រង់ពន្ធលើចលនទ្រព្យ និងអចលនទ្រព្យមានចំនួន ៤ ជាចម្បងរួមមាន៖ (១) បង្កើនចំណូលរបស់រដ្ឋាភិបាល, (២) ធ្វើឱ្យប្រសើរឡើងនូវសមធម៌សង្គម, (៣) បង្កើនស័ក្តិសិទ្ធិភាពនៃសេដ្ឋកិច្ច និង (៤) បង្កើនប្រសិទ្ធភាពនៃរដ្ឋបាលគ្រប់គ្រង។ ទន្ទឹមនេះ យុទ្ធសាស្ត្រនៃកំណែទម្រង់ពន្ធលើចលនទ្រព្យ និងអចលនទ្រព្យនៅក្នុងប្រទេសទាំង ៤ ត្រូវបានធ្វើឡើងផ្សេងៗគ្នា ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលប្រទេសនីមួយៗជួបប្រទះលើកិច្ចការប្រមូលចំណូលរបស់ខ្លួន។ តារាងខាងក្រោមបង្ហាញអំពីយុទ្ធសាស្ត្រនៃកំណែទម្រង់ពន្ធលើទ្រព្យសម្បត្តិនៅក្នុងប្រទេសទាំង ៤ ដូចតទៅ៖



| គោលបំណងចម្បង | ប្រភេទពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ | | | |
|---|---|---|---|---|
| | **កម្ពុជា** | **ហ្វីលីពីន** | **ថៃ** | **វៀតណាម** |
| បង្កើនចំណូល | - ពង្រឹងការអនុវត្តច្បាប់ និងអនុលោមភាពសារពើពន្ធ<br>- ធ្វើបច្ចុប្បន្នភាពតម្លៃមូលដ្ឋានគិតពន្ធអចលនទ្រព្យឱ្យស្មើ ៧០%-៨០% នៃតម្លៃទីផ្សារ<br>- កំណត់ធ្វើការវាយតម្លៃជាប្រចាំ (រៀងរាល់ ៥ ឆ្នាំ)<br>- ធ្វើបច្ចុប្បន្នភាពការចុះបញ្ជីអចលនទ្រព្យ និងទិន្នន័យ<br>- ពង្រីកវិសាលភាពនៃតំបន់ត្រូវប្រមូលពន្ធ។ | - ស្នើឡើងនូវច្បាប់ស្តីពីកំណែទម្រង់តម្លៃអចលនទ្រព្យ និងការវាយតម្លៃឡើងវិញ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិមាណតម្លៃអចលនទ្រព្យ និងពង្រីកមូលដ្ឋានគិតពន្ធ<br>- រំពឹងថាកំណើននៃចំណូលពន្ធលើអចលនទ្រព្យកើនដល់ ០,៤៣% នៃ ផ.ស.ស.។ | - អនុម័តច្បាប់ថ្មីស្តីពីពន្ធលើដីធ្លី និងសំណង់ (២០២០) ដើម្បីពង្រីកមូលដ្ឋានគិតពន្ធ, ពង្រឹងរដ្ឋបាលគ្រប់គ្រងនិងអនុលោមភាពរបស់អ្នកជាប់ពន្ធ<br>- កំណត់យកតម្លៃទីផ្សារដែលបានធ្វើការវាយតម្លៃ (ជំនួសឱ្យតម្លៃនៃការជួល)<br>- រំពឹងថាចំណូលនឹងកើនបាន ១៧% បន្ទាប់ពីរយៈពេលនៃការអនុវត្តបាន ៣ ឆ្នាំ។ | - ពិចារណាកំណត់យករបបពន្ធលើអចលនទ្រព្យទំនើបមួយ ដោយផ្អែកលើមូលដ្ឋានតម្លៃជាក់ស្តែង<br>- ពង្រីកមូលដ្ឋានគិតពន្ធ ដោយ ប្រមូលពន្ធលើដី និងលើការច្នៃឱ្យប្រសើរឡើង (Improvement)។ |
| សមធម៌សង្គម | - រៀបចំឱ្យមានវិធានការន្ធូរបន្ថយពន្ធដើម្បីកាត់បន្ថយផលប៉ះពាល់ពីបន្ទុកនៃការកើនឡើងនូវប្រាក់ពន្ធ<br>- រៀបចំគោលនយោបាយលើកលែងពន្ធសម្រាប់ករណី "Asset Rich and Cash Poor" ដែលកើតមានឡើងលើអ្នកជាប់ពន្ធមួយចំនួន។ | | - រៀបចំឱ្យមាននូវអត្រាពន្ធកំណើនតាមថ្នាក់(Progressive Tax Rate)<br>- រួមបញ្ចូលនូវអចលនទ្រព្យជាលំនៅដ្ឋានដែលមានតម្លៃខ្ពស់កាន់កាប់ដោយអ្នកជាប់ពន្ធទៅក្នុងមូលដ្ឋានគិតពន្ធ<br>- កំណត់នូវបទប្បញ្ញត្តិអន្តរកាលដើម្បីកាត់បន្ថយផលប៉ះពាល់ពីកំណែទម្រង់ពន្ធ។ | - រៀបចំគោលនយោបាយលើកលែងពន្ធសម្រាប់ករណី "Asset Rich and Cash poor" ដែលកើតមានឡើងលើអ្នកជាប់ពន្ធមួយចំនួន។ |
| ស័ក្តិសិទ្ធិភាពនៃសេដ្ឋកិច្ច | | - បង្កើនស័ក្តិសិទ្ធិភាពនៃការប្រើប្រាស់ដី តាម រយៈការពង្រឹង និងការប្រមូលពន្ធលើដីធ្លីមិនប្រើប្រាស់។ | - រៀបចំនូវអត្រាពន្ធខ្ពស់លើដីធ្លីមិនប្រើប្រាស់ ឬដីទំនេរ ដើម្បីជំរុញស័ក្តិសិទ្ធិភាពនៃការប្រើប្រាស់ដី។ | |
| ប្រសិទ្ធភាពនៃរដ្ឋបាលគ្រប់គ្រង | - ធ្វើឱ្យប្រសើរឡើងនូវការផ្លាស់ប្តូរទិន្នន័យរវាងក្រសួងស្ថាប័នពាក់ព័ន្ធ និងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងអចលនទ្រព្យ សម្រាប់គោលដៅពន្ធ។ | - រៀបចំស្តង់ដារនៃដំណើរការវាយតម្លៃ<br>- រៀបចំមូលដ្ឋានវាយតម្លៃរួមសម្រាប់ការប្រមូលពន្ធ<br>- កំណត់តាមស្តង់ដារអន្តរជាតិ<br>- ប្រមូលផ្តុំឡើងវិញនិងកាត់បន្ថយកត្តាពាក់ព័ន្ធនឹងនយោបាយលើការសម្រេចឱ្យមាននូវកាលវិភាគនៃតម្លៃទីផ្សារជាប្រចាំ។<br>- រៀបចំបង្កើតនូវទិន្នន័យអេឡិចត្រូនិក ដើម្បីគាំទ្រដល់ការវាយតម្លៃ។ | - ធ្វើសាមញ្ញភាពនូវក្របខ័ណ្ឌបទប្បញ្ញត្តិ ដោយបញ្ចូលគ្នានូវប្រភេទពន្ធ ចំនួន ២ (ពន្ធលើអគារនិងដី និងពន្ធលើការអភិវឌ្ឍដី)<br>- អភិវឌ្ឍទិន្នន័យរួមពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ។ | - ធ្វើសាមញ្ញភាពនូវក្របខ័ណ្ឌបទប្បញ្ញត្តិ ដោយបញ្ចូលគ្នានូវប្រភេទពន្ធលើការប្រើប្រាស់ដីចំនួន ២ (ពន្ធលើការប្រើប្រាស់ដីកសិកម្ម និងពន្ធលើការប្រើប្រាស់ដីមិនមែនកសិកម្ម)។ |

# IV. សេចក្ដីសន្និដ្ឋាន និងទិសដៅគួរអនុវត្ត

ពន្ធលើចលនទ្រព្យ និងអចលនទ្រព្យ ត្រូវបានចាត់ទុកជាប្រភពចំណូលដ៏មានសក្ដានុពល និងអាចដើរតួនាទីយ៉ាងសំខាន់មួយសម្រាប់យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការប្រមូលចំណូលប្រភពផ្ទៃក្នុងប្រកបដោយចីរភាព។ ទោះជាយ៉ាងនេះក្ដី ពន្ធលើចលនទ្រព្យនិងអចលនទ្រព្យដែលត្រូវបង់ជាប្រចាំ(RecurrentTax)នៅក្នុងប្រទេសទាំង៤ត្រូវបានមើលឃើញថាពុំទាន់ជាប្រភពចំណូលរួមចំណែកសំខាន់នៅឡើយ ដោយហេតុថាភាគរយនៃចំណូលពន្ធលើចលនទ្រព្យ និងអចលនទ្រព្យដែលប្រមូលបានធៀបនឹង ផ.ស.ស. នៅមានកម្រិតទាប ដែលនេះបណ្ដាលមកពីបញ្ហានៃការរៀបចំគោលនយោបាយ រួមមាន៖ មូលដ្ឋានគិតពន្ធមានលក្ខណៈចង្អៀត, អត្រាពន្ធមានប្រសិទ្ធភាពទាប, និងតម្លៃទាបជាងទីផ្សារ។ បន្ថែមពីលើនេះ គម្លាតនៃធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទិន្នន័យ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន បានបង្កឱ្យមានផលប៉ះពាល់លើសមត្ថភាពរដ្ឋបាលគ្រប់គ្រងនិងប្រតិបត្តិការ សម្រាប់ការអនុវត្ត និងការពង្រឹងលើកិច្ចការប្រមូលចំណូលពន្ធលើចលនទ្រព្យនិងអចលនទ្រព្យ។យុទ្ធសាស្ត្រដើម្បីសម្រេចបាននូវការបង្កើនចំណូលពន្ធប្រកបដោយចីរភាពពីកំណែទម្រង់ពន្ធលើចលនទ្រព្យនិងអចលនទ្រព្យចាំបាច់ត្រូវតែរៀបចំប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ស្របតាមស្ថានភាពជាក់ស្ដែងក្នុងប្រទេសនីមួយៗ និងត្រូវធ្វើឡើងសន្សឹមៗ ដើម្បីចៀសវាងនូវផលប៉ះពាល់ដល់អ្នកជាប់ពន្ធដែលងាយនឹងរងគ្រោះ និងត្រូវរៀបចំវិធានការផ្ដល់សំណងដែលចាំបាច់សម្រាប់ពួកគេ។ជាគំនិតគួរពិចារណាសម្រាប់ទិសដៅគួរអនុវត្តក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវកិច្ចការប្រមូលចំណូល បានកំណត់នូវបញ្ហាប្រឈមមួយចំនួនគួរធ្វើការឆ្លើយតប ដូចខាងក្រោម៖

## ១. ការវាយតម្លៃអចលនទ្រព្យ



ពង្រីកមូលដ្ឋានពន្ធ៖ ប្រទេសទាំង ៤ បានកំណត់ឱ្យមាននូវការលើកលែងពន្ធ, ការលើកទឹកចិត្តពន្ធ, និងការបន្ធូរបន្ថយពន្ធ ដែលជាអត្ថប្រយោជន៍ពន្ធកំណត់ក្នុងច្បាប់បទប្បញ្ញត្តិ ហើយអត្ថប្រយោជន៍ទាំងនេះធ្វើឱ្យមូលដ្ឋានពន្ធមានលក្ខណៈរួមចង្អៀត។

បង្កើនប្រសិទ្ធភាពនៃអត្រាពន្ធ៖ អត្រាពន្ធជាទូទៅគឺទាប ជាមួយនឹងប្រសិទ្ធភាពនៃអត្រាពន្ធក៏កាន់តែមានកម្រិតទាប។

ប្រើប្រាស់តម្លៃទីផ្សារដែលបានធ្វើបច្ចុប្បន្នភាព៖ ការវាយតម្លៃអចលនទ្រព្យ ពុំឆ្លុះគ្នាទៅនឹងតម្លៃទីផ្សារដោយសារតែភាពមានកម្រិត នៃធនធានរបស់រដ្ឋបាលគ្រប់គ្រងសម្រាប់ការអនុវត្តកិច្ចការនេះ។

## ២. ការរក្សាកំណត់ត្រាទិន្នន័យសុរិយោដី

ធ្វើទំនើបភាវូបនីយកម្មហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ៖ តម្រូវការចម្បងក្នុងការប្រមូលពន្ធលើអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពគឺប្រព័ន្ធចុះបញ្ជីអចលនទ្រព្យ និងទិន្នន័យសុរិយោដីមួយពេញលេញដែលរួមបញ្ចូលនូវទិន្នន័យអំពីភាពជាម្ចាស់កម្មសិទ្ធិ,សិទ្ធិប្រើប្រាស់, ការប្រើប្រាស់ជាក់ស្ដែង,តម្លៃលក់,ព្រំប្រទល់ដីនិងលក្ខណៈដទៃទៀតនៃអចលនទ្រព្យ។



សហការក្នុងការចែករំលែកទិន្នន័យ៖ កង្វះនូវកិច្ចសម្របសម្រួលរវាងស្ថាប័នរបស់រដ្ឋាភិបាលលើការផ្លាស់ប្ដូរនូវកំណត់ត្រាទិន្នន័យនិងកង្វះនូវភាពស៊ីគ្នានៃទិន្នន័យរវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ស្ថាប័នផ្សេងគ្នា គឺនៅតែជាបញ្ហាប្រឈមមួយ។

រក្សានូវទិន្នន័យដែលជឿជាក់បានសម្រាប់តម្លៃលក់៖ ការវាយតម្លៃទីផ្សារ ត្រូវពឹងផ្អែកលើតម្លៃលក់ដែលអាចធ្វើការប្រៀបធៀបគ្នារវាងតម្លៃដែលអ្នកទិញចង់ទិញ និងតម្លៃដែលអ្នកលក់ចង់លក់ ក្នុងប្រតិបត្តិការជំហោងដៃ (Arm's Length Transaction) ប៉ុន្តែទិន្នន័យជឿជាក់បានសម្រាប់ការលក់បច្ចុប្បន្ន និងតម្លៃកំណត់ជាក់លាក់នៅពុំទាន់អាចធ្វើទៅបាន ដោយសារតែអវត្តមាននៃទីផ្សារអចលនទ្រព្យមួយដែលមានការអភិវឌ្ឍប្រកបដោយភាពទុកចិត្តខ្ពស់។

រៀបចំអត្ថបទដោយ៖ លោក ហួរ ឆាយ, អតីតនិស្សិតអាហារូបករណ៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃសាលាគោលនយោបាយលីក្វាន់យូនៃប្រទេសសិង្ហបុរី ឆ្នាំសិក្សា២០២១-២០២៣

## ៣. បញ្ហាប្រឈមរដ្ឋបាលគ្រប់គ្រង

ពង្រឹងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ៖ ការអនុវត្តពន្ធលើចលនទ្រព្យ និងអចលនទ្រព្យមួយប្រកបដោយប្រសិទ្ធភាពទាមទារនូវសមត្ថភាពរដ្ឋបាលគ្រប់គ្រងមួយដែលពោរពេញដោយធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ខណៈដែលបញ្ហាទូទៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺកង្វះនូវអ្នកវាយតម្លៃអចលនទ្រព្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក៏ដូចជាបច្ចេកវិទ្យាថ្មីៗ និងការផ្គូរផ្គងទិន្នន័យរវាងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ដែលកត្តាទាំងនេះទាមទារនូវការវិនិយោគក្នុងទំហំធំ។



ធ្វើឱ្យប្រសើរឡើងនូវកម្រិតអនុលោមភាពរបស់អ្នកជាប់ពន្ធ៖ដោយសារសមត្ថភាពរដ្ឋបាលគ្រប់គ្រងនៅមានកម្រិតលើការកំណត់តម្លៃអចលនទ្រព្យ ប្រទេសមួយចំនួនអនុវត្តនូវរបបស្វ័យប្រកាសដែលនេះបង្កឱ្យមានការប្រកាសពន្ធទាបជាងជាក់ស្តែង ប្រសិនបើពុំមាននូវការពង្រឹងនូវការពិន័យទោសទណ្ឌ ដើម្បីឆ្លើយតបទៅនឹងការមិនប្រកាសពន្ធ និងការប្រកាសពន្ធខ្វះ។

អនុវត្តស្តង់ដារសម្រាប់ការវាយតម្លៃ៖ ការវាយតម្លៃ គឺជាបញ្ហាប្រឈមចម្បងសម្រាប់រដ្ឋបាលគ្រប់គ្រង នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែការកំណត់ និងការត្រួតពិនិត្យលើស្តង់ដារទូទៅមួយសម្រាប់ការវាយតម្លៃនឹងការពារដល់ប្រភពចំណូលនិងធ្វើឱ្យចៀសផុតពីភាពលំអៀងក្នុងវាយតម្លៃអចលនទ្រព្យ។

ទន្ទឹមនឹងនេះ ការរៀបចំប្រព័ន្ធពន្ធលើចលនទ្រព្យ និងអចលនទ្រព្យមួយល្អប្រសើរមិនត្រឹមតែរួមចំណែកដល់គោលដៅនៃការបង្កើនចំណូលប៉ុណ្ណោះទេ បន្ថែមពីលើនេះ ក៏នឹងគាំទ្រដល់យុទ្ធសាស្រ្តដទៃទៀតរបស់រដ្ឋាភិបាល ដូចជា៖ បម្រើជាឧបករណ៍គោលនយោបាយលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងលើការប្រើប្រាស់ដីធ្លី តាមរយៈការតម្លើងអត្រាពន្ធលើដីធ្លីមិនបានប្រើប្រាស់, ធ្វើឱ្យមានស្ថិរភាពតម្លៃនៃអចលនទ្រព្យដែលជាលំនៅដ្ឋានក៏ដូចជាកំណត់បាននូវតម្លៃដីធ្លីដែលកន្លងមកជាបញ្ហាមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងរៀបចំទីតាំងសម្រាប់គម្រោងអភិវឌ្ឍន៍នានានៅក្នុងប្រទេស។

ជាការឆ្លើយតប ក្រោមកម្មវិធីកំណែទម្រង់របស់ខ្លួន អគ្គនាយកដ្ឋានពន្ធដារបានខិតខំពង្រឹង និងធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធជាពិសេសលើការចុះអង្កេត ដើម្បីជំរុញការចុះបញ្ជីនិងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធលើអចលនទ្រព្យ, ការធ្វើបច្ចុប្បន្នភាពតម្លៃមូលដ្ឋានគិតពន្ធប្រថាប់ត្រា និងការរៀបចំសៀវភៅណែនាំស្តីពីពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ក៏ដូចជាការដាក់ឱ្យដំណើរការកម្មវិធីបង់ប្រាក់ពន្ធលើទូរស័ព្ទដៃ ដើម្បីលើកកម្ពស់សេវាអ្នកជាប់ពន្ធ និងបង្កភាពងាយស្រួលដល់អ្នកជាប់ពន្ធ។ បន្ថែមពីលើនេះ អគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួរបន្តពិចារណាលើកិច្ចការពង្រីកមូលដ្ឋានពន្ធ, ប្រសិទ្ធភាពនៃអត្រាពន្ធ ក៏ដូចជាយន្តការវាយតម្លៃអចលនទ្រព្យឱ្យសមស្របនឹងតម្លៃទីផ្សារសម្រាប់ទិសដៅរយៈពេលវែង ក្នុងគោលបំណងបង្កើនចំណូលប្រកបដោយចីរភាព និងលើកកម្ពស់សមធម៌ ប៉ុន្តែកិច្ចការងារនេះទាមទារនូវការគិតគូរប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់នានាដែលនឹងកើតឡើងលើអ្នកជាប់ពន្ធ៕

# ច្បាប់ ស្តីពី ភាពជាដៃគូ រវាង រដ្ឋ និងឯកជន

ច្បាប់នេះត្រូវបានរៀបចំ និងផ្សព្វផ្សាយជូនថ្នាក់ដឹកនាំ មន្ត្រីរាជការទទួលបន្ទុកកិច្ចការពាក់ព័ន្ធ និងភាគីពាក់ព័ន្ធសំខាន់ៗ នៅថ្ងៃអង្គារ ១៤ កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន(Public-PrivatePartnership-PPPLaw)ត្រូវបានតាក់តែងនិងកែសម្រួលអស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីឆ្នាំ២០១៧ហើយត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១។ បន្ទាប់មក, ច្បាប់នេះទទួលបាន ការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង រហូតដល់ព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាដាក់ឱ្យប្រើកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ កន្លងមក។ ច្បាប់នេះ មានគោលបំណងលើកកម្ពស់ការគ្រប់គ្រងយន្តការ PPP ក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ចីរភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌ ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា។



## ច្បាប់ស្តីពី PPP ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍សំខាន់ចំនួន ៤ គឺ៖

(១)ការថយចុះហិរញ្ញប្បទានឥតសំណងលើសកលលោក និងការបាត់បង់ជាបណ្តើរៗ តទៅអនាគតនូវឥណទានសម្បទានកម្រិតខ្ពស់របស់កម្ពុជា និងម៉្យាងទៀត, ប្រភពធនធានពីថវិកាជាតិនៅមានកម្រិតនៅឡើយ,ប៉ុន្តែតម្រូវការទុនវិនិយោគសាធារណៈសម្រាប់ជំរុញការអភិវឌ្ឍប្រទេសកាន់តែមានទំហំកើនឡើងជាលំដាប់,

(២)វិបត្តិជំងឺកូវីដ-១៩ ក៏បានយាយី និងបង្កផលប៉ះពាល់អវិជ្ជមានដល់សមិទ្ធផលសង្គម សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកនិងបន្ថប់បង្អាក់ដល់ដំណើរការអភិវឌ្ឍន៍ឈានឡើងរបស់កម្ពុជា,

(៣)រាជរដ្ឋាភិបាលកំពុងបន្តខិតខំប្រឹងប្រែងក្នុងការបញ្ចៀសកម្ពុជាកុំឱ្យធ្លាក់ផុងទៅក្នុង "អន្ទាក់នៃថ្លៃ" ដែលអាចកើតឡើងតាមរយៈការចុះកិច្ចសន្យារយៈពេលវែងដែលអាចឱ្យអ្នកប្រើប្រាស់ជាប់កាតព្វកិច្ចបង់ថ្លៃសេវា និងរដ្ឋជាប់កាតព្វកិច្ចបំណុលជាយថាហេតុប្រសិនបើមិនមានការពិនិត្យ និងវាយតម្លៃត្រឹមត្រូវ ម៉ត់ចត់ និង

(៤) ភាពចាំបាច់ក្នុងការទាក់ទាញនូវការចូលរួមពីដៃគូឯកជន ក្នុងការជំរុញកំណើន និងការរក្សាជវភាពសេដ្ឋកិច្ច ដោយផ្អែកលើមូលដ្ឋាននៃប្រភពធនធាន និងនវានុវត្តន៍របស់វិស័យឯកជនក្នុងការចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការផ្តល់សេវាសាធារណៈ។





រៀបចំអត្ថបទដោយ៖ អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន




ច្បាប់ ស្តីពី PPP នឹងបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងលើការរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោង PPP នៅកម្ពុជា ប្រកបដោយភាពច្បាស់លាស់ តាមរយៈការបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់រវាងស្ថាប័នសាមី ដែលជាស្ថាប័នដឹកមុខតាមវិស័យ ក្នុងការរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោង, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ពាក់ព័ន្ធផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ទៅតាមដំណាក់កាលនៃវដ្តគម្រោងដូចមានចែងក្នុងច្បាប់នេះ និងបានបំពេញបន្ថែមនូវនីតិវិធីសំខាន់ៗមួយចំនួន ដូចជាការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើសគម្រោង, ការសិក្សា និងវាយតម្លៃគម្រោង, ការជ្រើសរើសដៃគូឯកជននិងទីប្រឹក្សាពាក់ព័ន្ធ ការរៀបចំកិច្ចសន្យា និងដាក់ចេញនូវយន្តការគាំទ្រហិរញ្ញវត្ថុ, ការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោង PPP និងការតាមដាននិងអនុវត្តគម្រោង ព្រមទាំងគោលការណ៍ណែនាំចាំបាច់មួយចំនួនទៀត។

ច្បាប់ ស្តីពី PPP ត្រូវបានជំនួសច្បាប់ស្តីពីសម្បទាន ប៉ុន្តែបទប្បញ្ញត្តិនៃច្បាប់ថ្មីនេះមិនមានអានុភាពប្រតិសកម្មចំពោះ កិច្ចព្រមព្រៀងសម្បទាន ឬកិច្ចសន្យា ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចសន្យា PPP ដែលត្រូវបានចុះហត្ថលេខា មុនច្បាប់ PPP ចូលជាធរមាននោះទេ។

ច្បាប់ស្តីពី PPP នេះ ក៏នឹងបំពេញគ្នាទៅវិញទៅមកជាមួយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈ ការលើកទឹកចិត្តផ្នែកវិនិយោគ និងការការពារគម្រោងវិនិយោគ ដែលមានន័យថា គម្រោង PPP អាចនឹងទទួលបាននូវការចូលរួម និងការគាំទ្រនានាពីរដ្ឋ តាមរយៈក្រសួង ស្ថាប័នសាមីដែលមានសមត្ថកិច្ចទទួលខុសត្រូវតាមវិស័យពាក់ព័ន្ធនីមួយៗ និងដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះការការពារ និងការលើកទឹកចិត្តលើការវិនិយោគ រួមបញ្ចូលទាំងការអនុគ្រោះផ្នែកសារពើពន្ធ សម្រាប់គម្រោង PPP គឺត្រូវអនុវត្តស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ពាក់ព័ន្ធជាធរមាន។

ថ្វីត្បិតប្រទេសកម្ពុជាបានអនុវត្តគម្រោងសម្បទានចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងវិស័យអាកាសចរណ៍និងថាមពល និងមានច្បាប់ស្តីពីសម្បទានក្នុងឆ្នាំ២០០៧ដែលត្រូវបានជំនួសដោយច្បាប់ស្តីពីPPPថ្មីៗនេះក៏ដូចជាបានអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ឆ្នាំ២០១៦-២០២០ (PPP Policy 2016-2020) ក៏ពិតមែន ប៉ុន្តែការគ្រប់គ្រងយន្តការ PPP ឬក៏ទីផ្សារ PPP នៅកម្ពុជានៅតែស្ថិតក្នុងដំណាក់កាលមួយ ដែលទាមទារឱ្យមានការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងគម្រោង PPP បន្ថែមទៀត ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្ត និងឆ្លុះបញ្ចាំងពីបរិការណ៍ជាក់ស្តែងរបស់កម្ពុជា៕

# ផ្នែកទី ៣

# សុន្ទរកថា




នាយករដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE


នាយករដ្ឋមន្ត្រី

# សុន្ទរកថាគន្លឹះ
# របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត
# ដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ “គណនេយ្យភាពសមិទ្ធកម្ម”
# នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃចន្ទ ១៤ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣

- សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា នៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, ឯកអគ្គរាជទូត, ឯកឧត្តមអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ន ជាទីមេត្រី !

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុង «ពិធីប្រកាសដាក់ឱ្យអនុវត្ត ដំណាក់កាលទី ៤ : គណនេយ្យភាពសមិទ្ធកម្ម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ដែលជាទិវាប្រវត្តិសាស្ត្រមួយទៀត នៅក្នុងដំណើរការនៃការកែទម្រង់អភិបាលកិច្ចនៅកម្ពុជា។

ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា បាន និងកំពុងបន្តឈានឡើងជាលំដាប់ ឥតឈប់ឈរ នៅលើមាគ៌ាដ៏ត្រឹមត្រូវ និងប្រកបដោយក្តីសង្ឃឹម។ផ្លែផ្កាជាសមិទ្ធផលទទួលបាននាបច្ចុប្បន្នដុះចេញពីឫសគល់ដែលជាមូលដ្ឋានគ្រឹះពីអតីតកាលនោះគឺការបញ្ចប់ជាស្ថាពរនូវសង្គ្រាម និងការធានាបាននូវសុខសន្តិភាពបរិបូរណ៍ពេញផ្ទៃប្រទេស។ សន្តិភាព គឺជាបុរេល័ក្ខខ័ណ្ឌជាសកល និងជាបរិយាកាសចម្បងមិនអាចខ្វះបាន សម្រាប់ជានាដល់ដំណើរជីវិតជាប្រក្រតីនិងការរីកចម្រើនជឿនលឿនរបស់ប្រទេសជាតិក្នុងគ្រប់ផ្នែក,គ្រប់វិស័យ,រួមបញ្ចូលទាំងការផ្តល់ឱកាសដល់ការកែលម្អឬកែទម្រង់រចនាសម្ព័ន្ធនិងអភិបាលកិច្ចឱ្យកាន់តែប្រសើរឡើងថែមទៀតផងដែរដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

ច្បាស់ណាស់ថា, កន្លងមក, យើងមិនបានរង់ចាំទាល់តែទទួលបានសុខសន្តិភាពបរិបូរណ៍ពេញផ្ទៃប្រទេស ទើបចាប់ផ្តើមកិច្ចការកែទម្រង់នោះទេ។ ផ្ទុយទៅវិញ, ដោយតម្កល់ឧត្តមប្រយោជន៍ជាតិ និងប្រជាជន ជាធំ, យើងបានចាប់ផ្តើមធ្វើការកែទម្រង់លើគោលនយោបាយរបស់យើងជាបន្តបន្ទាប់ដោយផ្តោតលើអាទិភាពបន្ទាន់ទាំងឡាយស្របតាមបរិការណ៍និងកាលៈទេសៈនៃសម័យកាលនីមួយៗចាប់តាំងពីក្រោយការដួលរលំនៃរបបប្រល័យពូជសាសន៍មកម្ល៉េះ។ យ៉ាងណាមិញ, សុខសន្តិភាព, ស្ថិរភាពនយោបាយ និងឯកភាពជាតិពេញផ្ទៃប្រទេស, ដែលយើងសម្រេចបានមកដោយលំបាកបំផុត, បានផ្តល់ឱកាសឱ្យយើងអាចកែលម្អ និងស្ថាបនាបន្ថែមទៀត លើប្រព័ន្ធអភិបាលកិច្ចរបស់យើង តាមរយៈការរៀបចំការងារកែទម្រង់ជាប្រព័ន្ធ និងក្នុងលក្ខណៈជាកម្មវិធីរយៈពេលវែង ដែលមានការកំណត់ចក្ខុវិស័យវែងឆ្ងាយ, មានការបែងចែកជាដំណាក់កាល ប្រកបដោយភាពជាក់ស្តែងនិយម ជាមួយនឹងគោលដៅជាក់លាក់, ព្រមទាំងមានរចនាសម្ព័ន្ធដឹកនាំ និងមានយន្តការអនុវត្ត ច្បាស់លាស់។ យុទ្ធសាស្ត្រនេះ បានបង្ហាញអំពីសេចក្តីក្លាហាន, មហិច្ឆតា និងឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា លើការកែទម្រង់ ដោយតម្រូវទៅតាមបរិបទកម្ពុជា និងឆ្លើយតបបានតាមសេចក្តីត្រូវការរបស់កម្ពុជា ប្រកបដោយមោទនភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកលើសាវតារ និងទស្សនៈវិស័យនេះ, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញជាបន្តបន្ទាប់ នូវកម្មវិធីកែទម្រង់ក្នុងលក្ខណៈជាប្រព័ន្ធ ឬការកែទម្រង់រចនាសម្ព័ន្ធរយៈពេលវែង លើវិស័យសំខាន់ៗ សំដៅលើកកម្ពស់គុណភាពនៃប្រព័ន្ធអភិបាលកិច្ច ដែលរួមមានចំនួន ៤ គឺ ៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ជាមួយនឹងរចនាសម្ព័ន្ធដឹកនាំ, យន្តការអនុវត្ត និងផែនការសកម្មភាពលម្អិតច្បាស់លាស់, កម្មវិធីកែទម្រង់នីមួយៗ ទទួលបាននូវការសាទរ និងការគាំទ្រយ៉ាងសកម្ម ពីសំណាក់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា រួមបញ្ចូលនូវការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ជាបន្តបន្ទាប់, ក្នុងភាពជាដៃគូ, កិច្ចសហប្រតិបត្តិការ និងការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា។

**សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី** !

ឥឡូវនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលទី ៤, ដែលជាដំណាក់កាលចុងក្រោយរបស់ខ្លួន, បន្ទាប់ពីត្រូវបានអនុវត្តអស់រយៈពេលជិត ២០ ឆ្នាំ។ ខ្ញុំចាំបានថា ខ្ញុំផ្ទាល់បានធ្វើជាអធិបតី ក្នុងពិធីប្រកាសដាក់ចេញនូវដំណាក់កាលទី ១ នៃកម្មវិធីកែទម្រង់នេះ នៅក្នុងអំឡុងខែធ្នូ ឆ្នាំ២០០៤។ ជាមួយនឹងឆន្ទៈមុតស្លួចឥតរាថយ និងឥតងាករេ, រាជរដ្ឋាភិបាលកម្ពុជា បានជំរុញអនុវត្តកម្មវិធីកែទម្រង់ដ៏មានសារៈសំខាន់បំផុតមួយនេះ ឆ្លងកាត់ដំណាក់កាលធំៗ ចំនួន ៣ រួមមាន៖

- **ដំណាក់កាលទី ១** ត្រូវបានអនុវត្ត ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ ដែលមាន គោលដៅគន្លឹះ សំដៅលើ **ការបង្កើនភាពជឿទុកចិត្តនៃថវិកា**;
- **ដំណាក់កាលទី ២** ត្រូវបានអនុវត្ត ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដែលមានគោលដៅគន្លឹះ សំដៅលើ **ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**; និង
- **ដំណាក់កាលទី ៣** ត្រូវបានអនុវត្ត ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ ដែលមានគោលដៅគន្លឹះ សំដៅលើ **ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**។

**ដំណាក់កាលទី ៤** ដែលយើងកំពុងប្រកាសដាក់ឱ្យចាប់ផ្តើមអនុវត្តនាពេលនេះ ត្រូវបានគ្រោងចាប់អនុវត្ត ពីឆ្នាំ២០២៣ នេះ រហូតដល់ឆ្នាំ២០២៧ ដែលមានគោលដៅគន្លឹះសំដៅលើ **ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម**។

ជារួម, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលប្រមាណ ២០ ឆ្នាំ កន្លងទៅនេះ បានបង្កើតសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើននៅកម្ពុជា, ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទាំងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម សេដ្ឋកិច្ច របស់កម្ពុជា។ ជាការពិត, ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គម មានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយនឹងសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬថវិកាជាតិ ។ នៅឆ្នាំ ២០០៣, មុនការចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់នេះ, ចំណូលថវិកាជាតិសរុបមានប្រមាណតែ ១ ៨២១ ប៊ីលាន រៀលប៉ុណ្ណោះ; រីឯចំណាយថវិកាជាតិ មានប្រមាណ ២ ៩៩៤ ប៊ីលានរៀល។ រយៈពេល ២០ ឆ្នាំក្រោយ, ចំណូលថវិកាជាតិ ក្នុងឆ្នាំ ២០២៣ ត្រូវបានប៉ាន់ស្មានថា នឹងមានរហូតដល់ ៣២ ៩៣៦ ប៊ីលានរៀលឯណោះ, រីឯចំណាយថវិកាជាតិសរុប មានប្រមាណ ៤១ ៥៣៧ ប៊ីលានរៀល ។ សូចនាករសមិទ្ធកម្មដ៏ល្អប្រសើរនេះ គឺជាឃ្នាស់សេដ្ឋកិច្ចដ៏សំខាន់បំផុតមួយ ដែលធ្វើឱ្យកម្ពុជាទទួលបានកំណើន និងបន្តស្ថិរភាពនៃកំណើនសេដ្ឋកិច្ច ជាបន្តបន្ទាប់ រហូតដល់សម្រេចបាននូវចំណាត់ថ្នាក់ជា ប្រទេសមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០១៥ និងកំពុងបោះជំហានប្រកបដោយភាពជឿជាក់ ទៅកាន់ឋានៈជា ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។

សមិទ្ធកម្មដ៏ប្រសើរនេះក៏បានផ្តល់លទ្ធភាពកាន់តែខ្ពស់ជូនរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាលើកកម្ពស់ជីវភាព និងគុណភាពរបស់មន្ត្រីរាជការ, ពង្រឹងប្រសិទ្ធភាពស្ថាប័នសាធារណៈ, និងបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋបានកាន់តែល្អឡើង តាមរយៈអាទិភាពចំនួន ៤ នៅក្នុងយុទ្ធសាស្ត្រចតុកោណ គឺ : **មនុស្ស**, **ផ្លូវ**, **ទឹក និងភ្លើង** ដែលសំដៅដល់ការកសាង និងការអភិវឌ្ឍឥតឈប់ឈរ នូវហេដ្ឋារចនាសម្ព័ន្ធ, ទាំងរូបវន្ត និងមិនមែនរូបវន្ត, លើគ្រប់វិស័យ។ រីតតែសំខាន់ជាងនេះ, សមិទ្ធផលទាំងអស់នេះ គឺជាកត្តារួមចំណែកដ៏ធំធេង ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដែលមានការធ្លាក់ចុះជាលំដាប់។

លើសពីនេះ, សុខភាពដ៏ល្អប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាក៏បានធ្វើឱ្យរាជរដ្ឋាភិបាលមានថវិកាសន្សំគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាជាយថាហេតុទាំងឡាយ នាគ្រាកន្លងទៅ ជាអាទិ៍៖ ការឆ្លើយតបនឹងស្ថានភាពមិនអំណោយផល បង្កឡើងដោយវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ក៏ដូចជាការឆ្លើយតបនឹងគ្រោះមហន្តរាយ និងគ្រោះធម្មជាតិផ្សេងៗ ដែលមិនអាចស្មានទុកជាមុនបាន។ ជាក់ស្តែង, រាជរដ្ឋាភិបាលកម្ពុជា មានលទ្ធភាពគ្រប់គ្រាន់ខាងផ្នែកហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវវិបត្តិសុខុមាលភាព, សង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ រហូតកម្ពុជាត្រូវបានទទួលស្គាល់នៅក្នុងកម្រិតសកលលោកថា ជាប្រទេសគ្រប់គ្រងជំងឺកូវីដ-១៩ បានយ៉ាងល្អ និងជាប្រទេសស្ទុះងើបឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ បានយ៉ាងរហ័ស។












Join at
slido.com
#CAP-4



រឹតតែសំខាន់ថែមទៀត, ក្នុងបុព្វហេតុឯករាជ្យ និងអធិបតេយ្យជាតិ, សមិទ្ធកម្មដ៏ល្អនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានពង្រឹងឱ្យកាន់តែមាំមួនឡើងនូវភាពជាម្ចាស់និងតួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិដោយបានកាត់បន្ថយការពឹងពាក់លើការខ្ចីពីក្រៅប្រទេស ដែលបច្ចុប្បន្ន ការខ្ចីពីក្រៅប្រទេសប្រចាំឆ្នាំ មានទំហំមិនស្មើនឹង ២០ ភាគរយ នៃថវិកាជាតិសរុបនោះទេ។ ផ្ទុយទៅវិញ, នៅក្នុងអតីតកាល ៣០ ឆ្នាំមុន, ចំណូលក្នុងស្រុកដែលយើងរកបានដោយខ្លួនឯង មានត្រឹមប្រមាណមួយភាគបីនៃថវិកាជាតិសរុប តែប៉ុណ្ណោះ, បានន័យថា តម្រូវការប្រមាណពីរភាគបីនៃថវិកាជាតិ ត្រូវបានដោះស្រាយដោយប្រភពធនធានជាជំនួយហិរញ្ញវត្ថុពីក្រៅប្រទេស។ នេះ គឺជាលទ្ធផលជាក់ស្តែងដែលយើងសម្រេចបាន ស្របតាមគោលជំហរដឹកនាំ ដែលខ្ញុំបានប្រកាសជាសាធារណៈ នាពេលកន្លងទៅ គឺ៖ «កែ-ទម្រង់-រស់, មិនកែទម្រង់-ស្លាប់» ។ ទស្សនៈដឹកនាំនេះ, រួមជាមួយនឹងសមិទ្ធផលជាក់ស្តែងនៃកិច្ចការកែទម្រង់, បានធ្វើឱ្យក្តីរំពឹងទុកលើការកសាងប្រជាជាតិរបស់យើង ដែលត្រូវបានចារឹកទុកក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្លាយទៅជាការពិត នោះគឺ៖ «ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើងរីកចម្រើនលូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍» និងប្រែក្លាយកម្ពុជាឱ្យទៅជា «កោះសន្តិភាព» យ៉ាងពិតប្រាកដ។

សន្តិភាពនិងវិបុលភាពសង្គម, ដែលកំពុងតែផ្តល់មនុញ្ញផលដល់យើងទាំងអស់គ្នានាបច្ចុប្បន្ននេះ, បានធ្វើឱ្យយើងមានមោទនភាពជាតិយ៉ាងក្រៃលែង និងមានការជឿជាក់កាន់តែរឹងមាំថា «ខ្មែរពិតជាអាចធ្វើបាន» ។ ប៉ុន្តែ, ច្បាស់ណាស់ថា, យើងក៏មិនត្រូវស្កប់ស្កល់ ឬលង់លក់នៅក្នុងជោគជ័យបច្ចុប្បន្នដែរ។ ផ្ទុយទៅវិញ, យើងត្រូវប្រឹងប្រែងរៀនសូត្រ និងដកស្រង់ពិសោធន៍ពីការអនុវត្ត និងបណ្តាបញ្ហាប្រឈមនាពេលកន្លងទៅ ដើម្បីបោះជំហានទៅដំណាក់កាលថ្មីជាបន្តទៀត ជាមួយនឹងមហិច្ឆតាបែបប្រាកដនិយម និងមិនបង្អង់រង់ចាំ។ ប្រការនេះ មានន័យថា យើងត្រូវវាយតម្លៃឱ្យចំសកម្មភាពជាអាទិភាពដែលយើងត្រូវធ្វើជាបន្ទាន់ និងអាចធ្វើទៅបាន ដើម្បីឆ្លើយតបឱ្យចំសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងឱ្យសម្រេចបានលទ្ធផលកាន់តែប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់តាមការរំពឹងទុក ស្របពេលដែលយើងត្រូវមានការប្រុងប្រយ័ត្នខ្ពស់លើកត្តាបរិបទ និងកត្តាបរិស្ថានគ្របដណ្តប់ជារួមផងដែរ ដើម្បីធានានូវការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ឱ្យបានក្នុងកម្រិតជាអតិបរមា។

**សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

នៅក្នុងគោលដៅនៃ «ការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម» នេះដែលសំដៅទៅដល់ការទទួលខុសត្រូវផ្អែកលើលទ្ធផល, ការកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជាបានឈានចូលមកដល់ដំណាក់កាលយុទ្ធសាស្ត្រកម្រិតខ្ពស់ដែលជាគោលដៅដ៏ចម្បងរបស់យើង នោះគឺការប្រែប្រួលជាសារវន្តផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាព ដែលសំដៅដល់ការពង្រឹងប្រសិទ្ធភាព, គុណភាព និងការទទួលខុសត្រូវ លើលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និងមន្ត្រីរាជការក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ក្នុងន័យនេះ, សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ជាមួយនឹងការទទួលបាននូវការផ្ទេរសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួន, ក្រសួង ស្ថាប័ន នីមួយៗនឹងត្រូវមានការទទួលខុសត្រូវខ្ពស់ លើការប្រើប្រាស់ថវិកាឱ្យបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងចំគោលដៅកំណត់, ពោលគឺ, ម្ខាង, ត្រូវទទួលខុសត្រូវលើការសម្រេចឱ្យបាន នូវគោលបំណងគោលនយោបាយ, បេសកកម្ម និងសូចនាករលទ្ធផលរំពឹងទុករបស់ខ្លួន អនុលោមតាមគោលការណ៍នៃ «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»; និងម្ខាងទៀត, ត្រូវទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់លើការប្រើប្រាស់ថវិកាដែលត្រូវបានអនុម័តផ្តល់ជូន ឱ្យបានប្រកបដោយប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាព ព្រមទាំងធានាបាននូវ «តម្លៃនៃលុយ» ស្របតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាធរមាន។

ក្នុងស្មារតីបន្តជំរុញអនុវត្តដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់នេះឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក, ខ្ញុំសូមផ្តល់អនុសាសន៍គន្លឹះមួយចំនួនសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃគ្រប់ក្រសួងស្ថាប័នដែលជាតួអង្គនិម្មាបនករ និងប្រតិបត្តិករនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

**ទី១**. ត្រូវបង្កើនភាពជាម្ចាស់ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន ដោយរដ្ឋមន្ត្រី និងប្រធានស្ថាប័ន ត្រូវជំរុញការអនុវត្តប្រកបដោយភាពជាម្ចាស់ នូវកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅតាមគោលការណ៍រួមរបស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការសម្រេចបាន នូវគោលបំណង និងបេសកកម្មរបស់ក្រសួង ស្ថាប័ន ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ អាស្រ័យនេះ, គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវចាត់ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាការងារដែលត្រូវតាមដានការអនុវត្ត ជាប្រចាំ។ ការកែទម្រង់ ត្រូវផ្តើមចេញជាសំខាន់ពីការពង្រឹងភាពជាអ្នកដឹកនាំ និងការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ដោយផ្តោតទៅលើការសម្រេចនូវលទ្ធផល ស្របគ្នានឹងការពង្រឹងសមត្ថភាពធនធានមន្ត្រីរាជការនៅក្រោមឱវាទ។

**ទី២**. ត្រូវផ្តល់ការយកចិត្តទុកដាក់ខ្ពស់ ដល់ការត្រៀមរៀបចំគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យបាន នូវ «ការអនុវត្តជាមូលដ្ឋាន» នូវ ថវិកា

ព័ត៌មានសមិទ្ធកម្ម យ៉ាងយូរនៅឆ្នាំ២០២៦ ខាងមុខ ស្របតាមគោលដៅកំណត់នៃ «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ» របស់រាជរដ្ឋាភិបាល។ ច្បាស់ណាស់ថា ការកែទម្រង់ប្រព័ន្ធថវិកាជាតិ គឺជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសារ ថវិកា គឺជាឧបករណ៍គន្លឹះសម្រាប់រដ្ឋាភិបាលនៃប្រទេសនីមួយៗប្រើប្រាស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍប្រទេសជាតិ តាមរយៈការប្រមែប្រមូលធនធានរបស់ជាតិ ប្រកបដោយចីរភាព និងការវិភាជធនធានទាំងនោះ បម្រើឱ្យការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

**ទី៣.** ត្រូវបន្តពង្រឹងយន្តការសម្របសម្រួល,សង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់សំខាន់ៗទាំងឡាយរបស់រាជរដ្ឋាភិបាល, ពិសេស គឺកម្មវិធីកែទម្រង់ ៣ បូក ១ ស្របតាមឯកសារ «ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល» ដែលខ្ញុំបានសម្រេចដាក់ឱ្យអនុវត្ត នាពេលថ្មីៗកន្លងទៅ ។ អភិបាលកិច្ចល្អ ត្រូវការសមាសធាតុសំខាន់ទាំងបួន ដែលជាកម្មវត្ថុនៃកិច្ចការកែទម្រង់ ៣ បូក ១ នេះ ពោលគឺ៖ (១). ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព; (២). ធនធានមនុស្ស និងស្ថាប័នសាធារណៈ ប្រកបដោយគុណភាព, ភាពស្អាតស្អំ និងសមត្ថភាព; (៣). ការកំណត់បែងចែកមុខងារ ច្បាស់លាស់, ការធ្វើប្រតិភូកម្មអំណាច ត្រឹមត្រូវ និងការសម្របសម្រួលអនុវត្តមុខងារ ប្រកបដោយប្រសិទ្ធភាព; និង (៤). ប្រព័ន្ធច្បាប់ និងយុត្តិធម៌ ប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ, យើងពិតជាមានតម្រូវការចាំបាច់ ក្នុងការធានានូវសុខដុមភាព, សង្គតិភាព, ភាពប្រទាក់ក្រឡា និងការបំពេញគ្នាទៅវិញទៅមក នៃក្របខ័ណ្ឌកម្មវិធីកែទម្រង់ ៣ បូក ១ នេះ។

**ទី៤.** ត្រូវបន្តជំរុញឱ្យបានរីកចម្រើននូវវិស័យឌីជីថល ស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដោយបន្សី និងប្រទាក់ក្រឡាគ្នា ជាមួយនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាជាមួយកម្មវិធីកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

**ទី៥.** ត្រូវបន្តប្រកាន់ខ្ជាប់នូវ អភិក្រមការងារ «ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និងវះកាត់» ដែលជាអភិក្រមកែទម្រង់របស់មន្ត្រីរាជការ និងថ្នាក់ដឹកនាំនៅតាមក្រសួង ស្ថាប័ន ក្នុងគ្រប់កម្រិត, ទាំងកម្រិតបច្ចេកទេស, កម្រិតគ្រប់គ្រង និងកម្រិតដឹកនាំ, ក្នុងស្មារតីភ្ញាក់រលឹក,កែលម្អនិងបង្កើនប្រសិទ្ធភាពការងារ,ទាំងក្នុងក្របខ័ណ្ឌនៃការបំពេញការងារជាបុគ្គលក៏ដូចជាការបំពេញការងារជាក្រុម។

**ទី៦.** ត្រូវផ្តល់សារៈសំខាន់លើការពង្រឹង «ភាពជាអ្នកដឹកនាំ» នៅគ្រប់កម្រិត និងជាពិសេស «ក្នុងកម្រិតថ្នាក់ដឹកនាំ» នៅក្នុងស្ថាប័ន និងអង្គភាព ពីព្រោះនេះ គឺជាកត្តាចម្បងដែលកំណត់នូវភាពជោគជ័យនៃការងារ នៅក្នុងគ្រប់អង្គភាព និងក្រសួង ស្ថាប័ន, ទាំងសាធារណៈ និងឯកជន។

**ទី៧.** ត្រូវប្រកាន់យកគោលការណ៍ «គុណភាព, សមត្ថភាព និងគុណាធិបតេយ្យ» ជាវប្បធម៌ការងារ, ពិសេស នៅក្នុងការគ្រប់គ្រងធនធានមនុស្ស។ ប្រការនេះ សំដៅដល់ភាពចាំបាច់ក្នុងការផ្តល់នូវឱកាស និងការលើកទឹកចិត្ត, ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ, ប្រកបដោយសមធម៌ និងយុត្តិធម៌, ជូនដល់ មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ដោយផ្អែកលើគុណសម្បត្តិ ស្របតាមគុណវុឌ្ឍិ, បទពិសោធន៍, សមត្ថភាព, ឆន្ទៈ និងវិន័យ ក្នុងការបំពេញការងារ។ គោលការណ៍នេះ ត្រូវអនុវត្តមិនត្រឹមតែក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេប៉ុន្តែវាត្រូវតែក្លាយទៅជាគោលការណ៍អាទិភាពមួយរបស់រាជរដ្ឋាភិបាលសម្រាប់ពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន នៅគ្រប់កម្រិត។

**ទី៨.** ត្រូវពង្រឹងយន្តការ «តាមដាន, ត្រួតពិនិត្យ និងវាយតម្លៃ» នៅគ្រប់កម្រិត និងឱ្យបានទូលំទូលាយ, ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ជាឧបករណ៍ដើម្បីកំណត់ចំណុចខ្លាំង,ចំណុចខ្សោយ,បញ្ហាប្រឈមនិងកាលានុវត្តភាពនៃរាល់ការអនុវត្តផែនការសកម្មភាពការងារ។ម្យ៉ាងទៀត,យន្តការនេះក៏ជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ចូលរួមពង្រឹង«គណនេយ្យភាពសមិទ្ធកម្ម»ផងដែរ។

**សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ខ្ញុំពិតជាមានមោទនភាពខ្ពស់ចំពោះការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅដែលតាមរយៈនេះយើងអាចកសាងមូលដ្ឋានគ្រឹះតាមដំណាក់កាលនីមួយៗនិងអាចឈានមកដល់ដំណាក់កាលចុងក្រោយនេះបាន ដោយជោគជ័យយ៉ាងប្រចក្ស។

ជាការពិត,លទ្ធផល,សមិទ្ធផលនិងវឌ្ឍនភាពដែលសម្រេចបានមកដល់ពេលនេះពិតជាមិនអាចកាត់ផ្តាច់បានឡើយពីការចូលរួមចំណែករបស់គ្រប់ក្រសួង ស្ថាប័នទាំងអស់ក្នុងជួររាជរដ្ឋាភិបាល, ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ ក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំសូមយក ឱកាសនេះ សម្តែងនូវការវាយតម្លៃខ្ពស់ ជូនដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីឆ្នាំ២០០៤ មក, ជាពិសេស ថ្នាក់ដឹកនាំ និងមន្ត្រីទាំងឡាយ ដែលជាប់ពាក់ព័ន្ធតាំងពីដំបូង រហូតមកដល់បច្ចុប្បន្ន។

ជាមួយគ្នានេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានដឹកនាំផ្ទាល់ និងជាប់លាប់ តាំងពីដើមទី លើការងារនេះ ប្រកបដោយភាពជាអ្នកដឹកនាំ និងវិជ្ជាជីវៈខ្ពស់។ ខ្ញុំក៏សូមកោតសរសើរដោយស្មោះ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាគ្រប់ក្រសួង ស្ថាប័នដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់នេះប្រកបដោយភាពអត់ធ្មត់ និងភាពជាម្ចាស់។បន្ថែមលើនេះ,ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្តាដៃគូអភិវឌ្ឍន៍ទាំងឡាយដែលតែងតែបានគាំទ្រ,ទាំងជាជំនួយបច្ចេកទេស និងទាំងជាជំនួយហិរញ្ញវត្ថុ,ជាបន្តបន្ទាប់,តាំងពីដំណាក់កាលទី ១ រហូតមកដល់ដំណាក់កាលទី ៤ ដែលជាដំណាក់កាលចុងក្រោយនេះ។

ជាទីបញ្ចប់, ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមផ្តាំផ្ញើ និងជំរុញ, ជាថ្មីម្តងទៀត, ឱ្យគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ បន្តសកម្មចូលរួមអនុវត្ត តាមបេសកកម្ម, មុខងារ, កម្មវិធីការងារ និងគណនេយ្យភាពរបស់ខ្លួន ប្រកបដោយភាពជាម្ចាស់ និងឆន្ទៈកែទម្រង់មោះមុត នៅក្នុងកម្មវិធីកែទម្រង់នេះ ដូចត្រូវបានកំណត់នៅក្នុងឯកសារ «ចក្ខុវិស័យ និងយុទ្ធសាស្ត្រ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤» ។ ខ្ញុំសង្ឃឹមថា ដំណាក់កាលទី ៤ នឹងត្រូវបានអនុវត្តប្រកបដោយជោគជ័យ ជាមួយនឹងការដកស្រង់នូវមេរៀន និងពិសោធន៍ល្អៗ ព្រមទាំងការតាមដាន, ការត្រួតពិនិត្យ និងការវាយតម្លៃ ជាបន្តបន្ទាប់ ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម និងជម្នះនូវឧបសគ្គផងទាំងពួង ប្រកបដោយស្មារតីសាមគ្គី, កិច្ចសហការ និងការសម្របសម្រួលខ្ពស់ ក្នុងគោលបំណងសម្រេចឱ្យបាន នូវចក្ខុវិស័យ **កសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យឆ្លើយតបទៅតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ។**

ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវ **ដំណាក់កាលទី ៤ ៖ «ការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ចាប់ពីពេលនេះតទៅ៕

***សូមអរគុណ !***

# សុន្ទរកថា
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
## ថ្លែងក្នុងពិធីបិទ
## ការប្រកាសដាក់ឱ្យអនុវត្ត
## ដំណាក់កាលទី ៤ ឆ្នាំ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម"
## នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃចន្ទ ១៤ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

- ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល;
- លោកស្រី Jyotsana VARMA នាយិកាស្ថានតំណាងអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិ, ជាទីមេត្រី !

ខ្ញុំពិតមានសេចក្តីរីករាយជាអនេក ដោយបានចូលរួមក្នុងពិធីបិទ ការប្រកាសដាក់ឱ្យអនុវត្ត ដំណាក់កាលទី ៤ (ឆ្នាំ២០២៣-២០២៧)៖ «គណនេយ្យភាពសមិទ្ធកម្ម» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាពេលនេះ។ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំសូមគាំទ្រពេញទំហឹង និងប្តេជ្ញាគោរពអនុវត្តតាមអនុសាសន៍ទាំង ៨ ចំណុច, ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ, ពុទ្ធិមុតស្រួច, និងភាពឈ្លាសវៃ, ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែល សម្តេច បានដាក់ចេញ នៅក្នុងពិធីបើកកម្មវិធីរបស់យើង កាលពីព្រឹកមិញនេះ។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមក្នុងការដឹកនាំ និងការអនុវត្ត ការងារកែទម្រង់ ប្រកបដោយស្មារតីសហការល្អ, ការទទួលខុសត្រូវខ្ពស់, និងបានធ្វើឱ្យការងារកែទម្រង់ដ៏លំបាកនេះ ទទួលបាននូវផលផ្លែផ្កាជាវិជ្ជមាន និងជាឧត្តមប្រយោជន៍ដល់ប្រទេសជាតិទាំងមូល។ ច្បាស់ណាស់ថាសមិទ្ធផលដ៏ត្រចះត្រចង់ ដែលទទួលបានជាបន្តបន្ទាប់ ក្នុងការកសាងខឿន ទី ១, ទី ២ និង ទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាមិនអាចកាត់ផ្តាច់បានពីការគាំទ្រ, ទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកជំនួយបច្ចេកទេស, ពីសំណាក់ដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានឡើយ។ ជាមួយនឹងការថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការគាំទ្រកន្លងមក, ខ្ញុំក៏ដាក់ក្តីរំពឹងខ្ពស់ចំពោះការបន្តផ្តល់កិច្ចសហប្រតិបត្តិការជិតស្និទ្ធដល់រាជរដ្ឋាភិបាលកម្ពុជាពីសំណាក់ដៃគូអភិវឌ្ឍន៍របស់យើងលើការជំរុញអនុវត្តដំណាក់ចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពោលគឺ ដំណាក់កាលទី ៤ ៖ «គណនេយ្យភាពសមិទ្ធិកម្ម» នេះ។



**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ, ការតាមដាន និងការវាយតម្លៃ លើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ កន្លងទៅ, ទាំងក្នុងកម្រិតស្ថាប័នរដ្ឋាភិបាល និងក្នុងកម្រិតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍, ដោយប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ឬហៅកាត់ថា PEFA) និងឧបករណ៍ពិនិត្យឡើងវិញលើចំណាយសាធារណៈ(ឬហៅកាត់ថាPER)ព្រមទាំងតាមរយៈការត្រួតពិនិត្យលើការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS),យើងអាចសន្និដ្ឋានជារួមបានថាៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាន និងកំពុងស្ថិតលើមាគ៌ា និងទិសដៅត្រឹមត្រូវ លើមូលដ្ឋាននៃអភិក្រមអនុវត្ត ដែលមានភាពប្រាកដនិយម ស្របតាមបរិបទកម្ពុជា, ព្រមទាំងបានផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់ នៅតាមដំណាក់កាលនីមួយៗ។ ជាមួយនឹងវឌ្ឍនភាពដ៏ប្រសើរទាំងអស់នេះ, ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាត្រូវបានពង្រឹងជាបន្តបន្ទាប់ពោលគឺៈកាន់តែមានភាពជឿទុកចិត្ត,ទាំងក្នុងទិដ្ឋភាពនៃការកៀរគរចំណូលក៏ដូចជាក្នុងការគ្រប់គ្រងចំណាយថវិកា និងបំណុលសាធារណៈ; មានបុរេលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធានានូវគណនេយ្យភាពហិរញ្ញវត្ថុ; មានក្របខ័ណ្ឌថវិកាកម្មវិធីកាន់តែច្បាស់លាស់ ជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅទ្រទ្រង់ និងជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច, ជាពិសេស សម្រាប់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ; និងរឹតតែសំខាន់ថែមទៀត, មានមន្ត្រីដែលកាន់តែមានសមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដែលមានការយល់ដឹងកាន់តែខ្ពស់ឡើង សម្រាប់ចូលរួមអនុវត្តកម្មវិធីកែទម្រង់ ដើម្បីកសាងមូលដ្ឋានឆ្ពោះទៅកាន់ «គណនេយ្យភាពសមិទ្ធកម្ម» ដែលសំដៅដល់ការពង្រឹងប្រសិទ្ធភាព, គុណភាព និងការទទួលខុសត្រូវលើលទ្ធផលរបស់ស្ថាប័នសាធារណៈ និងមន្ត្រីរាជការ នៅក្នុងការប្រើប្រាស់ធនធានថវិការបស់ជាតិ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ដូចខ្ញុំធ្លាប់បានគូសបញ្ជាក់ជារឿយៗថា ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនមែនជាការងារដាច់ដោយឡែករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុណ្ណោះទេ, ប៉ុន្តែ ជាការងារដែលទាមទារឱ្យមានការចូលរួមពីសំណាក់គ្រប់ក្រសួង ស្ថាប័ន, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងស្មារតីនេះ, ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ក្រសួង ស្ថាប័ន ខិតខំកែលម្អផែនការយុទ្ធសាស្ត្រថវិកា, ពង្រឹងគុណភាពថវិកាកម្មវិធី, សកម្មចូលរួមក្នុងការអនុវត្ត FMIS, ព្រមទាំងលើកកម្ពស់ការពង្រឹងគណនេយ្យភាព និងតម្លាភាពនៃការអនុវត្តថវិការបស់ខ្លួន ជាមួយនឹងការប្រឹងប្រែងពង្រឹងថែមទៀត នូវភាពជាអ្នកដឹកនាំក្នុងកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័នរបស់ខ្លួន។ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ, ខ្ញុំសូមលើកទឹកចិត្តឱ្យបន្តពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី, ពង្រឹងប្រសិទ្ធភាពនៃការវិភាជន៍ថវិកា និងពង្រឹងគណនេយ្យភាពថវិកាបន្ថែមទៀត។ ជាមួយគ្នានេះ, រដ្ឋបាលរាជធានីខេត្តត្រូវត្រៀមខ្លួនចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំពុងរៀបចំធ្វើការសិក្សារួមគ្នា ហើយគ្រោងនឹងបញ្ចប់របាយការណ៍ សម្រាប់ដាក់ឱ្យអនុវត្ត នៅដើមឆ្នាំ២០២៤ ខាងមុខ។

បន្ថែមលើនេះ, ខ្ញុំសូមទាក់ទាញការយកចិត្តទុកដាក់របស់ក្រសួង ស្ថាប័ន, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់, លើសកម្មភាពជាក់ស្តែងមួយចំនួន ដែលជាអាទិភាពខ្ពស់ នៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ដូចតទៅៈ

ទី១). បន្តលើកកម្ពស់សមត្ថភាពស្ថាប័ន, ភាពជាអ្នកដឹកនាំ និងប្រសិទ្ធភាពនៃការគ្រប់គ្រង, ភាពជាម្ចាស់ និងឆន្ទៈ របស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ទាំងនៅតាមក្រសួង ស្ថាប័ន និងនៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ, ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំកិច្ចប្រជុំតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់របស់ខ្លួន ជាប្រចាំខែ និងរៀបចំរបាយការណ៍វឌ្ឍនភាព ប្រចាំត្រីមាស និងប្រចាំឆ្នាំ ឱ្យបានទាន់ពេល។

ទី២). បន្តជំរុញការអនុវត្ត និងការតាមដានលើការអនុវត្តផែនការសកម្មភាពលម្អិតសម្រាប់ «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥»; យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»; «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ឆ្នាំ២០១៩-២០២៥»; «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥»; «ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមFMIS»; និង«យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដារគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ឆ្នាំ២០២១-២០៣១» ដើម្បីឱ្យសម្រេចបានតាមគោលដៅដែលបានដាក់ចេញ ស្របតាមក្របខ័ណ្ឌពេលកំណត់ ប្រកបដោយ

ជោគជ័យ និងចីរភាព។

ទី៣).បន្តយកចិត្តទុកដាក់រៀបចំ និងកែលម្អគោលនយោបាយកៀរគរចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ស្របតាមបរិបទសង្គមសេដ្ឋកិច្ចកម្ពុជាព្រមទាំងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីសារពើពន្ធ;ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ; និងច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ; ឱ្យបានចប់សព្វគ្រប់ ដើម្បីមានមូលដ្ឋានគតិយុត្តពេញលេញ និងគ្រប់ជ្រុងជ្រោយ សម្រាប់ជានាការអនុវត្តច្បាប់ទាំងនេះ ប្រកបដោយប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាព។

ទី៤).ជំរុញការរៀបចំនូវលិខិតបទដ្ឋានពាក់ព័ន្ធ សម្រាប់ជានាដល់ការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (បន្ទាប់ពីសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈនេះ ទទួលបានការអនុម័ត និងត្រូវបានប្រកាសដាក់ឱ្យអនុវត្ត តាមនីតិវិធីជាធរមាន)។

ទី៥).សហការជិតស្និទ្ធជាក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជំរុញការរៀបចំបញ្ចប់នូវវិសោធនកម្មច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣។

ទី៦). ជំរុញការធ្វើស្វ័យប្រវត្តិកម្មពេញលេញនៃការអនុវត្តថវិកាតាមFMISនិងធានាប្រសិទ្ធភាពនៃការប្រើប្រាស់FMISឱ្យបានប្រសើរបំផុត។

ទី៧).បន្តជំរុញការពិនិត្យ និងការកែលម្អនីតិវិធីអនុវត្តថវិកា, ទាំងក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទាំងក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នជំនាញ, ដើម្បីឈានទៅ «អនុវត្តជាមូលដ្ឋាន» នូវ ថវិកាព័ត៌មានសមិទ្ធកម្ម ចាប់ពី២០២៦ តទៅ។

ទី៨).ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នជំនាញ ត្រូវបន្តបង្កើនការយកចិត្តទុកដាក់ លើការកែលម្អគុណភាព, ខ្លឹមសារ និងរចនាសម្ព័ន្ធកម្មវិធី, ក៏ដូចជារចនាសម្ព័ន្ធរដ្ឋបាល; ព្រមទាំងការកំណត់បន្ទាត់គណនេយ្យភាព ឱ្យច្បាស់លាស់ តាមកម្រិតនីមួយៗ នៃរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធរដ្ឋបាល។

ទី៩).ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នជំនាញ ត្រូវបន្តបង្កើនកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជិតស្និទ្ធ ដើម្បីកំណត់ និងជំរុញអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។ជាមួយគ្នានេះ,ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា, គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព នៃការរៀបចំ និងការបង្កើតអង្គភាពថវិកា ដោយត្រូវធ្វើការត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកានិងការកែសម្រួលរចនាសម្ព័ន្ធស្ថាប័នដោយផ្សារភ្ជាប់ជាមួយនឹងផែនការកសាងសមត្ថភាពផងដែរ។

ទី១០).ជំរុញការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឱ្យមានប្រសិទ្ធភាព តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្ត ដែលក្នុងនោះថ្នាក់ដឹកនាំឬថ្នាក់គ្រប់គ្រងត្រូវមានតួនាទីទទួលខុសត្រូវចំពោះសមិទ្ធកម្មឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត,ចំណែកការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័នសាមី, មុខងារសវនកម្មផ្ទៃក្នុង និងមុខងារអធិការកិច្ចហិរញ្ញវត្ថុ។

ទី១១).បន្តជំរុញរៀបចំ និងអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នជំនាញ។ ក្នុងកិច្ចការនេះ, អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តគាំទ្រ និងបណ្តុះបណ្តាលបន្ថែម លើការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម ព្រមទាំងធ្វើការតាមដាន និងវាយតម្លៃ ជាប្រចាំ លើការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម។

ទី១២).អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវជំរុញរៀបចំបញ្ចប់គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលនិងរបស់ក្រសួងស្ថាប័ននិងក្របខ័ណ្ឌរួមផែនទីបង្ហាញផ្លូវនិងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ (Expenditure Arrears) ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៅក្នុងការគ្រប់គ្រង និងការអនុវត្តចំណាយថវិកា។

ទី១៣).បន្តយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ទាំងផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទាំងនៅតាមក្រសួង ស្ថាប័ន និងទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ដើម្បីទ្រទ្រង់ដល់ការងារកែទម្រង់ផង និងដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តកិច្ចការប្រចាំថ្ងៃផង។

ទី១៤).បន្តយកចិត្តទុកដាក់ឱ្យបានកាន់តែខ្លាំងក្លាថែមទៀតលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមរយៈការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (ឬហៅកាត់ថា SARMIS) និងការរៀបចំបញ្ចប់ផែនការគោលសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ទី១៥).បន្តលើកកម្ពស់តម្លាភាពថវិកា ដូចមានកំណត់នៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ២០២៣ ដែលទើបត្រូវបានប្រកាសដាក់ឱ្យអនុវត្ត។ ជាការចាប់ផ្តើម, ក្រសួងធនធានទឹក និងឧតុនិយម; ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍; ក្រសួងអប់រំយុវជននិងកីឡា; និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា; ត្រូវមានភារកិច្ចរៀបចំវេទិកាសាធារណៈអំពីការរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ និងការរៀបចំសៀវភៅថវិកាពលរដ្ឋ ស្របតាមការណែនាំដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ជូននាពេលថ្មីៗ កន្លងទៅ។

ទី១៦).បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ លើគំនិតផ្តួចផ្តើមមួយចំនួន នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមគោលការណ៍បៃតង, ការបញ្ជ្រាបយេនឌ័រក្នុងថវិកា, និងការធ្វើពិពិធកម្មបំណុលសាធារណៈ, ពិសេស តាមរយៈការអភិវឌ្ឍមូលបត្ររដ្ឋ។

ទី១៧).ជំរុញអនុវត្តផែនការសកម្មភាពលម្អិត និងយន្តការត្រួតពិនិត្យនិងតាមដាន សម្រាប់ការអនុវត្តឯកសារ «ចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១» រួមមាន៖ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ; កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ; កម្មវិធីជាតិសម្រាប់ការកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី** !

ភ្ជាប់ជាមួយអនុសាសន៍តម្រង់ទិសខាងលើ, ក្នុងនាមស្ថាប័ននិម្មាបនករ, ខ្ញុំក៏សូមណែនាំដល់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធ្វើការសិក្សា និងរៀបចំក្របខ័ណ្ឌវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន (Public Financial Management Assessment Framework; PFMAF) ដើម្បីបម្រើឱ្យគោលបំណង ២ យ៉ាង ដូចខាងក្រោម៖

ទី១-ដើម្បីគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចកំណត់បាន នូវភាពខ្លាំង និងភាពខ្សោយ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន សម្រាប់ជាមូលដ្ឋាននៃការតម្រង់ទិស និងការដាក់ចេញនូវវិធានការកែលម្អចាំបាច់នានា ជាបន្តទៀត នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម; និង

ទី២-ដើម្បីក្រសួង ស្ថាប័ន ដែលជាស្ថាប័នអនុវត្តថវិកា អាចទទួលបាននូវការយល់ដឹងជាក់លាក់អំពី៖ (១).ស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័នសាមី; និង (២).លំដាប់អាទិភាព និងភាពប្រទាក់ក្រឡាគ្នា នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន (MAP) ជាមួយនឹងក្របខ័ណ្ឌនៃផែនការសកម្មភាពរួមដំណាក់កាលទី ៤ (CAP4) និងទិសដៅជាក់ស្តែងនៃការកសាងប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម នៅតាមក្រសួង ស្ថាប័នរបស់ខ្លួន។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការងារកែទម្រង់ និងសូមលើកទឹកចិត្ត ឱ្យការចូលរួមនេះ មានភាពជាប់មិនដាច់ និងកាន់តែសកម្មខ្លាំងឡើង ពីមួយឆ្នាំទៅមួយឆ្នាំ។

ខ្ញុំក៏សូមអរគុណជាថ្មីម្តងទៀត ចំពោះបណ្តាដៃគូអភិវឌ្ឍន៍ ដែលបានផ្តល់ការគាំទ្រចាំបាច់, ទាំងជាហិរញ្ញប្បទាន និងជាជំនួយបច្ចេកទេស, ប្រកបដោយសុឆន្ទៈ និងជានិច្ចកាល តែងតែបានលើកតម្កើង និងគោរពភាពជាម្ចាស់របស់កម្ពុជា។ ខ្ញុំដាក់ការរំពឹងខ្ពស់ លើការបន្តនូវកិច្ចសហការ និងកិច្ចសហប្រតិបត្តិការ ប្រកបដោយផ្លែផ្កានេះ កាន់តែសកម្មឡើងថែមទៀតនៅក្នុង ដំណាក់កាលទី ៤ ដ៏សារៈសំខាន់ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា។

ខ្ញុំក៏សូមយកឱកាសនេះ សម្តែងនូវការវាយតម្លៃខ្ពស់ ជូនដល់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំពោះកិច្ចប្រឹងប្រែង និងការលះបង់គ្រប់បែបយ៉ាង ក្នុងការសម្របសម្រួល និងការជំរុញការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងសូមលើកទឹកចិត្តឱ្យបង្កើនការប្រឹងប្រែងកាន់តែខ្លាំងឡើងថែមទៀត ដើម្បីជាឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនយើង។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, បានសមប្រកបនឹងពុទ្ធពរ និងពរ ទាំង ៥ ប្រការ គឺ ៖ អាយុ, វណ្ណៈ, សុខៈ, ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទ ពិធីប្រកាសដាក់ឱ្យអនុវត្ត ដំណាក់កាលទី៤(ឆ្នាំ២០២៣-២០២៧)៖«គណនេយ្យភាពសមិទ្ធកម្ម»នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាពេលនេះ៕

**សូមអរគុណ**!

រៀបចំអត្ថបទដោយ៖ ផ្នែកការងារកែទម្រង់ទាំងបី គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ អ.គ.ហ.





# ផ្នែកទី ៤

# ទស្សនៈ និង មតិ



# ថ្លែងក្នុងពិធីប្រកាស ដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម”

*សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣*

“

យើងមិនរង់ចាំទាល់តែមានសន្តិភាពពេញលេញទើបយើងធ្វើការកែទម្រង់នោះទេ និងមកដល់ពេលនេះយើងមានប្រព័ន្ធហិរញ្ញវត្ថុដែលចូលដល់ដំណាក់កាលទី៤ដែលឥលូវនេះយើងកំពុងតែនៅបន្តអនុវត្តនូវថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ និងចាប់ពីថ្ងៃនេះទៅយើងនឹងមានការផ្លាស់ប្តូរទៅកាន់ដំណាក់កាលទី៤។អញ្ចឹងខ្ញុំគួរតែយកឱកាសនេះបញ្ជាក់ថាមិនមែនជាបញ្ហាលេងសើចនោះទេ ហើយក៏មិនមែនជាការឃោសនាខាងនយោបាយលើក្រដាស់និងដេញថ្លៃក្នុងរយៈពេលនៃការបោះឆ្នោតនោះដែរ។ប៉ុន្តែយើងបានឆ្លងកាត់នូវការធ្វើរឿងនេះតាំងពីចាប់ផ្តើមនៅពេលលំបាកបំផុតយើងអត់រង់ចាំដល់ទៅមានជំនួយសហភាពអឺរ៉ុប យើងអត់រង់ចាំរហូតដល់មានធនាគារពិភពលោក ឬ IMF ឬធនាគារអភិវឌ្ឍន៍អាស៊ីទេ យើងធ្វើកែទម្រង់តាំងពីយើងនៅជាប់ទណ្ឌកម្ម។

”





# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងកម្មវិធីបិទពិធីប្រកាសដាក់ឱ្យប្រើ ជាផ្លូវការនូវចក្ខុវិស័យ និងយុទ្ធសាស្ត្រ ស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល”

*សណ្ឋាគារសូហ្វីថែលភ្នំពេញ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២*

“ រាជរដ្ឋាភិបាលបានកំណត់យក “អភិបាលកិច្ចល្អ” ធ្វើជាស្នូលនៃគោលនយោបាយជាតិដែលបានដាក់ចេញជាបន្តបន្ទាប់ រួមមាន យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ១ រហូតដល់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ។ កម្មវិធីកំណែទម្រង់ទាំង ៤ រួមមាន កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវតម្កល់ឆន្ទៈក្នុងការរៀបចំនិងអនុវត្តកំណែទម្រង់ទាំងនេះប្រកបដោយការយកចិត្តទុកដាក់និងការទទួលខុសត្រូវខ្ពស់សម្រាប់រយៈពេលវែង។ ”



**សម្តេចក្រឡាហោម ស ខេង**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ

## ថ្លែងក្នុងកម្មវិធីបើកពិធីប្រកាសដាក់ឱ្យប្រើ ជាផ្លូវការនូវចក្ខុវិស័យ និងយុទ្ធសាស្ត្រ ស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល”

*សណ្ឋាគារសូហ្វីថែលភ្នំពេញ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២*

“ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តចាត់ទុកការកែទម្រង់ជាអាទិភាពគោលនយោបាយរបស់ខ្លួនដែលឆ្លុះបញ្ចាំងតាមរយៈការកំណត់ថា “ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច” ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤។ បន្ថែមពីនេះ នៅក្នុងបរិបទសកលលោកនាពេលបច្ចុប្បន្នការកែទម្រង់ផ្នែកអភិបាលកិច្ចមានសារៈសំខាន់ជាងពេលណាៗទាំងអស់ព្រោះត្រូវពង្រឹងសមត្ថភាពនិងភាពរឹងមាំរបស់ស្ថាប័នសាធារណៈក្នុងការឆ្លើយតបដោយវិធានការបង្ការជាបុរេសកម្ម បានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពចំពោះវិបត្តិជាច្រើនដែលអាចកើតឡើងដោយមិនអាចស្មានទុកបាន ដែលកាន់តែពិបាកដោះស្រាយ និងមានលក្ខណៈកាន់តែស្រួចស្រាល់ខ្លាំងឡើង។ ”



**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ថ្លែងក្នុងកម្មវិធីបើកសិក្ខាសាលាពិគ្រោះយោបល់លើចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១របស់រាជរដ្ឋាភិបាល”

*សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២*

“ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល” នេះ គឺជាសក្ខីភាពនៃការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតម្កល់ការងារកែទម្រង់ជាការងារអាទិភាពខ្ពស់បំផុតតាមទិសស្លោក“កែទម្រង់រស់មិនកែទម្រង់ស្លាប់”ដោយរាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែដាក់ចេញនូវកម្មវិធីកែទម្រង់ជាប្រព័ន្ធតាមការដ្ឋានក្នុងវិស័យនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែរាជរដ្ឋាភិបាល ផ្តោតការយកចិត្តទុកដាក់ និងអាទិភាពខ្ពស់លើការធានាបាននូវ“សង្គតិភាពនិងសុខដុមភាព”រវាងកម្មវិធីកែទម្រង់ទាំងនេះ សំដៅជំរុញ “ល្បឿននៃកំណែទម្រង់អភិបាលកិច្ចល្អ” ឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិខ្ពស់ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤។”



**ឯកឧត្តម កើត រិទ្ធ**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

រៀបចំអត្ថបទដោយ៖ ផ្នែកការងារកែទម្រង់ទាំងបី គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ អ.គ.ហ.

## ថ្លែងក្នុងកម្មវិធីបិទសិក្ខាសាលាពិគ្រោះយោបល់លើចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី “សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល”

*សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២*

“ អនុលោមតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ក្នុងក្របខណ្ឌនៃការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច រាជរដ្ឋាភិបាលបានកំណត់គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្នសមធម៌និងយុត្តិធម៌តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំគ្រប់គ្រង និងចាត់ចែងកិច្ចការប្រទេសជាតិ ពិសេសជានានិរន្តរភាពនៃតួនាទី និងដំណើរការ រដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល និងការកសាងជាតិ។ ”



**ឯកឧត្តម យក់ ប៊ុនណា**

រដ្ឋលេខាធិការប្រចាំការ ក្រសួងមុខងារសាធារណៈ

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង៖

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ អ.គ.ហ. |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង អ.គ.ហ. |
| មាស សុខសេនសាន | អគ្គលេខាធិការរង អ.គ.ហ. |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង អ.គ.ហ. |
| យ៉េត វីណែល | អគ្គលេខាធិការរង អ.គ.ហ. |
| អ៊ុង លុយណា | អគ្គលេខាធិការរង អ.គ.ហ. |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង អ.គ.ហ. |

# រៀបចំអត្ថបទដោយ៖

| | | |
|---|---|---|
| ផ្នែកការងារកែទម្រង់ទាំងបី គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ | លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| | វុទ្ធី សត្រា | មន្ត្រីជំនាញ |
| | ស៊ុន គឹមហេង | មន្ត្រីជំនាញ |
| | ឆាយ សម្បត្តិ | មន្ត្រីជំនាញ |
| ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ | គង់ ឆោមកែវរលក្ខណ៍ | មន្ត្រីជំនាញជាន់ខ្ពស់ |
| | គុណ មុនីរ័ត្នភួង | មន្ត្រីជំនាញ |
| | ចាន់ ផាន់ណា | មន្ត្រីជំនាញ |
| | ធន សិទ្ធិកា | មន្ត្រីជំនាញ |
| ផ្នែកអនុវត្តថវិកា | ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| | ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| | លឹម សុខហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| | រិទ្ធ រតនៈ | មន្ត្រីជំនាញ |
| ផ្នែកចំណូលសារពើពន្ធ | រស់ ដាលីន | មន្ត្រីជំនាញជាន់ខ្ពស់ |
| | ជា សុខផេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ផ្នែកគោលនយោបាយ និងរៀបចំថវិកា | ម៉េត រ៉ាម៉ន | មន្ត្រីជំនាញជាន់ខ្ពស់ |
| | ផេង សុខម៉ែ | មន្ត្រីជំនាញជាន់ខ្ពស់ |
| | អ៊ូ ចិន្តា | មន្ត្រីជំនាញ |
| ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ | អ៊ុំ យុទ្ធី | នាយករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ |
| | អ៊ូច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| | ឈុន ម៉ារឌី | មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| | អ៊ុង វលក្ខទេវី | មន្ត្រីជំនាញផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| | ឡេង ចាន់ភួង | មន្ត្រីជំនាញផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| | សុគន្ធ វិរៈស័ក | មន្ត្រីជំនួយការផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ៖

អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន

លោក ហួរ ឆាយ, អតីតនិស្សិតអាហារូបករណ៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃសាលាគោលនយោបាយលីក្វាន់យូនៃប្រទេសសិង្ហបុរី ឆ្នាំសិក្សា២០២១-២០២៣

# នវានុវត្តន៍ និងកែសម្រួលដោយ៖

| | | |
|---|---|---|
| ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ | គង់ ឆោមកែវរលក្ខណ៍ | មន្ត្រីជំនាញជាន់ខ្ពស់ |
| | គុណ មុនីរ័ត្នភួង | មន្ត្រីជំនាញ |
| | ចាន់ ផាន់ណា | មន្ត្រីជំនាញ |
| | ធន សិទ្ធិកា | មន្ត្រីជំនាញ |

# ១

## មករា ២០២៣

បុស្ស-មាឃ ឆ្នាំខាល

ព.ស. ២៥៦៦

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ១ ១០ កើត | ២ ១១ កើត | ៣ ១២ កើត | ៤ ១៣ កើត | ៥ ១៤ កើត ថ្ងៃកោរ | ៦ ១៥ កើត ពេញបូណ៌មី | ៧ ១ រោច |
| ៨ ២ រោច | ៩ ៣ រោច | ១០ ៤ រោច | ១១ ៥ រោច | ១២ ៦ រោច | ១៣ ៧ រោច | ១៤ ៨ រោច |
| ១៥ ៩ រោច | ១៦ ១០ រោច | ១៧ ១១ រោច | ១៨ ១២ រោច | ១៩ ១៣ រោច | ២០ ១៤ រោច ថ្ងៃកោរ | ២១ ១៥ រោច |
| ២២ មាឃ | ២៣ ២ កើត | ២៤ ៣ កើត | ២៥ ៤ កើត | ២៦ ៥ កើត | ២៧ ៦ កើត | ២៨ ៧ កើត |
| ២៩ ៨ កើត | ៣០ ៩ កើត | ៣១ ១០ កើត | ១ ១១ កើត | ២ ១២ កើត | ៣ ១៣ កើត | ៤ ១៤ កើត ថ្ងៃកោរ |
| ៥ ១៥ កើត ពេញបូណ៌មី | ៦ ១ រោច | ៧ ២ រោច | ៨ ៣ រោច | ៩ ៤ រោច | ១០ ៥ រោច | ១១ ៦ រោច |

- ១ : ទិវាចូលឆ្នាំសកល
- ៧ : ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍
- ១៥ : ថ្ងៃសែនដកជើងធ្នូ
- ២១ : ថ្ងៃសែនចូលឆ្នាំចិន
- ២២ : ចូលឆ្នាំចិន
- ២៣ : ចូលឆ្នាំចិន
- ២៤ : ចូលឆ្នាំចិន

# ២

## កុម្ភៈ ២០២៣

មាឃ-ផល្គុន ឆ្នាំខាល

ព.ស. ២៥៦៦

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៩ ៨ កើត | ៣០ ៩ កើត | ៣១ ១០ កើត | ១ ១១ កើត | ២ ១២ កើត | ៣ ១៣ កើត | ៤ ១៤ កើត ថ្ងៃកោរ |
| ៥ ១៥ កើត ពេញបូណ៌មី | ៦ ១ រោច | ៧ ២ រោច | ៨ ៣ រោច | ៩ ៤ រោច | ១០ ៥ រោច | ១១ ៦ រោច |
| ១២ ៧ រោច | ១៣ ៨ រោច | ១៤ ៩ រោច | ១៥ ១០ រោច | ១៦ ១១ រោច | ១៧ ១២ រោច | ១៨ ១៣ រោច ថ្ងៃកោរ |
| ១៩ ១៤ រោច | ២០ ផល្គុន | ២១ ២ កើត | ២២ ៣ កើត | ២៣ ៤ កើត | ២៤ ៥ កើត | ២៥ ៦ កើត |
| ២៦ ៧ កើត | ២៧ ៨ កើត | ២៨ ៩ កើត | ១ ១០ កើត | ២ ១១ កើត | ៣ ១២ កើត | ៤ ១៣ កើត |
| ៥ ១៤ កើត ថ្ងៃកោរ | ៦ ១៥ កើត ពេញបូណ៌មី | ៧ ១ រោច | ៨ ២ រោច | ៩ ៣ រោច | ១០ ៤ រោច | ១១ ៥ រោច |

- ៥ : ពិធីបុណ្យមាឃបូជា ហែអ្នកតាចិន
- ១៤ : ថ្ងៃបុណ្យនៃសេចក្តីស្រលាញ់
- ២១ : ទិវាជាតិសុខភាពមាតា និងទារក
- ២៤ : ទិវាជាតិយល់ដឹងពីមីន

# ៣

## មីនា ២០២៣

ផល្គុន-ចេត្រ ឆ្នាំខាល

ព.ស. ២៥៦៦

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៦ ៧ កើត | ២៧ ៨ កើត | ២៨ ៩ កើត | ១ ១០ កើត | ២ ១១ កើត | ៣ ១២ កើត | ៤ ១៣ កើត |
| ៥ ១៤ កើត ថ្ងៃកោរ | ៦ ១៥ កើត ពេញបូណ៌មី | ៧ ១ រោច | ៨ ២ រោច | ៩ ៣ រោច | ១០ ៤ រោច | ១១ ៥ រោច |
| ១២ ៦ រោច | ១៣ ៧ រោច | ១៤ ៨ រោច | ១៥ ៩ រោច | ១៦ ១០ រោច | ១៧ ១១ រោច | ១៨ ១២ រោច |
| ១៩ ១៣ រោច | ២០ ១៤ រោច ថ្ងៃកោរ | ២១ ១៥ រោច | ២២ ចេត្រ | ២៣ ២ កើត | ២៤ ៣ កើត | ២៥ ៤ កើត |
| ២៦ ៥ កើត | ២៧ ៦ កើត | ២៨ ៧ កើត | ២៩ ៨ កើត | ៣០ ៩ កើត | ៣១ ១០ កើត | ១ ១១ កើត |
| ២ ១២ កើត | ៣ ១៣ កើត | ៤ ១៤ កើត ថ្ងៃកោរ | ៥ ១៥ កើត ពេញបូណ៌មី | ៦ ១ រោច | ៧ ២ រោច | ៨ ៣ រោច |

៣ : ទិវាវប្បធម៌ជាតិ

៤ : ទិវានយោបាយទឹក

៨ : ទិវានារីអន្តរជាតិ

២២ : ទិវាពិភពលោកទឹក និងឧតុនិយម

២៤ : ទិវាពិភពលោកកំចាត់ជម្ងឺរបេង

# ៤

## មេសា ២០២៣

ចេត្រ-ពិសាខ ឆ្នាំថោះ

ព.ស. ២៥៦៦

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៦ ៥ កើត | ២៧ ៦ កើត | ២៨ ៧ កើត | ២៩ ៨ កើត | ៣០ ៩ កើត | ៣១ ១០ កើត | ១ ១១ កើត |
| ២ ១២ កើត | ៣ ១៣ កើត | ៤ ១៤ កើត ថ្ងៃកោរ | ៥ ១៥ កើត ពេញបូណ៌មី | ៦ ១ រោច | ៧ ២ រោច | ៨ ៣ រោច |
| ៩ ៤ រោច | ១០ ៥ រោច | ១១ ៦ រោច | ១២ ៧ រោច | ១៣ ៨ រោច | ១៤ ៩ រោច | ១៥ ១០ រោច |
| ១៦ ១១ រោច | ១៧ ១២ រោច | ១៨ ១៣ រោច ថ្ងៃកោរ | ១៩ ១៤ រោច | ២០ ពិសាខ | ២១ ២ កើត | ២២ ៣ កើត |
| ២៣ ៤ កើត | ២៤ ៥ កើត | ២៥ ៦ កើត | ២៦ ៧ កើត | ២៧ ៨ កើត | ២៨ ៩ កើត | ២៩ ១០ កើត |
| ៣០ ១១ កើត | ១ ១២ កើត | ២ ១៣ កើត | ៣ ១៤ កើត ថ្ងៃកោរ | ៤ ១៥ កើត ពេញបូណ៌មី | ៥ ព.ស. ២៥៦៧ | ៦ ២ រោច |

៥ : ឆេងម៉េង

៧ : ទិវាសុខភាពពិភពលោក

១៤ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ
មហាសង្ក្រាន្ត ម៉ោង ១៦:០០

១៥ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ
វារៈវ័នបត

១៦ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ
ថ្ងៃឡើងស័ក

៣០ : កម្ពុជាចូលជាសមាជិកអាស៊ាន

# ៥

## ឧសភា ២០២៣

ពិសាខ-ជេស្ឋ ឆ្នាំថោះ ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គារ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ៣០ ១១ កើត | ១ ១២ កើត | ២ ១៣ កើត | ៣ ១៤ កើត ថ្ងៃកោរ | ៤ ១៥ កើត ពេញបូណ៌មី | ៥ ព.ស. ២៥៦៧ | ៦ ២ រោច |
| ៧ ៣ រោច | ៨ ៤ រោច | ៩ ៥ រោច | ១០ ៦ រោច | ១១ ៧ រោច | ១២ ៨ រោច | ១៣ ៩ រោច |
| ១៤ ១០ រោច | ១៥ ១១ រោច | ១៦ ១២ រោច | ១៧ ១៣ រោច | ១៨ ១៤ រោច ថ្ងៃកោរ | ១៩ ១៥ រោច | ២០ ជេស្ឋ |
| ២១ ២ កើត | ២២ ៣ កើត | ២៣ ៤ កើត | ២៤ ៥ កើត | ២៥ ៦ កើត | ២៦ ៧ កើត | ២៧ ៨ កើត |
| ២៨ ៩ កើត | ២៩ ១០ កើត | ៣០ ១១ កើត | ៣១ ១២ កើត | ១ ១៣ កើត | ២ ១៤ កើត ថ្ងៃកោរ | ៣ ១៥ កើត ពេញបូណ៌មី |
| ៤ ១ រោច | ៥ ២ រោច | ៦ ៣ រោច | ៧ ៤ រោច | ៨ ៥ រោច | ៩ ៦ រោច | ១០ ៧ រោច |

១ : ទិវាពលកម្មអន្តរជាតិ
៣ : ទិវាសេរីភាពសារព័ត៌មានពិភពលោក
៤ : ពិធីបុណ្យវិសាខបូជា
៥ : ព្រឹត្តិការណ៍កីឡាស៊ីហ្គេម លើកទី៣២ នៅកម្ពុជា (៥-១៧ ឧសភា)
៨ : ព្រះរាជពិធីច្រត់ព្រះនង្គ័ល
ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម
១៤ : ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ទិវាអ្នកម្តាយ
១៥ : ទិវាអន្តរជាតិនៃគ្រួសារ
១៦ : កំណើតនគរបាលជាតិ
២០ : ទិវាជាតិនៃការចងចាំ
៣១ : ទិវាពិភពលោកគ្មានថ្នាំជក់

# ៦

## មិថុនា ២០២៣

ជេស្ឋ-បឋមាសាឍ ឆ្នាំថោះ ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គារ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៨ ៩ កើត | ២៩ ១០ កើត | ៣០ ១១ កើត | ៣១ ១២ កើត | ១ ១៣ កើត | ២ ១៤ កើត ថ្ងៃកោរ | ៣ ១៥ កើត ពេញបូណ៌មី |
| ៤ ១ រោច | ៥ ២ រោច | ៦ ៣ រោច | ៧ ៤ រោច | ៨ ៥ រោច | ៩ ៦ រោច | ១០ ៧ រោច |
| ១១ ៨ រោច | ១២ ៩ រោច | ១៣ ១០ រោច | ១៤ ១១ រោច | ១៥ ១២ រោច | ១៦ ១៣ រោច ថ្ងៃកោរ | ១៧ ១៤ រោច |
| ១៨ បឋមាសាឍ | ១៩ ២ កើត | ២០ ៣ កើត | ២១ ៤ កើត | ២២ ៥ កើត | ២៣ ៦ កើត | ២៤ ៧ កើត |
| ២៥ ៨ កើត | ២៦ ៩ កើត | ២៧ ១០ កើត | ២៨ ១១ កើត | ២៩ ១២ កើត | ៣០ ១៣ កើត | ១ ១៤ កើត ថ្ងៃកោរ |
| ២ ១៥ កើត ពេញបូណ៌មី | ៣ ១ រោច | ៤ ២ រោច | ៥ ៣ រោច | ៦ ៤ រោច | ៧ ៥ រោច | ៨ ៦ រោច |

១ : ទិវាកុមារអន្តរជាតិ
៣ : ព្រឹត្តិការណ៍កីឡាអាស៊ានប៉ារ៉ាហ្គេម លើកទី១២ នៅកម្ពុជា
៥ : ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក
១២ : ទិវាពិភពលោកប្រឆាំងពលកម្មកុមារ
១៥ : តុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេ សម្រេចឱ្យកម្ពុជាជាម្ចាស់កម្មសិទ្ធិលើប្រាសាទព្រះវិហារ
១៨ : ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ទិវាលោកឪពុក
២២ : សែននំចាំង
២៦ : ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ៧

## កក្កដា ២០២៣

បឋមាសាឍ-ទុតិយាសាឍ ឆ្នាំថោះ ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គារ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៥ ៨ កើត | ២៦ ៩ កើត | ២៧ ១០ កើត | ២៨ ១១ កើត | ២៩ ១២ កើត | ៣០ ១៣ កើត | ១ ១៤ កើត ថ្ងៃកោរ |
| ២ ១៥ កើត ពេញបូណ៌មី | ៣ ១ រោច | ៤ ២ រោច | ៥ ៣ រោច | ៦ ៤ រោច | ៧ ៥ រោច | ៨ ៦ រោច |
| ៩ ៧ រោច | ១០ ៨ រោច | ១១ ៩ រោច | ១២ ១០ រោច | ១៣ ១១ រោច | ១៤ ១២ រោច | ១៥ ១៣ រោច |
| ១៦ ១៤ រោច ថ្ងៃកោរ | ១៧ ១៥ រោច | ១៨ ទុតិយាសាឍ | ១៩ ២ កើត | ២០ ៣ កើត | ២១ ៤ កើត | ២២ ៥ កើត |
| ២៣ ៦ កើត | ២៤ ៧ កើត | ២៥ ៨ កើត | ២៦ ៩ កើត | ២៧ ១០ កើត | ២៨ ១១ កើត | ២៩ ១២ កើត |
| ៣០ ១៣ កើត | ៣១ ១៤ កើត ថ្ងៃកោរ | ១ ១៥ កើត ពេញបូណ៌មី | ២ ១ រោច | ៣ ២ រោច | ៤ ៣ រោច | ៥ ៤ រោច |

១ : ទិវាមច្ឆាជាតិ

៣ : កម្ពុជាចូលជាសមាជិកអង្គការយូណេស្កូ

៧ : ប្រាសាទព្រះវិហារ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

៨ : ប្រាសាទសំបូរព្រៃគុក ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

៩ : រុក្ខទិវា

១១ : ទិវាប្រជាជនពិភពលោក

២៥ : ពិធីសិតទៀនព្រះវស្សា

៣១ : សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានចុះក្នុងបញ្ជីស្មារតីចងចាំនៃពិភពលោករបស់យូនេស្កូ

## ៨

## សីហា ២០២៣

ទុតិយាសាឍ-ស្រាពណ៍ ឆ្នាំថោះ ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គារ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ៣០ ១៣ កើត | ៣១ ១៤ កើត ថ្ងៃកោរ | ១ ១៥ កើត ពេញបូណ៌មី | ២ ១ រោច | ៣ ២ រោច | ៤ ៣ រោច | ៥ ៤ រោច |
| ៦ ៥ រោច | ៧ ៦ រោច | ៨ ៧ រោច | ៩ ៨ រោច | ១០ ៩ រោច | ១១ ១០ រោច | ១២ ១១ រោច |
| ១៣ ១២ រោច | ១៤ ១៣ រោច | ១៥ ១៤ រោច ថ្ងៃកោរ | ១៦ ១៥ រោច | ១៧ ស្រាពណ៍ | ១៨ ២ កើត | ១៩ ៣ កើត |
| ២០ ៤ កើត | ២១ ៥ កើត | ២២ ៦ កើត | ២៣ ៧ កើត | ២៤ ៨ កើត | ២៥ ៩ កើត | ២៦ ១០ កើត |
| ២៧ ១១ កើត | ២៨ ១២ កើត | ២៩ ១៣ កើត | ៣០ ១៤ កើត ថ្ងៃកោរ | ៣១ ១៥ កើត ពេញបូណ៌មី | ១ ១ រោច | ២ ២ រោច |
| ៣ ៣ រោច | ៤ ៤ រោច | ៥ ៥ រោច | ៦ ៦ រោច | ៧ ៧ រោច | ៨ ៨ រោច | ៩ ៩ រោច |

២ : ចូលព្រះវស្សា

១២ : ទិវាយុវជនអន្តរជាតិ

៣០ : សែនក្បាលទឹក

## ៩ កញ្ញា ២០២៣

ស្រាពណ៍-ភទ្របទ ឆ្នាំថោះ

ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៧ ១១ កើត | ២៨ ១២ កើត | ២៩ ១៣ កើត | ៣០ ១៤ កើត ថ្ងៃកោរ | ៣១ ១៥ កើត ពេញបូណ៌មី | ១ ១ រោច | ២ ២ រោច |
| ៣ ៣ រោច | ៤ ៤ រោច | ៥ ៥ រោច | ៦ ៦ រោច | ៧ ៧ រោច | ៨ ៨ រោច | ៩ ៩ រោច |
| ១០ ១០ រោច | ១១ ១១ រោច | ១២ ១២ រោច | ១៣ ១៣ រោច ថ្ងៃកោរ | ១៤ ១៤ រោច | ១៥ ភទ្របទ | ១៦ ២ កើត |
| ១៧ ៣ កើត | ១៨ ៤ កើត | ១៩ ៥ កើត | ២០ ៦ កើត | ២១ ៧ កើត | ២២ ៨ កើត | ២៣ ៩ កើត |
| ២៤ ១០ កើត | ២៥ ១១ កើត | ២៦ ១២ កើត | ២៧ ១៣ កើត | ២៨ ១៤ កើត ថ្ងៃកោរ | ២៩ ១៥ កើត ពេញបូណ៌មី | ៣០ ១ រោច |
| ១ ២ រោច | ២ ៣ រោច | ៣ ៤ រោច | ៤ ៥ រោច | ៥ ៦ រោច | ៦ ៧ រោច | ៧ ៨ រោច |

៨ : ទិវាអក្ខរកម្មអន្តរជាតិ

១៦ : ទិវាអូហ្សូនបរិស្ថានអន្តរជាតិ

២១ : ទិវាសន្តិភាពអន្តរជាតិ

២៤ : ទិវាប្រកាសរដ្ឋធម្មនុញ្ញ

២៧ : ទិវាទេសចរណ៍ពិភពលោក

២៩ : សែនលោកខែ

៣០ : បិណ្ឌ ១

## ១០ តុលា ២០២៣

ភទ្របទ-អស្សុជ ឆ្នាំថោះ

ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ១ ២ រោច | ២ ៣ រោច | ៣ ៤ រោច | ៤ ៥ កើត | ៥ ៦ រោច | ៦ ៧ រោច | ៧ ៨ រោច |
| ៨ ៩ រោច | ៩ ១០ រោច | ១០ ១១ រោច | ១១ ១២ រោច | ១២ ១៣ រោច | ១៣ ១៤ រោច ថ្ងៃកោរ | ១៤ ១៥ រោច |
| ១៥ អស្សុជ | ១៦ ២ កើត | ១៧ ៣ កើត | ១៨ ៤ កើត | ១៩ ៥ កើត | ២០ ៦ កើត | ២១ ៧ កើត |
| ២២ ៨ កើត | ២៣ ៩ កើត | ២៤ ១០ កើត | ២៥ ១១ កើត | ២៦ ១២ កើត | ២៧ ១៣ កើត | ២៨ ១៤ កើត ថ្ងៃកោរ |
| ២៩ ១៥ កើត ពេញបូណ៌មី | ៣០ ១ រោច | ៣១ ២ រោច | ១ ៣ រោច | ២ ៤ រោច | ៣ ៥ រោច | ៤ ៦ រោច |
| ៥ ៧ រោច | ៦ ៨ រោច | ៧ ៩ រោច | ៨ ១០ រោច | ៩ ១១ រោច | ១០ ១២ រោច | ១១ ១៣ រោច ថ្ងៃកោរ |

១ : ទិវាមនុស្សចាស់អន្តរជាតិ, បិណ្ឌ ២

២ : បិណ្ឌ ៣ ៣ : បិណ្ឌ ៤ ៤ : បិណ្ឌ ៥

៥ : ទិវាគ្រូបង្រៀនពិភពលោក, បិណ្ឌ ៦

៦ : បិណ្ឌ ៧ ៧ : បិណ្ឌ ៨ ៨ : បិណ្ឌ ៩

៩ : បិណ្ឌ ១០ ១០ : បិណ្ឌ ១១ ១១ : បិណ្ឌ ១២

១២ : បិណ្ឌ ១៣

១៣ : ពិធីបុណ្យភ្ជុំបិណ្ឌ ១៤ : ពិធីបុណ្យភ្ជុំបិណ្ឌ

១៥ : ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ, ពិធីបុណ្យភ្ជុំបិណ្ឌ

២៣: ទិវារំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស

២៩ : ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ ព្រះករុណា ព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចេញព្រះវស្សា

៣០ : កឋិនកាល

៣១ : បុណ្យខ្មោចហាឡូវីន

## ១១ វិច្ឆិកា ២០២៣

អស្សុជ-កត្តិក ឆ្នាំថោះ

ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៩<br>១៥ កើត ពេញបូណ៌មី | ៣០<br>១ រោច | ៣១<br>២ រោច | ១<br>៣ រោច | ២<br>៤ រោច | ៣<br>៥ រោច | ៤<br>៦ រោច |
| ៥<br>៧ រោច | ៦<br>៨ រោច | ៧<br>៩ រោច | ៨<br>១០ រោច | ៩<br>១១ រោច | ១០<br>១២ រោច | ១១<br>១៣ រោច ថ្ងៃកោរ |
| ១២<br>១៤ រោច | ១៣<br>កត្តិក | ១៤<br>២ កើត | ១៥<br>៣ កើត | ១៦<br>៤ កើត | ១៧<br>៥ កើត | ១៨<br>៦ កើត |
| ១៩<br>៧ កើត | ២០<br>៨ កើត | ២១<br>៩ កើត | ២២<br>១០ កើត | ២៣<br>១១ កើត | ២៤<br>១២ កើត | ២៥<br>១៣ កើត |
| ២៦<br>១៤ កើត ថ្ងៃកោរ | ២៧<br>១៥ កើត ពេញបូណ៌មី | ២៨<br>១ រោច | ២៩<br>២ រោច | ៣០<br>៣ រោច | ១<br>៤ រោច | ២<br>៥ រោច |
| ៣<br>៦ រោច | ៤<br>៧ រោច | ៥<br>៨ រោច | ៦<br>៩ រោច | ៧<br>១០ រោច | ៨<br>១១ រោច | ៩<br>១២ រោច |

៧ : របាំព្រះរាជទ្រព្យ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

៩ : ពិធីបុណ្យឯករាជ្យជាតិ

២៣ : ទិវាអនាម័យបរិស្ថានជាតិ

២៥ : ល្ខោនស្រមោលស្បែក ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

២៦ : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែអកអំបុក

២៧ : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែអកអំបុក

២៨ : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែអកអំបុក
ល្ខោនខោល ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

៣០ : ចាប៉ីដងវែង ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

## ១២ ធ្នូ ២០២៣

កត្តិក-មិគសិរ ឆ្នាំថោះ

ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៦<br>១៤ កើត ថ្ងៃកោរ | ២៧<br>១៥ កើត ពេញបូណ៌មី | ២៨<br>១ រោច | ២៩<br>២ រោច | ៣០<br>៣ រោច | ១<br>៤ រោច | ២<br>៥ រោច |
| ៣<br>៦ រោច | ៤<br>៧ រោច | ៥<br>៨ រោច | ៦<br>៩ រោច | ៧<br>១០ រោច | ៨<br>១១ រោច | ៩<br>១២ រោច |
| ១០<br>១៣ រោច | ១១<br>១៤ រោច ថ្ងៃកោរ | ១២<br>១៥ រោច | ១៣<br>មិគសិរ | ១៤<br>២ កើត | ១៥<br>៣ កើត | ១៦<br>៤ កើត |
| ១៧<br>៥ កើត | ១៨<br>៦ កើត | ១៩<br>៧ កើត | ២០<br>៨ កើត | ២១<br>៩ កើត | ២២<br>១០ កើត | ២៣<br>១១ កើត |
| ២៤<br>១២ កើត | ២៥<br>១៣ កើត | ២៦<br>១៤ កើត ថ្ងៃកោរ | ២៧<br>១៥ កើត ពេញបូណ៌មី | ២៨<br>១ រោច | ២៩<br>២ រោច | ៣០<br>៣ រោច |
| ៣១<br>៤ រោច | | | | | | |

១ : ទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍

២ : ល្បែងទាញព្រ័ត្រ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

៣ : ទិវាជនពិការពិភពលោក

១០ : ទិវាសិទ្ធិមនុស្សអន្តរជាតិ

១២ ទិវាជាតិប្រឆាំងការជួញដូរមនុស្ស

១៤ : អង្គរ ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិតកភណ្ឌពិភពលោក
កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ

២២ : សែនដំអ៊ី

២៥ : បុណ្យគ្រិស្តម៉ាស

២៩ : ទិវានយោបាយឈ្នះ ឈ្នះ

# ប្រតិទិនខ្មែរឆ្នាំ២០២៣

ដំណាក់កាលទី ១

២០០៤-២០០៨
ភាពជឿទុកចិត្តនៃថវិកា

ដំណាក់កាលទី ២

២០០៩-២០១៥
គណនេយ្យភាពហិរញ្ញវត្ថុ

ដំណាក់កាលទី ៣

២០១៦-២០២២
ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ដំណាក់កាលទី ៤

២០២៣-២០២៧
គណនេយ្យភាពសមិទ្ធកម្ម


ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ,
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

www.pfm.gov.kh

(+៨៥៥) ៨៥ ៧៧៧ ៩២៤

gsc@pfm.gov.kh

www.facebook.com/gscpfm


ទាញយកព្រឹត្តិបត្រ